# សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម







ខែមករា ឆ្នាំ ២០០៨

អង្គការ លីកាដូ / លីកាដូ កាណាដា

# សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម

ឯកសារនេះមានបំណងដើម្បីពន្យល់អំពីករណីដីធ្លី ដែលទាក់ទងនឹងសហគមន៍ដីក្រហមនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា។ វាត្រូវបានចងក្រងឡើងជាឧបករណ៍សំរាប់ធ្វើការតស៊ូមតិតាមផ្លូវច្បាប់ ដើម្បីជួយដល់ក្រុមគ្រួសារទាំងឡាយ ដែលបន្តរស់នៅតំបន់មានទំនាស់ និងដើម្បីតវ៉ា បញ្ហានីត្យានុកូលភាពនៃកិច្ចសន្យា ដែលគំរាមកំហែងយកដីធ្លីរបស់ពួកគេ។

របាយការណ៍នេះត្រូវបានស្រាវជ្រាវ និងសរសេរដោយអង្គការ លីកាដូ កាណាដា។ ការស្រាវជ្រាវនេះផ្អែកទាំងស្រុងទៅលើឯកសារ និងព័ត៌មានផ្សេងៗដែលតំណាងសហគមន៍ដីក្រហម និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូដែលធ្វើការទៅលើករណីនេះបានផ្តល់ឱ្យ។ អង្គការ លីកាដូ កាណាដា សូមថ្លែងអំណរគុណចំពោះតំណាងសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលបានផ្តល់ព័ត៌មាន មតិ និងយោបល់ទាំងឡាយនៅពេលធ្វើការស្រាវជ្រាវ។

ឯកសារនេះមានបំណងផ្តល់ការយល់ដឹងឱ្យបានទូលំទូលាយ ប៉ុន្តែ ដោយមានការលំបាកក្នុងការផ្ទៀងផ្ទាត់ព័ត៌មាន ការស្វែងរកឯកសារ និងការលំបាកក្នុងការធានាឱ្យមានការបកប្រែត្រឹមត្រូវ អាចមានបាត់ចំណុចខ្លះ ឬភាពមិនស៊ីគ្នាមួយចំនួន។ ប្រសិនបើមានបញ្ហានេះមែន នោះចំណុចទាំងនេះត្រូវបានចង្អុលបង្ហាញនៅក្នុងរបាយការណ៍។

ការបកប្រែឧបសម្ព័ន្ធក្នុងរបាយការណ៍នេះក្រៅផ្លូវការ ត្រូវបានធ្វើឡើងដោយអង្គការ លីកាដូ កាណាដា។ ទោះបីជាឯកសារបកប្រែជាភាសាអង់គ្លេសអាចមិនត្រឹមត្រូវតាមវេយ្យាករណ៍ តែឯកសារទាំងនោះផ្តល់នូវខ្លឹមសារនៃមាតិកានៅក្នុងឯកសារផ្សេងៗ។

ដោយបានចុះបញ្ជីនៅឆ្នាំ២០០៦ ជាអង្គការមិនយកកម្រៃ នៅទីក្រុងកូឡុំប៊ី-អង់គ្លេស អង្គការលីកាដូកាណាដា ធ្វើការតស៊ូមតិដើម្បីស្វែងរកការគាំទ្រពីអន្តរជាតិទៅលើបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា និងផ្តល់នូវជំនួយខាងការរកមូលនិធិបច្ចេកទេស និង ពិគ្រោះយោបល់ដល់អង្គការលីកាដូ។ អាសយដ្ឋានគេហទំព័រ www.licadho.org or www.licadhocanada.com ។

**អង្គការ លីកាដូ កាណាដា**

**ភ្នំពេញ ប្រទេសកម្ពុជា**

**ខែមករា ឆ្នាំ ២០០៨**

# មាតិកា


**ប្រវត្តិ** ~~~~~~~~~~ ១

**ការវិភាគផ្លូវច្បាប់លើករណីដីធ្លីនៅសហគមន៍ដីក្រហម** ~~~~~~~~~~ ៩

**ការតស៊ូយកសហគមន៍ដីក្រហមៈ សិទ្ធិលើទ្រព្យសម្បត្តិ ទល់នឹងឧបាយកលបង្ខិតបង្ខំ** ~~~~~~~~~~ ១៤

**កាលប្បវត្តិន៍លំអិតនៃព្រឹត្តិការណ៍** ~~~~~~~~~~ ២៣

ឆ្នាំ ២០០៣-២០០៤ ---------- ២៣

ឆ្នាំ ២០០៥ ---------- ២៤

ឆ្នាំ ២០០៦ ---------- ២៥

ឆ្នាំ ២០០៧ ---------- ២៧

**ឧបសម្ព័ន្ធ** ~~~~~~~~~~ ៣២

ឧបសម្ព័ន្ធទី១ ---------- ៣៣

ឧបសម្ព័ន្ធទី២ ---------- ៣៤

ឧបសម្ព័ន្ធទី៣ ---------- ៣៧

ឧបសម្ព័ន្ធទី៤ ---------- ៤០

ឧបសម្ព័ន្ធទី៥ ---------- ៤២

ឧបសម្ព័ន្ធទី៦ ---------- ៤៣

ឧបសម្ព័ន្ធទី៧ ---------- ៤៥

ឧបសម្ព័ន្ធទី៨ ---------- ៥០

ឧបសម្ព័ន្ធទី៩ ---------- ៥២

ឧបសម្ព័ន្ធទី១០ ---------- ៥៦

ឧបសម្ព័ន្ធទី១១ ---------- ៥៧

ឧបសម្ព័ន្ធទី១២ ---------- ៥៩

ឧបសម្ព័ន្ធទី១៣ ---------- ៦០

ឧបសម្ព័ន្ធទី១៤ ---------------------------------------------------- ៦១
ឧបសម្ព័ន្ធទី១៥ ---------------------------------------------------- ៦៥
ឧបសម្ព័ន្ធទី១៦ ---------------------------------------------------- ៦៦
ឧបសម្ព័ន្ធទី១៧ (ក) ------------------------------------------------ ៦៧
ឧបសម្ព័ន្ធទី១៧ (ខ) ------------------------------------------------ ៦៨
ឧបសម្ព័ន្ធទី១៨ ---------------------------------------------------- ៦៩
ឧបសម្ព័ន្ធទី១៩ ---------------------------------------------------- ៧០
ឧបសម្ព័ន្ធទី២០ (ក) ------------------------------------------------ ៧១
ឧបសម្ព័ន្ធទី២០ (ខ) ------------------------------------------------ ៧២
ឧបសម្ព័ន្ធទី២១ ---------------------------------------------------- ៧៥
ឧបសម្ព័ន្ធទី២២ ---------------------------------------------------- ៧៨
ឧបសម្ព័ន្ធទី២៣ ---------------------------------------------------- ៨០
ឧបសម្ព័ន្ធទី២៤ ---------------------------------------------------- ៨១
ឧបសម្ព័ន្ធទី២៥ ---------------------------------------------------- ៨៣

□ □ □

# ប្រវត្តិ

ដីក្រហមគឺជាសហគមន៍មួយក្នុងចំណោមសហគមន៍ជាច្រើន ដែលប្រឈមមុខនឹងការបណ្តេញចេញនៅតំបន់មាត់ទន្លេបាសាក់ ក្នុងខណ្ឌចំការមន ក្រុងភ្នំពេញ។ តំបន់នេះជាកន្លែងដីមានតម្លៃ ជាដីដែលគេចង់បានយ៉ាងខ្លាំង។ មានអគាររដ្ឋាភិបាល និងអគាររដ្ឋថ្មីៗជាច្រើន រាប់បញ្ចូលទាំងអគាររដ្ឋសភាជាតិ ដែលត្រូវបានសាងសង់កាលពីប៉ុន្មានឆ្នាំថ្មីៗកន្លងទៅ និងមានក្រុមហ៊ុនឯកជនជាច្រើនដែលចង់បានដីនៅទីនោះ ដើម្បីអភិវឌ្ឍន៍ពាណិជ្ជកម្មដែលអាចមានផលចំណេញច្រើន។ អ្នកភូមិក្នុងតំបន់ មានភាពក្លាហានណាស់ក្នុងការតស៊ូដើម្បីយកដីនេះ នៅខណៈដែលអ្នកមានអំណាចប្តឹងទាមទារយកដីរបស់ពួកគាត់។ សហគមន៍ដីក្រហមស្ថិតនៅភូមិសំបុកចាប ដែលកាលពីពាក់កណ្តាលឆ្នាំ២០០៦ មានអ្នកភូមិជាង ១.០០០ នាក់ត្រូវបានបណ្តេញចេញ (ហើយត្រូវបានផ្លាស់ទីតាំងឱ្យទៅរស់នៅក្នុងស្ថានភាពមួយស្មោកគ្រោក នៅទីតាំងមួយដែលមានចម្ងាយជាង ២០ គីឡូម៉ែត្រ)។

សហគមន៍ដីក្រហម កាលពីដើមឡើយមានសហគមន៍ចំនួន ៧ ផ្សេងៗគ្នានៅក្នុងនោះ។ សហគមន៍ដែលទាំងនេះនៅតែមាននៅឡើយសព្វថ្ងៃនេះ ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋានក្នុងតំបន់ ប៉ុន្តែពួកគេត្រូវបានបែងចែកតាមរដ្ឋបាលជា ២ ភូមិគឺ ភូមិ ២ និងភូមិ ១៥។

តាមអ្នកភូមិបានឱ្យដឹងថា អ្នកភូមិជាច្រើនបានមករស់នៅសហគមន៍ដីក្រហមតាំងពីដើមឆ្នាំរហូតដល់ពាក់កណ្តាលឆ្នាំ ១៩៨០។ ពួកគេនិយាយថាតំបន់នេះ គឺជាដីលិចទឹកដែលសំបូរទៅដោយដើមឈើនៅពេលដែលពួកគេមកដល់។ អ្នកភូមិមករស់នៅមុនគេបានកាប់ឆ្កាដើមឈើទាំងនោះ ហើយបានយកដីក្រហមមកចាក់នៅតំបន់នោះ ដែលដីក្រហមបានក្លាយជាឈ្មោះសហគមន៍នេះគឺសហគមន៍ដីក្រហម។

ជាច្រើនឆ្នាំកន្លងមក ប្រជាជននៅតំបន់ដីក្រហមបានកើនឡើង ហើយក៏ក្លាយជាប្រជាជនចំរុះ ប៉ុន្តែប្រជាជនភាគច្រើននៅទីនោះជាទូទៅបានអ្វីមួយច្រើនចែកគ្នាហូប - ពួកគេគឺជាអ្នកក្រីក្រ។ ភាគច្រើនក្នុងចំណោមពួកគេធ្វើជាកម្មករសំណង់ អ្នករត់ម៉ូតូឌុប ឬរត់រ៉ឺម៉កកង់បី អ្នកលក់ដូររបស់កំប៉ិចកំប៉ុកនៅផ្សារតូចមួយ ជាដើម ដោយរកបានប្រាក់បន្តិចបន្តួចដើម្បីចិញ្ចឹមជីវិត។

រយៈពេលបីឆ្នាំនេះ ប្រជាពលរដ្ឋនៅសហគមន៍ដីក្រហមបានរស់នៅដោយមានការភ័យខ្លាចពីការបណ្តេញចេញ ដើម្បីឈូសឆាយដីរបស់ពួកគេ ដែលមានតម្លៃតាមការប៉ាន់ប្រមាណជាង ៤៤ លានដុល្លារអាមេរិក - នឹងត្រូវរឹបអូសយកដោយក្រុមហ៊ុនឯកជនមួយ។ ក្រុមហ៊ុន ដែលមានឈ្មោះថា 7NG មានផែនការអភិវឌ្ឍពាណិជ្ជកម្មប្រកបដោយផលចំណេញនៅតំបន់នោះ រួមមានលំនៅដ្ឋាន និងអាគារការិយាល័យជាដើម។ អ្នកភូមិមួយចំនួនបានចាកចេញពីដីរបស់ពួកគាត់ដោយស្ម័គ្រចិត្តរួចទៅហើយ ចំណែកអ្នកផ្សេងទៀតនៅតែបន្តរស់នៅទីនោះនៅឡើយ គឺដើម្បីតស៊ូយកដីរបស់ខ្លួន ឬយ៉ាងហោចណាស់ ដើម្បីទទួលបាននូវសំណងសមរម្យសំរាប់

ដីខ្លួនដែរ។ ពួកអ្នកភូមិ ដែលសព្វថ្ងៃកំពុងបន្តរស់នៅលើដីនោះនៅឡើយ ស្ទើរតែជារៀងរាល់ថ្ងៃ បានស៊ូទ្រាំយ៉ាងខ្លាំងនឹងការយាយីការបំភិតបំភ័យអំពើហិង្សាការគំរាមបណ្តេញចេញ និងភាពមិនច្បាស់យ៉ាងខ្លាំងអំពីអនាគតរបស់ពួកគេ។ ពួកគាត់គឺជាសហគមន៍មួយដែលត្រូវបានគេព័ទ្ធរបងជុំវិញ។

បញ្ហាសំខាន់នៅសហគមន៍ដីក្រហមគឺថា តើសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋកម្ពុជាអាចអនុវត្តបានដែរឬទេ ឬថាតើប្រជាពលរដ្ឋអាចត្រូវបានបង្ខំ និងសម្លុតគំរាមឱ្យបោះបង់ដីរបស់ពួកគាត់បាន ឬយ៉ាងណា។

### *ទិដ្ឋភាពទូទៅនៃទំនាស់*

ទោះបីជាទំនាស់ដីធ្លីនៅសហគមន៍ដីក្រហម និងបញ្ហាផ្លូវច្បាប់ជុំវិញទំនាស់នេះ អាចទំនងជាស្មុគស្មាញក៏ដោយ ជាក់ស្តែងទៅវាជារឿងសាមញ្ញទេ:

- រដ្ឋាភិបាលបានសន្យាពីដំបូងថានឹងផ្តល់ "ដីសម្បទានសង្គមកិច្ច" ដល់អ្នកភូមិ នេះមានន័យថាពួកគេនឹងបាត់បង់ដីមួយភាគនៅកន្លែងទំនាស់ប៉ុន្តែនឹងទទួលមកវិញនូវផ្ទះល្វែងថ្មីល្អប្រសើរជាងមុននៅលើផ្ទៃដីដែលនៅសេសសល់។ ដំណោះស្រាយនោះគឺថា ក្រុមហ៊ុនឯកជននឹងទទួលបានដីមួយផ្នែកដើម្បីអភិវឌ្ឍពាណិជ្ជកម្ម ប៉ុន្តែក្រុមហ៊ុនត្រូវសាងសង់ផ្ទះល្វែងថ្មីជូនអ្នកភូមិនៅលើផ្ទៃដី ដែលនៅសល់។ ការដោះស្រាយបែបនេះ ទំនងជាចំណេញទាំងសងខាង។
- ផ្ទុយទៅវិញ ការដោះស្រាយត្រូវបានផ្លាស់ប្តូរ - អ្នកភូមិត្រូវបានប្រាប់ឱ្យប្រគល់ដីទាំងអស់នៃសហគមន៍ដីក្រហមឱ្យទៅក្រុមហ៊ុនឯកជនមួយ ហើយឱ្យទទួលយកផ្ទះល្វែងថ្មី ដែលស្ថិតនៅចម្ងាយ ២០ គីឡូម៉ែត្រ នៅជាយក្រុងភ្នំពេញទៅវិញ។
- អ្នកភូមិអះអាងថា ពួកគេមិនដែលត្រូវបានស្នើសុំឱ្យ ឬយល់ព្រមទទួលយកផ្ទះផ្សេង *នៅខាងក្រៅតំបន់ដីក្រហមឡើយ*។ អ្នកភូមិនិយាយថា នៅពេលនោះ "អ្នកតំណាងសហគមន៍របស់ពួកគាត់" បានចុះកិច្ចសន្យាយល់ព្រមទទួលយកផ្ទះល្វែងនោះដោយមិនបានឱ្យពួកគាត់ដឹងឡើយ។
- ពេលដែលពួកគាត់បានដឹងនូវអ្វីៗ ដែលបានកើតឡើង អ្នកភូមិទាមទារភ្លាមៗ ឱ្យគេប្រកាសមោឃភាពកិច្ចសន្យានោះ។ ពលរដ្ឋទាំងអស់ក៏បានឈប់ទទួលស្គាល់អ្នកទាំងនោះជាតំណាងសហគមន៍ ដែលមិនបានពិគ្រោះយោបល់ជាមួយពួកគាត់ ហើយក៏បាន ជ្រើសតាំងអ្នកតំណាងថ្មី ដើម្បីចរចាក្នុងនាមពួកគាត់ទាំងអស់។
- មានភស្តុតាងគ្រប់គ្រាន់ - ដូចដែលផ្នែកវិភាគផ្លូវច្បាប់នៃរបាយការណ៍នេះនឹងបង្ហាញឱ្យឃើញ - ថាកិច្ចសន្យាដែលត្រូវបានចុះហត្ថលេខាក្នុងនាមពលរដ្ឋសហគមន៍គឺមិនស្របច្បាប់ទេ។ តាមកិច្ចសន្យានេះមានន័យថា អ្នកភូមិទាំងនោះត្រូវបានសាកសួរយោបល់និងយល់ព្រមទាំងស្រុងជាមុនរួចហើយ( តាមពិតពួកគាត់និយាយថា មិនត្រូវបានសួរយោបល់ឡើយ)។

ដោយប្រឈមមុខនឹងស្ថានភាពបែបនេះ ក្រុមហ៊ុន 7NG និងសាលាក្រុងភ្នំពេញ - ជំនួសឱ្យការចាត់ទុកកិច្ចសន្យាជាមោឃៈ និងការចរចាដោយសុចរិតជាមួយសហគមន៍ ដើម្បីរកដំណោះស្រាយមួយដែលអាចទទួលយកបានទាំងអស់គ្នា បានចាប់ផ្តើមយុទ្ធនាការបង្ខំអ្នកភូមិឱ្យទទួលយកសុពលភាពនៃកិច្ចសន្យា ហើយបោះបង់លំនៅដ្ឋានរបស់ពួកគាត់នៅសហគមន៍ដីក្រហមដោយស្ម័គ្រចិត្ត។ ទន្ទឹមនឹងនេះ ក្រុមហ៊ុន 7NG ត្រូវបានផ្តល់ជូននូវប័ណ្ណកម្មសិទ្ធិយ៉ាងហោចណាស់លើដីមួយភាគ ហើយអាចលើដីទាំងអស់ផងដែរនៅសហគមន៍ដីក្រហម - ដោយបើកឱកាសឱ្យគេបណ្តេញអ្នកភូមិចេញនៅពេលណាក៏បាន តាមសំណើរបស់ក្រុមហ៊ុន។

នៅក្នុងការរីករាលដាលនៃការរំលោភយកដីធ្លីនៅប្រទេសកម្ពុជា រឿងរ៉ាវរបស់សហគមន៍ដីក្រហមគឺជាឧទាហរណ៍មួយដ៏ក្រៀមក្រំ ប៉ុន្តែពុំមែនបញ្ហាចំឡែកទេ វាជាវិធីដែលបុគ្គលមានអំណាច និងក្រុមហ៊ុននានាជាន់ឈ្លីសិទ្ធិលំនៅដ្ឋាន និងទ្រព្យសម្បត្តិរបស់អ្នកក្រីក្រ ដោយមានការសមគំនិតពីអាជ្ញាធររដ្ឋាភិបាលទេ។

## ពីដីសម្បទានសង្គមកិច្ច "សំរាប់អ្នកក្រីក្រ " ទៅជាកិច្ចសន្យាមួយលែងមានសុពលភាពៈ ដំណើររឿងដែលបានកើតឡើង

នៅឆ្នាំ ២០០៣ សហគមន៍ដីក្រហមគឺជាសហគមន៍មួយក្នុងចំណោមសហគមន៍ជាយក្រុងក្រីក្រទាំង ៤ នៅទីក្រុងភ្នំពេញ ដែលត្រូវបានជ្រើសរើសសំរាប់សម្បទានដីសង្គមកិច្ច ដែលជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍របស់រដ្ឋាភិបាលសំរាប់អ្នកក្រីក្រ។ ដោយបានផ្តល់ជូនដោយផ្ទាល់ និងបានប្រកាសភ្លាមៗមុនពេលបោះឆ្នោតសាកលកាលពីខែកក្កដា ឆ្នាំ ២០០៣ ដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គំនិតផ្តួចផ្តើមនេះ ត្រូវបានសាទរថាជាកម្មវិធីផ្តល់លំនៅដ្ឋានដ៏ជឿនលឿន និងគួរឱ្យស្វាគមន៍ជំនួសឱ្យការបណ្តេញចេញដោយបង្ខំដែលកំពុងរីករាលដាលនេះ។ គំនិតនោះ គឺ "ដើម្បីធ្វើការបែងចែកដី": នៅតំបន់នីមួយៗនៃតំបន់ទាំង ៤ នោះ ក្រុមហ៊ុនឯកជនត្រូវបានអនុញ្ញាតឱ្យធ្វើការអភិវឌ្ឍមួយផ្នែកនៃតំបន់សំរាប់ពាណិជ្ជកម្មផ្ទាល់របស់ខ្លួន រីឯអ្នកភូមិនឹងត្រូវបានគេផ្តល់ឱ្យជំនួសវិញជាផ្ទះល្វែងក្នុងអគារថ្មីៗ ដែលនឹងត្រូវសាងសង់នៅលើផ្នែកមួយផ្សេងទៀតនៃតំបន់នោះ។ ដូច្នេះ គេអាចធ្វើការអភិវឌ្ឍពាណិជ្ជកម្មនៅតំបន់ទាំង ៤ ប៉ុន្តែអ្នកភូមិនឹងត្រូវបានផ្តល់សំណងដោយទទួលបានជាផ្ទះល្វែងជំនួសវិញ និងជីវភាពរបស់ពួកគេនឹងមិនត្រូវបានរំខានដោយការបណ្តេញចេញទាំងស្រុងពីតំបន់នោះឡើយ។

ចំពោះសហគមន៍ដីក្រហមនេះ ទីស្តីការគណៈរដ្ឋមន្ត្រីបានសម្រេចផ្តល់ដីសម្បទានសង្គមកិច្ចជូនដល់សហគមន៍ ដែលគ្រួសារទាំងឡាយរស់នៅតំបន់នោះត្រូវផ្លាស់ទីតាំងចូលទៅរស់នៅផ្ទះថ្មីនៅលើផ្ទៃដីទំហំ ៣.៧ ហិកតា ក្នុងទំហំផ្ទៃដីសរុបទាំងអស់ ៤.៧ ហិកតាក្នុងតំបន់។ ដីដែលនៅសល់ទំហំ ១ ហិកតា ត្រូវបានផ្តល់ឱ្យក្រុមហ៊ុនឯកជនសំរាប់ធ្វើការអភិវឌ្ឍន៍ពាណិជ្ជកម្មរបស់ខ្លួន។

តាមផែនការអភិវឌ្ឍន៍របស់ទីស្តីការគណៈរដ្ឋមន្ត្រី គេបានរកឃើញចំនួនគ្រួសាររស់នៅសហគមន៍ដីក្រហម ដែលនឹងត្រូវចូលទៅរស់នៅក្នុងផ្ទះថ្មី ចំនួន ១.៤៦៥ ដែលក្នុងនោះមានមនុស្សសរុបចំនួន ៥.៨៥៤ នាក់។

មានបញ្ហាពីរជាមួយនិងផែនការអភិវឌ្ឍន៍ពីដំបូង។ បញ្ហាទី ១ គឺថា តាមការវាស់វែងជាបន្តបន្ទាប់ ដែលការិយាល័យរៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដីបានធ្វើ សហគមន៍ដីក្រហមមិនមានទំហំ ៤.៧ ហិកតានោះទេ - វាមានទំហំតែ ៣.៦ ហិកតាប៉ុណ្ណោះ។ បញ្ហាទី ២ តំណាងសហគមន៍បច្ចុប្បន្នបានតវ៉ា ហើយនៅតែតវ៉ានៅឡើយចំពោះស្ថិតិអ្នកភូមិចំនួន ១.៤៦៥ គ្រួសារ រស់នៅសហគមន៍ដីក្រហមនេះ។ ពួកគាត់និយាយថានៅពេលនោះមានអ្នកភូមិមិនលើសពី ៨០៤ គ្រួសារឡើយ ដែលបានរស់នៅសហគមន៍ដីក្រហម ។

ការផ្ទៀងផ្ទាត់ដោយឯករាជ្យនូវចំនួនគ្រួសារពិតប្រាកដដែលរស់នៅតំបន់នេះនៅពេលនោះ មិនអាចធ្វើបានឡើយ។ អាជ្ញាធរក្រុងអះអាងថា តួលេខគ្រួសារត្រឹមត្រូវ ហើយផ្អែកតាមការស្រង់ស្ថិតិនោះគឺ ១.៤៦៥ គ្រួសារ។ អ្នកតំណាងសហគមន៍បច្ចុប្បន្នបានផ្តល់បញ្ជីអ្នកភូមិមួយច្បាប់ឱ្យអង្គការ លីកាដូ កាណាដា ដែលធ្វើឡើងក្រោយពីការស្រង់ស្ថិតិរបស់សាលាក្រុង ហើយបានគូសបញ្ជាក់ថាចំនួនគ្រួសារជាច្រើននៅក្នុងបញ្ជីនោះ មិនដែលបានរស់នៅក្នុងសហគមន៍ដីក្រហមនេះទេ។ តំណាងសហគមន៍តវ៉ាថា ចំនួនគ្រួសារត្រូវបានបំប៉ោងដោយចេតនា ដើម្បីធ្វើឱ្យអំណាចនៃការតវ៉ារបស់អ្នកភូមិសហគមន៍ដីក្រហមត្រូវចុះខ្សោយ ។ ពួកសហគមន៍ និងមេធាវីរបស់ពួកគាត់និយាយផងដែរថា ពិតជាមានអំពើពុករលួយដែលស្ថិតិត្រូវបានបំប៉ោងតាមរយៈការសូកប៉ាន់ ដើម្បីអនុញ្ញាតឱ្យអ្នកក្រៅ ដែលមិនមានសិទ្ធិ មានឈ្មោះនៅក្នុងបញ្ជីទទួលផ្ទះល្វែងថ្មីដែរ។

ហេតុផលដែលនាំអោយមានការគណនាទំហំដីសហគមន៍ដីក្រហមមិនត្រឹមត្រូវ និងអ្នកទទួលខុសត្រូវចំពោះការគណនានោះ មិនច្បាស់លាស់ទេ។ ប៉ុន្តែ កំហុសឆ្គង - រួមផ្សំជាមួយស្ថិតិអ្នកភូមិ ដែលត្រូវបានបំប៉ោងនោះ - បានបង្កើតឱ្យមានបញ្ហាជាក់ស្តែងមួយ។ នៅសហគមន៍ដីក្រហមនេះ ទំហំផ្ទៃដីតូចជាងការប៉ាន់ស្មាន ហើយទំហំផ្ទៃដី ១ ហិកតា ដែលបម្រុងផ្តល់ឱ្យក្រុមហ៊ុនដើម្បីធ្វើការអភិវឌ្ឍពាណិជ្ជកម្ម (សំរាប់សាងសង់ផ្ទះដោះដូរវិញ) នោះអត់មាន។ ទន្ទឹមនឹងនេះ មាន - យ៉ាងហោចក៏មាននៅលើឯកសារដែរ - គឺមនុស្សជាច្រើនថែមទៀតដែលត្រូវចូលទៅរស់នៅផ្ទះសង់ដោះដូរ។

តាមរបាយការណ៍មួយរៀបចំឡើងដោយលោកអភិបាលខណ្ឌកាលពីខែ កញ្ញា ឆ្នាំ ២០០៤ បានឱ្យដឹងថា កំហុសឆ្គងក្នុងការគណនាទំហំផ្ទៃដីត្រូវបានរាយការណ៍ជូនលោកអភិបាលក្រុងភ្នំពេញ ហើយលោកអភិបាលក្រុងបានឆ្លើយតបថា អ្នកភូមិអាចរក្សាទុកដីទំហំ ៣.៦ ហិកតាទាំងអស់ ដែលមាននៅសហគមន៍ដីក្រហមនេះ។

ទោះបីជាមានការសន្យាបែបនេះក៏ដោយ ក៏អាជ្ញាធរមូលដ្ឋាន និងអតីតអ្នកតំណាងសហគមន៍ដីក្រហមបានស្នើសុំឱ្យពួកសហគមន៍ប្រគល់ដីមួយភាគ - ហើយក្រោយមក អាចដីទាំងមូលនៅតំបន់ដីក្រហមឱ្យទៅក្រុមហ៊ុនឯកជន។

តាមរបាយការណ៍ដដែល ដែលរៀបចំឡើងដោយលោកអភិបាលខណ្ឌបានឱ្យដឹងថា អតីតអ្នកតំណាងសហគមន៍បានទំនាក់ទំនងជាមួយក្រុមហ៊ុនឯកជនជាច្រើន ដើម្បីអភិវឌ្ឍដោយសហគមនន៍ព្រមចែកដីពាក់កណ្ដាល (៥០/៥០) ម្នាក់ៈ ក្រុមហ៊ុនអាចត្រូវបានផ្ដល់ដីទំហំ ១.៨ ហិកតានៃផ្ទៃដីសរុបទាំងអស់ទំហំ ៣.៦ ហិកតា ដើម្បីធ្វើការអភិវឌ្ឍពាណិជ្ជកម្ម ប្រសិនបើក្រុមហ៊ុននោះសាងសង់ផ្ទះល្វែងលើផ្ទៃដីដែលនៅសល់ទំហំ ១.៨ ហិកតាឱ្យអ្នកភូមិនោះ។ ប៉ុន្តែ ការចរចាបានបរាជ័យ។ ក្រោយមក អ្នកតំណាងបានចាប់ផ្ដើមពិភាក្សាជាមួយក្រុមហ៊ុនឯកជនមួយអំពីការដោះដូរដីទាំងមូលៈ ក្រុមហ៊ុនអាចយកផ្ទៃដីសរុបទាំងអស់ទំហំ ៣.៦ ហិកតា នៅសហគមន៍ដីក្រម ជាថ្នូរនឹងការសាងសង់ផ្ទះល្វែងឱ្យអ្នកភូមិនៅកន្លែងផ្សេង នាទីក្រុងភ្នំពេញ។

នៅខែមករា ឆ្នាំ ២០០៥ ក្រុមហ៊ុនសំណង់ 7NG ចំកាត់ បានចុះកិច្ចសន្យាមួយជាមួយតំណាងសហគមន៍ចំនួន ៣៦នាក់ ដោយធ្វើការដោះដូរដីសហគមន៍ដីក្រហមទាំងអស់ជាថ្នូរនឹងផ្ទះល្វែងថ្មីសំរាប់អ្នកភូមិនៅទីតាំងលំនៅដ្ឋានថ្មី ដែលមានចម្ងាយ ២០ គីឡូម៉ែត្រ។ កិច្ចសន្យានោះចែងថា ក្រុមហ៊ុន 7NG នឹងត្រូវបានប្រគល់ "ដីទំហំ ៣.៦ ហិកតា ដែលជាដីសម្បទានសង្គមកិច្ចផ្ដល់ដោយរាជរដ្ឋាភិបាលកម្ពុជាទៅឱ្យសហគមន៍ដីក្រហមទាំង ៧ " ជាថ្នូរនឹងការសាងសង់អគារផ្ទះល្វែងចំនួន ១.៤៧២ ល្វែង នៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ។

តាមឯកសារបានឱ្យដឹងថា កិច្ចសន្យានោះត្រូវបានចុះហត្ថលេខាដោយអ្នកតំណាងសហគមន៍ចំនួន ៣៦ នាក់ កាលពីថ្ងៃ ១៣ ខែ មករា និងដោយលោក ស្រី ចន្ទ ដែលជានាយកក្រុមហ៊ុន 7NG បីថ្ងៃក្រោយមក។ មានមន្ត្រីជាច្រើន រួមមានទាំងអតីតមេភូមិ ២ និងមេភូមិ ១៥ ជាសាក្សីក្នុងការចុះកិច្ចសន្យានោះដែរ។

អ្នកភូមិសហគមន៍ដីក្រហមនិយាយថា អ្នកតំណាងរបស់ពួកគាត់មិនបានសាកសួរយោបល់ខ្លួនជាមុនឡើយ អំពីការចុះកិច្ចសន្យានេះ ហើយថាពួកគាត់មិនដែលយល់ព្រមផ្លាស់ទីតាំងចេញពីដីនេះឡើយ។ នៅថ្ងៃទី ២០ ខែ មករា អ្នកភូមិបានដឹងថាមានការចុះកិច្ចសន្យា នៅពេលពួកគាត់ចូលរួមការប្រជុំមួយនៅសាលមហោស្រពទន្លេបាសាក់ដែលនៅទីនោះអាជ្ញាធរមូលដ្ឋាននិងអ្នកតំណាងសហគមន៍ បានជម្រាបឱ្យពួកគាត់ដឹង។

ក្នុងគោលបំណងដើម្បីធ្វើឱ្យការភ័យខ្លាចរបស់អ្នកភូមិបានស្ងាត់ទៅវិញមន្ត្រីដែលមានវត្តមាននៅកិច្ចប្រជុំនោះ បានធានាអះអាងសាជាថ្មីចំពោះអ្នកភូមិពេលប្រជុំថា *គ្មានអ្នកណាមួយនឹងត្រូវបានបង្ខំឱ្យទទួលយកកិច្ចសន្យានោះទេ*។ អ្នកភូមិត្រូវបានគេប្រាប់ថា ប្រសិនបើ

ពួកគាត់ចង់ទទួលយកសំណើរបស់ក្រុមហ៊ុន 7NG តាមកិច្ចសន្យា ពួកគាត់គួរចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន។ ប៉ុន្តែ ប្រសិនបើពួកគាត់មិនចង់ទទួលយកសំណើរនោះទេ នឹងពុំមានបញ្ហាអ្វីកើតឡើងចំពោះពួកគាត់ឡើយ ។

### *ក្រោយពីបានចុះកិច្ចសន្យា*

មានការធានាអះអាងសាថ្មីជាច្រើនថា កិច្ចសន្យាត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្តទាំងស្រុងដោយសហគមន៍ដីក្រហម ដែលភ្លាមនោះអ្នកភូមិបានបង្ហាញភស្តុតាង និងបញ្ជាក់ថាការអះអាងនេះមិនត្រឹមត្រូវទេ។ ក្រុមហ៊ុន 7NG និងអាជ្ញាធរមូលដ្ឋានបានចាប់ផ្តើមយុទ្ធនាការ-ដំបូងប្រើកលល្បិច ប៉ុន្តែក្រោយមកប្រើសំដីអសុរោះខ្លាំងៗដោយផ្ទាល់ - ដើម្បីបង្ខំអ្នកភូមិឱ្យទទួលយកកិច្ចសន្យានោះ ហើយចាកចេញពីសហគមន៍ដីក្រហម ។

ឧបាយកលបង្ខិតបង្ខំកាន់តែមានខ្លាំងឡើងៗ ដោយអ្នកភូមិជាច្រើន មានការស្រងាកចិត្តព្រោះគ្មានការពិគ្រោះយោបល់អំពីកិច្ចសន្យា និងមានការភ័យខ្លាចក្រែងបញ្ហាកាន់តែរីកធំទៅៗ ដូចនេះក៏បានចាប់ផ្តើមរៀបចំខ្លួនដើម្បីការពារសិទ្ធិលើទ្រព្យសម្បត្តិរបស់ពួកខ្លួន។ ពួកប្រជាសហគមន៍បានធ្វើការតវ៉ាជំទាស់នឹត្យានុកូលភាពនៃកិច្ចសន្យា និងភាពស្របច្បាប់នៃ "អ្នកតំណាង "របស់ពួកគាត់ដែលបានចុះហត្ថលេខាលើកិច្ច សន្យាដោយមិន បានឱ្យពួកគាត់ដឹងសោះ ។

អ្នកភូមិបានជ្រើសតាំងអ្នកតំណាងសហគមន៍ថ្មីចំនួន ២៣ រូប ដោយនិយាយថា ពួកគេលែងទទួលស្គាល់អ្នកតំណាងចាស់ (ដែលអាជ្ញាធរបានចាត់តាំង ដោយមិនជ្រើសរើសតាមការបោះឆ្នោត) ដែលបានចុះកិច្ចសន្យានោះទៀតហើយ។ នៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០០៥ អ្នកតំណាងថ្មីបានបញ្ជូនញត្តិមួយច្បាប់ ដែលផ្តិតមេដៃដោយអ្នកភូមិចំនួន ៨០៤ គ្រួសារ នៅសហគមន៍ដីក្រហមទៅសាលាក្រុងភ្នំពេញ ដើម្បីស្នើសុំឱ្យមោឃភាពកិច្ចសន្យាជាមួយក្រុមហ៊ុន 7NG ពីព្រោះកិច្ចសន្យានោះត្រូវធ្វើឡើងដោយមិនបានឱ្យអ្នកភូមិដឹង។ នៅថ្ងៃទី២៦ ខែកុម្ភៈ អ្នកតំណាងបានធ្វើការតាមដានដោយផ្ញើរលិខិតមួយច្បាប់ទៅតំណាងរាស្ត្រមួយរូប ដើម្បីស្នើសុំកិច្ចអន្តរាគមន៍ពីលោក ដើម្បីឱ្យជួយមោឃភាពកិច្ចសន្យានោះ ។

នៅរដូវប្រាំង ឆ្នាំ ២០០៦ អ្នកតំណាងទាំងនេះបានប្រមូលអ្នកភូមិជាង ៣៧០ គ្រួសារ ដើម្បីផ្តិតមេដៃនៅលើឯកសារមួយ ដែលទទួលស្គាល់តួនាទីជាអ្នកដឹកនាំរបស់ពួកគាត់ ដោយសង្ឃឹមថានឹងទទួលបានភាពស្របច្បាប់នៅតុលាការ ។

ចាប់តាំងពីពេលនោះមក ជិតបីឆ្នាំហើយ អ្នកភូមិសហគមន៍ដីក្រហមបានធ្វើការអំពាវនាវ និងដាក់ពាក្យបណ្តឹងរាប់មិនអស់ទៅអាជ្ញាធរនានា - ព្រមទាំងជូននាយករដ្ឋមន្ត្រី មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ផ្សេងៗ សាលាក្រុងភ្នំពេញ ការិយាល័យរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ និង ទៅកាន់តុលាការរាជធានីភ្នំពេញ - ដើម្បីមោឃភាពកិច្ចសន្យានោះ ។

ទោះបីជាបណ្តឹងអំពីនីត្យានុកូលភាពនៃកិច្ចសន្យារបស់ខ្លួននៅមានសុពលភាពក៏ដោយ(សូមមើលផ្នែកវិភាគផ្លូវច្បាប់ខាងក្រោម)ក៏ការអំពាវនាវរបស់អ្នកភូមិមិនត្រូវបានគេធ្វើដឹងធ្វើឮឡើយ។ អាជ្ញាធរមិនត្រឹមតែមិនបានការពារ ប៉ុន្តែថែមទាំងបានរំលោភបំពានទៅលើសិទ្ធិលើទ្រព្យសម្បត្តិរបស់អ្នកភូមិទៀតផង។ ឧទាហរណ៍សំខាន់មួយគឺៈ កាលពីខែ ធ្នូ ឆ្នាំ ២០០៦ ការិយាល័យរៀបចំដែនដីនគររូបនីយកម្មនិងសំណង់បានចេញសេចក្តីសម្រេចឱ្យផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី យ៉ាងហោចណាស់ក៏សំរាប់ដីមួយផ្នែកនៃសហគមន៍ដីក្រហម ឱ្យក្រុមហ៊ុន 7NG[១] ដែរ។

នៅពេលជាមួយគ្នានេះ អ្នកភូមិស៊ូទ្រាំនឹងយុទ្ធនាការបំភិតបំភ័យជាបន្តបន្ទាប់ - ធ្វើឡើងជាពិសេសទៅលើអ្នកតំណាងថ្មីរបស់ពួកគាត់ដើម្បីបង្ខំឱ្យបោះបង់ចោលដីរបស់ខ្លួន។ យុទ្ធនាការនេះ រួមមានការគំរាមកំហែង អំពើហិង្សលើរាង្គកាយ សកម្មភាពបង្ករឿង និងការប្តឹងបណ្តឹងព្រហ្មទណ្ឌដោយមិនសមហេតុផលចំពោះពួកតំណាងនោះ។ (សូមមើលផ្នែកការតស៊ូដើម្បីយកសហគមន៍ដីក្រហមខាងក្រោម ចំពោះព័តិមានពិស្តារអំពីការយាយី ដែលអ្នកភូមិបានទទួលរងកំឡុងពេលតស៊ូដើម្បីការពារសិទ្ធិលើទ្រព្យសម្បត្តិរបស់ពួកគេ។)


កងរាជអាវុធហត្ថបំភិតបំភ័យអ្នកភូមិ

ពេលវេលាចេះតែកន្លងផុតទៅ អ្នកភូមិរាប់រយគ្រួសារនៅសហគមន៍ដីក្រហមបានទទួលយកលក្ខខណ្ឌរបស់ក្រុមហ៊ុន 7NG ហើយបានព្រមចាកចេញពីដី។ ពួកគាត់មួយចំនួនអាចពេញចិត្តនឹងការដោះស្រាយ ដែលក្រុមហ៊ុនបានផ្តល់ឱ្យ ប៉ុន្តែចំពោះអ្នកខ្លះទៀត យុទ្ធនាការនៃការបំភិតបំភ័យអាចជាកត្តាមួយធ្ងន់ធ្ងរក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ពួកគាត់ដើម្បីចាកចេញ។ ការពិតគឺថា ប្រសិនបើ ក្រុមហ៊ុន 7NG បានផ្តល់ដំណោះស្រាយត្រឹមត្រូវពិតប្រាកដដល់អ្នកភូមិ ហើយពួកគេមានឆន្ទៈបោះបង់សិទ្ធិរស់នៅសហគមន៍ដីក្រហមដោយស្ម័គ្រចិត្តទាំងស្រុង នោះយុទ្ធនាការនៃការបំភិតបំភ័យនឹងមិនចាំបាច់ប្រើប្រាស់ឡើយ។

ការផ្លាស់ទីតាំងថ្មីទៅកាន់ភូមិដំណាក់ត្រយឹង អាចជាការសមរម្យ និង អាចទទួលយកបានសំរាប់អ្នកភូមិមួយចំនួននៅសហគមន៍ដីក្រហម ប៉ុន្តែសំរាប់អ្នកផ្សេងទៀត តំបន់នោះ - នៅជាយក្រុងភ្នំពេញដែលមានចម្ងាយ ២០ គីឡូម៉ែត្រពីលំនៅដ្ឋាន និង ការងារបច្ចុប្បន្នរបស់ខ្លួន - ជាមូលហេតុដែលមិនអាចទទួលយកបានឡើយ។

---

[១] ប័ណ្ណកម្មសិទ្ធិដីធ្លី — សូមមើលឧបសម្ព័ន្ធ ១៧ ក) និង ខ) - ផ្តល់កម្មសិទ្ធិដីទំហំ ២ ហិកតានៅភូមិ ២ នៃសហគមន៍ដីក្រហមទៅឱ្យក្រុមហ៊ុន 7NG ។ គេមិនបានដឹងទេថាតើប្លង់កម្មសិទ្ធិស្រដៀងគ្នានេះត្រូវបានផ្តល់ឱ្យក្រុមហ៊ុនសំរាប់ដីនៅសល់នៅសហគមន៍ដីក្រហមដែរឬទេ ប៉ុន្តែមន្ត្រីក្រុមហ៊ុនបានអះអាងម្តងហើយម្តងទៀតថា ពួកគេមានប័ណ្ណកម្មសិទ្ធិដីទាំងអស់នៅសហគមន៍នេះ។

ដោយទទួលស្គាល់បញ្ហានេះ ក្រុមហ៊ុន 7NG បានផ្តល់ជម្រើសមួយដល់អ្នកភូមិ ជម្រើសនោះគឺក្រុមហ៊ុននឹងទិញដីពួកគាត់ដោយផ្ទាល់ ជំនួសឱ្យការផ្តល់ផ្ទះល្វែងនៅភូមិដំណាក់ត្រយឹង។ ប៉ុន្តែ តម្លៃដែលក្រុមហ៊ុនផ្តល់ឱ្យគឺទាបជាងតម្លៃទីផ្សារខ្លាំងពេក ចំពោះដីតំបន់ទន្លេបាសាក់ ហើយដោយតម្លៃដីចេះតែកើនឡើងនៅប្រទេសកម្ពុជា តម្លៃនេះមិនអាចគ្រប់គ្រាន់ដើម្បីទិញដីផ្នែកណាមួយ ដែលប្រហាក់ប្រហែលគ្នានៅទីក្រុងភ្នំពេញបានឡើយ។ តម្លៃដែលក្រុមហ៊ុនហ៊ានទិញគឺខុសៗគ្នា ប៉ុន្តែថ្មីៗនេះ តាមដឹងតម្លៃខ្ពស់បំផុតដែលក្រុមហ៊ុនហ៊ានទិញអ្នកភូមិ គឺប្រហែល ៧.៥០០ ដុល្លារអាមេរិក សំរាប់ផ្ទះទំហំ ៣២ម $^{២}$ (ឬស្មើនឹង ២៣៤ ដុល្លារអាមេរិកក្នុង ១ ម៉ែត្រក្រឡា) -ដែលតម្លៃនេះអាចទាបជាងតម្លៃទីផ្សាពាក់កណ្តាល[២] ។

នៅពេលសរសេរឯកសារនេះ តាមអ្នកតំណាងសហគមន៏បានឱ្យដឹងថា មានអ្នកភូមិ ២៨០គ្រួសារ ដែលបដិសេធដំណោះស្រាយរបស់ក្រុមហ៊ុន កំពុងរស់នៅសហគមន៏ដីក្រហមនៅឡើយ។ ពួកគេបន្តស្វែងរកដំណោះស្រាយមួយប្រកបដោយយុត្តិធមិ និងត្រឹមត្រូវអាចទទួលយកបានសំរាប់ខ្លួនចំពោះបញ្ហាទំនាស់ដីធ្លីនេះ ។ពួកគាត់ចង់បានដំណោះស្រាយមួយដែលអនុញ្ញាតឱ្យខ្លួននៅនឹងកន្លែង ប៉ុន្តែ ប្រសិនបើដំណោះស្រាយនេះមិនអាចធ្វើបានទេ- យ៉ាងហោចណាស់ ក៏បានទទួលសំណងជាប្រាក់កាសដោយត្រឹមត្រូវ និងសមរម្យសំរាប់ទ្រព្យសម្បត្តិរបស់ពួកគាត់។

ផ្នែកខាងក្រោមនៃរបាយការណ៏នេះ ដែលមានចំណងជើងថា ការវិភាគផ្លូវច្បាប់ ពិនិត្យទៅលើបញ្ហាផ្លូវច្បាប់ - ហើយជាពិសេស លើអនីត្យានុកូលភាពនៃកិច្ចសន្យារបស់ក្រុមហ៊ុន 7NG ដែលធ្វើឡើងជាមួយអតីតអ្នកតំណាងសហគមន៏។ ផ្នែកបន្ទាប់មកទៀត ដែលមានចំណងជើងថា ការតស៊ូដើម្បីយកសហគមន៏ដីក្រហម ពិនិត្យជាពិស្តារបន្ថែមទៀតទៅលើការតស៊ូរបស់សហគមន៏ ដើម្បីរក្សាបាននូវសិទ្ធិលើដីធ្លីរបស់ខ្លួន ដោយសន្តិវិធី និងដោយស្របច្បាប់ និងយុទ្ធនាការគាបសង្កត់ ដែលបានប្រើប្រាស់ទៅលើពួកសហគមន៏។

□ □ □

[២] ប្រភព : កាសែតឌឺ ឃាមបូឌាដេលី ចេញផ្សាយថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០០៧ និងក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ ប៊ុណ្ណា

# ការវិភាគផ្លូវច្បាប់លើករណីដីធ្លីនៅសហគមន៍ដីក្រហម

ករណីនៅតំបន់សហគមន៍ដីក្រហម ដែលបានចោទជាការលំបាកយ៉ាងខ្លាំងនោះ គឺថាកម្មសិទ្ធិដីធ្លី ដែលអ្នកភូមិបានកាន់កាប់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយនោះ មិនត្រូវបានគេកំណត់ឱ្យបានច្បាស់លាស់នៅឡើយទេ។ ការវិភាគផ្លូវច្បាប់ ដូចខាងក្រោមនឹងសិក្សាអំពីករណីផ្លូវច្បាប់តាមទស្សនៈផ្សេងៗគ្នានៅតំបន់ដីក្រហមនេះ។ ជាការគួរឱ្យចាប់អារម្មណ៍ដោយកត់សម្គាល់ថា ពីជ្រុងណាក៏បាន ដែលយើងជ្រើសរើសយកមកវិភាគលើករណីនេះ វាហាក់បីដូចជាថា ការដោះដូរដីធ្លី ដែលបានកើតឡើង តាមទស្សនៈនីមួយៗគឺផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ទាំងឡាយ។

## ដីសម្បទានសង្គមកិច្ចត្រូវបានប្រគល់ជូនសហគមន៍ដីក្រហម

ផែនការអភិវឌ្ឍន៍ ដែលទីស្តីការគណៈរដ្ឋមន្ត្រីបានដាក់ចេញកាលពីខែកក្កដា ឆ្នាំ ២០០៣ កំណត់ថា "សហគមន៍ដីក្រហម [.....] ត្រូវបាន ផ្តល់ជូនជាដីសម្បទានសង្គមកិច្ច "។ ទោះបីជាឯកសារនេះពុំបានចងកាតព្វកិច្ចខាងផ្លូវច្បាប់ ឬពុំមានប្រសិទ្ធិភាពខាងផ្លូវច្បាប់ភ្លាមក៏ដោយ ក៏ឯកសារនេះត្រូវបានផ្តល់នូវអំណាចនយោបាយជាន់ខ្ពស់មួយទៅហើយ ពីព្រោះវាត្រូវបានដាក់ចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី។ ហេតុដូច្នេះផែនការអភិវឌ្ឍន៍នេះបង្ហាញឱ្យឃើញនូវចេតនារបស់រដ្ឋាភិបាលចំពោះសហគមន៍ដីក្រហម ក្នុងការផ្តល់ដីសម្បទាន សង្គមកិច្ចជូនដល់សហគមន៍នេះ។

ជំពូក ៥ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ចែងអំពីដីសម្បទាន។ មាត្រា ៥៣ ចែងថា " សម្បទានដីគឺជាសិទ្ធិស្របច្បាប់ ដែលមានចែងក្នុងឯកសារគតិយុត្ត ចេញដោយអាជ្ញាធរមានសមត្ថកិច្ច តាមអំណាចឆន្ទានុសិទ្ធិឱ្យរូបវន្ត ឬនីតិបុគ្គល ឬក្រុមមនុស្ស ដើម្បីកាន់កាប់ដី និងប្រើប្រាស់សិទ្ធិលើដីនោះតាមការកំណត់នៃច្បាប់នេះ [សេចក្តីបញ្ជាក់បន្ថែម] "។ តាមព័ត៌មាន ដែលយើងមាន ឯកសារគតិយុត្តនេះ ទំនងមិនទាន់បានចេញនៅឡើយទេ។

ទោះបីជាយ៉ាងណាក៏ដោយ គេអាចចាត់ទុកផែនការអភិវឌ្ឍន៍ជាសក្ខីកម្មដ៏រឹងមាំមួយនៃគោលនយោបាយរបស់រដ្ឋាភិបាលចំពោះសហគមន៍នេះ។ ជាលទ្ធផល តំណាងសហគមន៍ និងអ្នកភូមិទាំងឡាយ បានអំពាវនាវម្តងហើយម្តងទៀតដល់លោកនាយករដ្ឋមន្ត្រី ឱ្យដោះស្រាយករណីនេះដោយផ្ទាល់ និងសុំអនុញ្ញាតឱ្យពួកគាត់បន្តរស់នៅលើដីរបស់ខ្លួន និងបែងចែកជាមួយក្រុមហ៊ុន។

ឯកសារជាច្រើនបង្ហាញថា សាលាក្រុងភ្នំពេញបានចាត់ទុកឯកសារនេះ ថាមានអំណាចផ្តាច់មុខ ពីព្រោះកាលពីខែកញ្ញា ឆ្នាំ ២០០៤ ខ្លួនបានចេញរបាយការណ៍មួយ មានចំណងជើងថា "របាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំការអភិវឌ្ឍន៍នៅនឹងកន្លែងនៅតំបន់សហ-គមន៍ដីក្រហម "។ នៅក្នុងរបាយការណ៍នេះ សាលាក្រុងទទួលស្គាល់ថា : " សហគមន៍ដីក្រហមបានទទួលគោលនយោបាយពី សម្តេច

សែន ព្រមទាំងត្រូវបានលោកអនុញ្ញាតឱ្យធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង ហើយនៅពេលជាមួយគ្នានេះដែរ ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញលិខិតមួយលេខ ៨៧៥ ចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៣ ដែលបានអនុញ្ញាតជាគោលការណ៍ឱ្យសាលាក្រុងភ្នំពេញចាត់ចែងដីសម្បទានសង្គមកិច្ចនេះ [.......] [សេចក្តីបញ្ជាក់បន្ថែម] ”។

លើសពីនេះទៅទៀត សាលាក្រុងបានប្រកាសថា ខ្លួនបានចេញលិខិតមួយ [លេខ ២៥៤] ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ”ដើម្បីជម្រុញឱ្យមានការអនុវត្តគោលនយោបាយខាងលើប្រកបដោយប្រសិទ្ធិភាព ”។ ជាចុងក្រោយ ឯកសារកំណត់ពីការគណនាឡើងវិញទៅលើទំហំផ្ទៃដីសរុបទាំងមូលនៅតំបន់ដីក្រហមតាមការវាស់វែងសាជាថ្មី។ នៅពេលបានជ្រាបថា ទំហំដី ដែលបានវាស់មានទំហំតូចជាងការគិតពីដំបូង អភិបាលក្រុងបានមានប្រសាសន៍ថា ”ទំហំដី ដែលមានពិតប្រាកដ នឹងត្រូវផ្តល់ជូនសហគមន៍ដោយគ្មានការរឹបអូសយកផ្នែកណាមួយទុកជាសម្បត្តិរដ្ឋឡើយ ”។

វិធានការ ដែលសាលាក្រុងបានចាត់ឡើង ក៏ដូចជាសេចក្តីថ្លែងការណ៍របស់ខ្លួន ទំនងជាបញ្ជាក់ថា ដីសហគមន៍ដីក្រហម ត្រូវបានចាត់ទុកដោយភាគីពាក់ព័ន្ធទាំងអស់ថាជាដីសម្បទានសង្គមកិច្ច និងបញ្ជាក់ថា គោលនយោបាយនានា ដែលបានដាក់ចេញនៅក្នុងផែនការអភិវឌ្ឍន៍ ដែលរៀបចំឡើងកាលពីខែកក្កដា ឆ្នាំ ២០០៣ ត្រូវបានអនុវត្ត ហើយអំណាចនយោបាយជាន់ខ្ពស់ត្រូវបានផ្តល់ជូនផងដែរ។ ប៉ុន្តែ មកដល់ពេលនេះ សាលាក្រុងពុំបានអនុវត្តផែនការនោះឡើយ។ ផ្ទុយទៅវិញ សាលាក្រុង ឥឡូវ កំពុងតែធ្វើការជាមួយក្រុមហ៊ុអភិវឌ្ឍន៍ឯកជន ដោយគាំទ្រយ៉ាងខ្លាំងឱ្យមានការផ្លាស់ទីតាំងចេញពីកន្លែងបច្ចុប្បន្ន។ នេះគឺជាការខកខានយ៉ាងជាក់ស្តែងមួយរបស់សាលាក្រុងភ្នំពេញក្នុងការមិនអនុវត្តការអភិវឌ្ឍនៅនឹងកន្លែងនៅសហគមន៍ដីក្រហមនេះ ជាដីសម្បទានសង្គមកិច្ច ហើយក៏កំពុងតែរំលោភបំពានដោយផ្ទាល់លើគោលបំណងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងនាយករដ្ឋមន្ត្រី ដែលបានលើកឡើងយ៉ាងច្បាស់នោះ។

## ដីក្រហមគឺជាដីឯកជនរបស់រដ្ឋ

នៅពេលជាមួយគ្នានេះ ដោយយល់ឃើញថា ឯកសារគតិយុត្ត ដូចបានលើកឡើងខាងលើ ដែលបញ្ជាក់ថាដីក្រហមជាដីសម្បទានសង្គមកិច្ច មិនទាន់ត្រូវបានចេញ នៅពេលចុះហត្ថលេខាលើកិច្ចសន្យារវាងអតីតអ្នកតំណាងសហគមន៍ និងក្រុមហ៊ុន គេអាចសន្មតបានថា ដីក្រហមមិនដែលត្រូវបានគេប្តូរឱ្យទៅជាដីសម្បទានសង្គមកិច្ចត្រឹមត្រូវនោះទេ ហើយផ្ទុយទៅវិញ គឺជាដីឯកជនរបស់រដ្ឋ - ហើយការពិត វានៅតែជាដីឯកជនរបស់រដ្ឋ។ ពិតណាស់ មាត្រា ៥៨ នៃច្បាប់ភូមិបាលគាំទ្រជំហរនេះ ដោយចែងថា ”សម្បទានដីអាចធ្វើឡើងបានតែនៅលើដីជាចំណែកនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ”។ ម្យ៉ាងទៀត ប្រសិនបើ ដីក្រហមមិនមែនជាដីឯកជនរបស់រដ្ឋទេ នោះគេក៏មិនអាចចាត់ទុកវាជាដីសម្បទានសង្គមកិច្ចបានឡើយ ទោះបីជា ឋានៈដីនេះ ត្រូវបានកំណត់យ៉ាងសុក្រិត្យដោយច្បាប់ថាជា

ដីសម្បទានសង្គមកិច្ចក៏ដោយ។ មុនពេលតំបន់ដីក្រហមត្រូវបានប្រើប្រាស់ ក៏បញ្ជាក់ផងដែរអំពីឋានៈដីនេះ ពីព្រោះគ្មានកំណត់ហេតុដីធ្លី ដែលធ្លាប់បានដាក់ឱ្យប្រើប្រាស់ ដូចដែលត្រូវបានកំណត់ថាជាដីសាធារណៈរបស់រដ្ឋ តាមមាត្រា ១៥ នៃច្បាប់ភូមិបាលឡើយ។



អ្នកភូមិដើរជាក្បួនដើម្បីទាមទារសិទ្ធិពួកគេ

ច្បាប់ភូមិបាលអនុញ្ញាតឱ្យប្រជាពលរដ្ឋរស់នៅលើអចលនទ្រព្យឯកជនរបស់រដ្ឋ ដើម្បីអាស្រ័យផលតាមបែបភោគៈនៅលើអចលទ្រព្យរបស់ពួកខ្លួនដែលក្រោយមកអាចក្លាយជាកម្មសិទ្ធិពេញលេញ។ ដើម្បីទទួលបានដូច្នេះ ភោគីត្រូវតែរស់នៅលើអចលនទ្រព្យរបស់ខ្លួនរយៈពេលអប្បបរិមា ៥ ឆ្នាំ មុនពេលច្បាប់ភូមិបាលឆ្នាំ២០០១ត្រូវបានអនុម័ត។ លើសពីនេះទៅទៀត ភោគៈនោះត្រូវតែពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត។ ប្រជាពលរដ្ឋនៅតំបន់ដីក្រហមបានបំពេញតាមលក្ខខណ្ឌទាំងអស់នេះរួចហើយ។

សៀវភៅគ្រួសារនៅតំបន់ដីក្រហមផ្តល់ភស្តុតាងគ្រប់គ្រាន់ចំពោះការរស់នៅរបស់ពួកគាត់នៅតំបន់ដីក្រហម ហើយបញ្ជាក់ច្បាស់អំពីសិទ្ធិភោគៈរបស់ខ្លួននៅលើដីនោះ។

ច្បាប់ភូមិបាលឆ្នាំ ២០០១ ចែងក្នុងមាត្រា ៥ ផងដែរ ថា " គ្មានបុគ្គលណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនោះ មិនមែនដើម្បីផលប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ជា *បន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌* [សេចក្តីបញ្ជាក់បន្ថែម] "។ តាមអ្នកភូមិ បានឱ្យដឹងថា លក្ខខណ្ឌផ្តល់សំណងដោយសមរម្យ និងយុត្តិធម៌ មិនទំនងត្រូវបានបំពេញឱ្យបានទាន់ពេលទេត្រង់ចំនុចនេះ។ តាមការប្រៀបធៀបមួយ ទោះបីជាក្រុមហ៊ុនអចលនទ្រព្យ ប៊ុណ្ណា បានវាយតម្លៃដីកាលពីពេលថ្មីៗនេះ ថាមានតម្លៃលើសពី ១.០០០ដុល្លាអាមេរិក ក្នុងមួយម៉ែត្រក្រឡាក៏ដោយ[៣] ក៏អ្នកភូមិដីក្រហម បច្ចុប្បន្ននេះ ត្រូវបានផ្តល់តម្លៃប្រហែលជា ២៣៤ ដុល្លាអាមេរិក ក្នុងមួយម៉ែត្រក្រឡាតែប៉ុណ្ណោះ។

## កិច្ចសន្យាត្រូវបានចុះហត្ថលេខាដោយបុគ្គលដែលគ្មានសមត្ថភាព

ករណីសហគមន៍ដីក្រហម លើកយកមកសំអាងផងដែរនូវច្បាប់កម្ពុជាស្តីពីកិច្ចសន្យា ដែលជាក្រិត្យច្បាប់ លេខ៣៨ ក្រ.ច *ស្តីអំពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា* (ពីនេះតទៅហៅថា ច្បាប់កិច្ចសន្យា) ដែលបានអនុមត័នៅឆ្នាំ ១៩៨៨

---

[៣] ការវាយតម្លៃដីដោយក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ ប៊ុណ្ណា បានប៉ាន់ប្រមាណតម្លៃដីសរុបនៅតំបន់ដីក្រហមថា មានតម្លៃប្រហែលជា ៤៤ លានដុល្លារអាមេរិក ដែលនេះមានន័យថា វាមានតម្លៃលើសពី ១.០០០ ដុល្លារអាមេរិកក្នុងមួយម៉ែត្រកាក្រឡា។ សូមមើលកាសែត ឌឺ ឃែមបូឌា ដេលី ចេញថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០០៧។

ពីព្រោះករណីដីក្រហមនេះ ចាំបាច់ត្រូវផ្អែកទៅលើកិច្ចសន្យាមួយ ដែលសហគមន៍និងតំណាងសហគមន៍បច្ចុប្បន្ន ចាត់ទុកជាកិច្ចសន្យាមិនស្របច្បាប់។ កត្តាជាច្រើននៃច្បាប់កិច្ចសន្យាគាំទ្រជំហរនេះ ហេតុដូច្នេះហើយ ក៏ជំទាស់នឹងនីត្យានុកូលភាពនៃកិច្ចសន្យា ដែលអតីតអ្នកតំណាងសហគមន៍ និងក្រុមហ៊ុន 7NG បានចុះហត្ថលេខា។

មាត្រា ១ នៃច្បាប់កិច្ចសន្យាចែងថា "កិច្ចសន្យា គឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គល២នាក់ ឬច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬច្រើនដែលទាក់ទិននឹងខ្លួន។ តាមនិយមន័យខាងលើ បុគ្គលអាចជារូបវន្តបុគ្គល ឬ ជានីតិបុគ្គល។ *នីតិបុគ្គលអាចធ្វើកិច្ចសន្យាតាមរយៈបុគ្គល ដែលជាតំណាងរបស់ខ្លួនបាន* [សេចក្តីបញ្ជាក់បន្ថែម]"។ បន្ថែមលើនេះទៀត មាត្រា ៣ ចែងថា កិច្ចសន្យាមួយអាចយកជាការបាន លុះត្រាតែ : [......] ធ្វើឡើង*ដោយបុគ្គលទាំងឡាយដែលមានសមត្ថភាពចុះកិច្ចសន្យា* [សេចក្តីបញ្ជាក់បន្ថែម ] ។

បញ្ហាចំពោះសហគមន៍ដីក្រហម គឺត្រូវរកឱ្យឃើញថា តើអតីតអ្នកតំណាងសហគមន៍ ដែលបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន 7NG កាលពីថ្ងៃទី ១៣ ខែមករា ឆ្នាំ២០០៥ ក្នុងនាមសហគមន៍ បានទទួលការអនុញ្ញាតត្រឹមត្រូវអោយមានសិទ្ធិធ្វើដូច្នេះដែរឬទេ។ យោងតាមអ្នកតំណាងសហគមន៍ក្រោយពីបានចុះកិច្ចសន្យាថា សហគម៍មិនដែលត្រូវបានសាកសួរយោបល់អំពីកិច្ចសន្យា ឬ អំពីឆន្ទៈក្នុងការដោះដូរដីធ្លីដើម្បីជាថ្នូរចាកចេញទៅរស់នៅកន្លែងមួយនៅក្រៅទីក្រុងភ្នំពេញឡើយ។ ពួកគាត់ ក៏មិនបានយល់ព្រមចាកចេញពីកន្លែងបចុប្បន្នផងដែរ។

ជាភស្តុតាង ដែលសហគមន៍មិនយល់ព្រមលើការដោះដូរដីធ្លីនេះ មានឯកសារមួយ ចេញនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០០៥ ក្នុងឯកសារនោះ តំណាងសហគមន៍ដែលត្រូវបានតែងតាំងថ្មី បានជម្រាបឯកឧត្តមតំណាងរាស្ត្រ ហួ រ៉ាន់ អំពីលិខិតតវ៉ា ដែលពួកគាត់បានដាក់ជូននៅថ្ងៃទី ៧ ខែកុម្ភៈ។ លិខិតតវ៉ានោះធ្វើឡើងដោយប្រជាពលរដ្ឋចំនួន ៨០៤ គ្រួសារ។ ស្នាមមេដៃប្រជាពលរដ្ឋទាំងនោះមួយច្បាប់ត្រូវបានភ្ជាប់ជាមួយលិខិតតវ៉ាដែលបានដាក់ជូនសាលាក្រុងភ្នំពេញនិងលិខិតដែលបានផ្ញើជូនឯកឧត្តមហួ រ៉ាន់។ ហេតុការណ៍នោះគឺ សហគមន៍ធ្វើការតវ៉ាភ្លាមៗ បន្ទាប់ពីពួកគាត់បានទទួលដំណឹងអំពីកិច្ចសន្យាដោះដូរដីធ្លី ដែលនេះជាការបង្ហាញអោយឃើញ ថាពួកគាត់មិនមានឆន្ទៈក្នុងការធ្វើជាភាគីមួយនៃកិច្ចសន្យាបែបនេះឡើយ។

ប្រសិនបើ កិច្ចសន្យាពិតជាត្រូវបានចុះហត្ថលេខាដោយអតីតអ្នកតំណាង ដែលអ្នកភូមិមិនបានអនុញ្ញាតឱ្យធ្វើដូច្នេះមែន កិច្ចសន្យានោះត្រូវទុកជាមោឃៈយោងតាមលក្ខខណ្ឌទាំងឡាយនៃច្បាប់កិច្ចសន្យា ដូចដែលមានចែងក្នុងមាត្រា ៤ និងមាត្រា ៦។ មាត្រា ៤ ចែងថា" កិច្ចសន្យាទាំងឡាយណា ដែលមិនបានធ្វើតាមទំរង់ដែលច្បាប់បានកំណត់ ត្រូវទុកជាមោឃៈ" ចំណែកមាត្រា ៦ ចែងថា" កិច្ចសន្យាដូចតទៅត្រូវចាត់ទុកជាមោឃៈ នៅពេលដែល ក) កិច្ចសន្យានោះមិនកើតចេញ ពីការព្រមព្រៀងដោយពិតប្រាកដ ឬសេរី; ខ) កិច្ចសន្យានោះកើតចេញពីបុគ្គលគ្មានសមត្ថភាព ចុះកិច្ចសន្យា "។ លើសពីនេះទៀត មាត្រា ៧ ចែងថា "មិនអាចចាត់ទុកថា

មានការព្រមព្រៀងត្រឹមត្រូវទេ កាលណាការព្រមព្រៀងនោះ ធ្វើឡើងដោយការភ័ន្តច្រឡំ ដោយមានហិង្សា ឬ ដោយការបន្លំបោកប្រាស់"។

ជាចុងក្រោយ ដោយសារតែមានការគាបសង្កត់លើអ្នកភូមិនៅតំបន់ដីក្រហមឱ្យទទួលយកកិច្ចសន្យា និងប្រគល់ដីពួកគាត់ទៅឱ្យក្រុមហ៊ុន គេអាចលើកយកមាត្រា ៩ នៃច្បាប់កិច្ចសន្យា ដែលចែងថា "ហិង្សានឹងទៅជាមូលហេតុមោឃភាពនៃកិច្ចសន្យាបាន កាលណាហិង្សានោះជាការគំរាមកំហែង បង្ខិតបង្ខំតាមផ្លូវកាយ ឬ ផ្លូវចិត្តប្រព្រឹត្តទៅលើភាគីណាមួយ ប្តី ប្រពន្ធ បុព្វញាតិ ឬ បច្ឆាញាតិណាមួយរបស់ភាគីនោះ"។

ប្រសិនបើសហគមន៍ដីក្រហមមិនអាចត្រូវបានចាត់ទុកជាដីសម្បទានសង្គមកិច្ចដោយត្រឹមត្រូវទេ នោះមាត្រា ១៨ នៃអនុក្រិត្យស្តីពីសម្បទានដីសង្គមកិច្ច ក៏ទាក់ទងនិងការវិភាគផ្លូវច្បាប់ដែរ។ មាត្រានេះចែងថា "មុខសញ្ញាអ្នកទទួលដី មិនអាចលក់ ដូរ ជួល ឬ ធ្វើអំណោយដីសម្បទានសង្គមកិច្ចក្នុងរយៈពេល ៥ ឆ្នាំ ដំបូង នៃការអនុវត្តិកម្មវិធីសម្បទានដីសង្គមកិច្ចនេះទេ។ ប្រសិនបើមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ចណាខកខានមិនបានបំពេញតាមលក្ខខណ្ឌនៃការកាន់កាប់ និងប្រើប្រាស់ដីសម្បទាននោះ ដីនេះនឹងត្រូវវិលមកជាដីរបស់រដ្ឋវិញដើម្បីធ្វើការបែងចែកសាជាថ្មី[៤]"។ ហេតុដូច្នេះ អតីតអ្នកតំណាងសហគមន៍មិនត្រូវមានសិទ្ធិក្នុងការផ្ទេរដីតាមកិច្ចសន្យាជាមួយក្រុមហ៊ុន 7NG ឡើយ។

ចំពោះហេតុផលទាំងអស់នេះ វាកាន់តែច្បាស់ណាស់ថា តាមច្បាប់ កិច្ចសន្យារវាងក្រុមហ៊ុន 7NG និងអតីតអ្នកតំណាងសហគមន៍មិនត្រូវមានសុពលភាពឡើយ។

□ □ □

[៤] ច្បាប់ផ្លូវការជាភាសាខ្មែរ ចែងផងដែរថា ការដោះដូរដីធ្លី គឺជាអំពើខុសច្បាប់។

# ការគំរាមកំហែងលើសហគមន៍ដីក្រហមៈ សិទ្ធិលើទ្រព្យសម្បត្តិ ទល់នឹងឧបាយកលបង្ខិតបង្ខំ

ផ្នែកនេះគូសបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងដែលសហគមន៍ដីក្រហមធ្វើឡើង ដើម្បីតស៊ូដោយស្របច្បាប់ និងដោយសន្តិវិធីដើម្បីរក្សាឱ្យបាននូវសិទ្ធិលើទ្រព្យសម្បត្តិរបស់ពួកគាត់ និង យុទ្ធនាការដែលបានធ្វើឡើងដោយក្រុមហ៊ុន 7NG និងអាជ្ញាធរដើម្បីបង្ខិតបង្ខំពួកសហគមន៍ឱ្យបោះបង់ដីធ្លីរបស់ខ្លួន។

## ការបំភិតបំភ័យ ការរំខានយាយី និងការភ័យខ្លាច

អ្នកភូមិសហគមន៍ដីក្រហមបានដឹងអំពីកិច្ចសន្យាជាមួយក្រុមហ៊ុន 7NG ដែលអ្នកតំណាងរបស់ពួកគេបានចុះហត្ថលេខានៅឯកិច្ចប្រជុំមួយកាលពីថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០៥ រៀបចំឡើងដោយមន្ត្រីមូលដ្ឋាន ដោយមិនបានពិគ្រោះយោបល់ជាមួយសហគមន៍ឡើយ។ ពួកគាត់និយាយថា ខ្លួនត្រូវបានប្រាប់ថាកិច្ចសន្យានេះគឺធ្វើឡើងដោយស្ម័គ្រចិត្តទាំងស្រុង ដោយអ្នកភូមិអាចជ្រើសរើសដោយសេរី ថាតើទទួល ឬ មិនទទួលយកសំណើរបស់ក្រុមហ៊ុន 7NG ដើម្បីដោះដូរដីធ្លីរបស់ពួកគាត់នៅសហគមន៍ដីក្រហមជាថ្នូរនឹងផ្ទះល្វែងថ្មីនៅភូមិដំណាក់ត្រយឹង។ ប៉ុន្តែ ជាក់ស្តែងគឺ អ្នកភូមិពុំបានឃើញកិច្ចសន្យានោះឡើយដោយគេពុំបានផ្តល់ឱ្យ។

ក្នុងរយៈពេលជាច្រើនថ្ងៃក្រោយមកគេក៏ចាប់ផ្តើមផ្សព្វផ្សាយព័ត៌មានមួយផ្ទុយទៅវិញដល់ប្រជាពលរដ្ឋ។ អ្នកតំណាងសហគមន៍ បានផ្សព្វផ្សាយព័ត៌មានជាពាក្យសំដីថា អ្នកភូមិគួរតែចុះហត្ថលេខាទទួលយកសំណើក្រុមហ៊ុនឱ្យបានឆាប់ ពីព្រោះបើនៅរង់ចាំបង្អែរបង្អង់ ពួកគាត់នឹងពុំអាចទទួលបានអ្វីឡើយ។ អ្នកដែលមិនព្រមទទួលយកសំណើនេះ-ផ្ទះសម្បែងរបស់ខ្លួននឹងត្រូវបានដុតបំផ្លាញចោល ឬ តំបន់ដីក្រហមទាំងមូល នឹងត្រូវបានគេធ្វើរបងបិទជិត ហើយអ្នកភូមិនឹងមិនអាចធ្វើដំណើរចេញចូលផ្ទះសម្បែងរបស់ខ្លួនបានឡើយ។

ដោយមានការភ័យខ្លាច និងមានការសង្ស័យ អ្នកភូមិបានធ្វើការតវ៉ាជំទាស់នឹងអ្នកតំណាងរបស់ខ្លួនដែលបានចុះកិច្ចសន្យា ហើយពួកគាត់ក៏ជ្រើសរើសអ្នកតំណាងថ្មីតាមបែបប្រជាធិបតេយ្យនិងបានប្រកាសទាត់ចោលកិច្ចសន្យានេះតែម្តង។ អ្នកតំណាងដែលត្រូវបានជ្រើសតាំងថ្មី បានចាប់ផ្តើមប្រមូលអ្នកភូមិឱ្យផ្តិតមេដៃលើញត្តិតវ៉ាមួយ ដើម្បីបដិសេធកិច្ចសន្យាចោល ដែលជាសកម្មភាពមួយបង្កឱ្យមានការបំភិតបំភ័យភ្លាមៗពីសំណាក់អាជ្ញាធរមូលដ្ឋាន។ នៅចុងខែមករា និង ដើម ខែកុម្ភៈ អ្នកតំណាងជាច្រើននាក់ ត្រូវបានឃាត់ខ្លួនដោយសន្តិសុខភូមិ នៅពេលដែលពួកគាត់កំពុងដើរប្រមូលស្នាមមេដៃអ្នកភូមិ។ អ្នកតំណាងមួយរូបត្រូវបានដោះលែងវិញនៅពេលអ្នកភូមិ ដែលខឹងសម្បាជាង ១០០នាក់ បានមកឡោមព័ទ្ធការិយាល័យភូមិ ដើម្បីទាមទារឱ្យគាត់មានសេរីភាពវិញ។

ការភ័យខ្លាចរបស់អ្នកភូមិបានក្លាយជារឿងពិត នៅពេលដែលកិច្ចសន្យាមួយច្បាប់បានធ្លាក់ដល់ដៃអ្នកភូមិកាលពីថ្ងៃទី៤ ខែកុម្ភៈ។ យោងតាមពាក្យពេចន៍ក្នុងកិច្ចសន្យា ទើបអ្នកភូមិដឹងថាកិច្ចសន្យានេះគឺចងកាតព្វកិច្ចខាងផ្លូវច្បាប់ - ដែលមិនបានធ្វើឡើងដោយស្ម័គ្រចិត្តដូចគេប្រាប់ឡើយ។ ដោយដឹងដូច្នេះ មានអ្នកភូមិកាន់តែច្រើនឡើងមានឆន្ទៈផ្តិតមេដៃលើញត្តិតវ៉ាដើម្បីបដិសេធកិច្ចសន្យានេះ។ មកដល់ត្រឹមថ្ងៃទី ៧ ខែកុម្ភៈ មានអ្នកភូមិសរុបចំនួន ៨០៤គ្រួសារ បានផ្តិតមេដៃលើញត្តិ ហើយញត្តិនេះក៏ត្រូវបានបញ្ជូនទៅសាលាក្រុងភ្នំពេញ ដោយបានចម្លងជូនអាជ្ញាធរមូលដ្ឋានផងដែរ។

នៅថ្ងៃទី ២៥ ខែកុម្ភៈ អ្នកតំណាងសហគមន៍ទាំង ២៣ នាក់ ដែលត្រូវបានជ្រើសតាំងថ្មីៗ ត្រូវបានអាជ្ញាកោះហៅឱ្យចូលរួមកិច្ចប្រជុំមួយនៅសាលាខណ្ឌដើម្បីពិភាក្សាអំពីញត្តិនេះ។ អ្នកតំណាងសហគមន៍និយាយថា ដោយមិនបានលើកយកកង្វល់របស់ប្រជាពលរដ្ឋមកដោះស្រាយទេ មន្ត្រីនៅទីនោះបែរជាលើកឡើងថាស្នាមមេដៃទាំងនេះគឺជាស្នាមមេដៃក្លែងក្លាយទៅវិញ។ ពួកមន្ត្រីទាំងនោះបានប្រកាសថា គេនឹងធ្វើការស៊ើបអង្កេតហើយបើរកឃើញថា ជាស្នាមមេដៃមិនពិតប្រាកដនោះអ្នកតំណាងសហគមន៍ នឹងត្រូវ " ប្រឈមមុខនឹងច្បាប់ "។ នៅថ្ងៃបន្ទាប់អ្នកតំណាងសហគមន៍ បានឆ្លើយតបដោយបញ្ជូនញត្តិ និងលិខិតមួយច្បាប់ទៅតំណាងរាស្ត្រមណ្ឌលភ្នំពេញដើម្បីសុំឱ្យជួយអន្តរាគមន៍។



ស្ត្រីទ្រហោយំ ត្រូវបានបុគ្គលិកក្រុមហ៊ុន 7NG ធាក់
ឱ្យដួល និងដាក់ខ្នោះដៃ កាលពីខែសីហា ឆ្នាំ ២០០៧

អ្នកភូមិនិយាយថាជាងមួយខែក្រោយមកផែនការនៃការបំភិតបំភ័យមួយបែបពីសំណាក់មន្ត្រីមូលដ្ឋាននិងអតីតអ្នកតំណាងសហគមន៍ក៏លេចចេញជារូបរាងឡើងៈ អ្នកតំណាងម្នាក់ក្នុងចំណោមអ្នកតំណាងទាំងឡាយរបស់សហគមន៍ដែលទើបតែត្រូវបានតែងតាំងថ្មីត្រូវបានប្រធានភូមិកោះហៅដោយតម្រូវឱ្យគាត់ឈប់ដើរប្រមូលស្នាមមេដៃ ។ ផ្ទះរបស់អ្នកតំណាងម្នាក់ផ្សេងទៀតត្រូវបានគេដុត។ រីឯអ្នកតំណាងផ្សេងៗទៀតត្រូវបានគេជេរប្រមាថមាក់ងាយជាពាក្យសម្តីហើយទទួលរងការចោទប្រកាន់ដោយគ្មានការពិតពីនគរបាល។

គេរៀបចំឆាកល្ខោនសំរាប់យុទ្ធនាការបង្ខិតបង្ខំមួយ ប្រឆាំងនឹងអ្នកភូមិសហគមន៍ដីក្រហម - ហើយជាពិសេសប្រឆាំងនឹងអ្នកតំណាងថ្មីរបស់ពួកគេ ដែលយុទ្ធនាការនេះបានបន្តរហូតដល់សព្វថ្ងៃ។ នៅខែកក្កដា ឆ្នាំ ២០០៦ អ្នកតំណាងមួយរូបត្រូវបាន សន្តិសុខភូមិម្នាក់វាយដំយ៉ាងធ្ងន់ធ្ងរ ហើយអ្នកភូមិដទៃៗទៀត បានទទួលរងរបួសនៅក្នុងការប្រឈមមុខដោយហិង្សាជាមួយបុគ្គលិកក្រុមហ៊ុន 7NG ឬអាជ្ញាធរមូលដ្ឋាន។ នៅខែ សីហា ឆ្នាំ២០០៧ នគរបាល និង កងរាជអាវុធហត្ថបានអមដំណើរ ការពារកម្មករស៊ីឈ្នួលប្រដាប់ដោយពូថៅ និងដែកគាស់ដើម្បីព្យាយាមវាយកំទេចជម្រកនៅសហគមន៍ដីក្រហម។ អ្នកភូមិម្នាក់ ដែលធ្វើការទប់ទល់ដោយសន្តិវិធីត្រូវបានបុគ្គលិកក្រុមហ៊ុន និងកងរាជអាវុធហត្ថចាប់បោកឱ្យដួលហើយដាក់ខ្នោះដៃអស់រយៈពេលជាច្រើនម៉ោង។

រយៈពេលពាន្ឆាំហើយ ក្រុមហ៊ុន 7NG ដោយមានការសមគំនិតពីអាជ្ញាធរមូលដ្ឋានបានធ្វើយុទ្ធនាការរួមគ្នាមួយដើម្បីបញ្ចុះបញ្ចូលសហគមន៍ដីក្រហម - ម្តងមួយគ្រួសារៗ មួយផ្ទះម្តងៗ - ឱ្យបោះបង់ដីធ្លីរបស់ពួកគេ។ ការប្រឈមមុខនឹងការបំភិតបំភ័យនិងការយាយី រំខាន ការគំរាមចាប់ខ្លួន និងឃុំខ្លួនក្នុងពន្ធនាគារ សំរាប់បុរស ស្ត្រី និងកុមារនៅតំបន់ដីក្រហម បានក្លាយជាផ្នែកមួយនៃជីវភាពប្រចាំថ្ងៃរបស់ពួកគាត់កាន់តែខ្លាំងឡើងៗ។

## កិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ដីក្រហម

សហគមន៍ដីក្រហមបានប្រើគ្រប់មធ្យោបាយស្ទើរតែអស់លទ្ធភាពទៅហើយដើម្បីការពារដោយស្របច្បាប់និងដោយសន្តិវិធីនូវសិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួន។ ចាប់តាំងពីខែ កុម្ភៈ ឆ្នាំ ២០០៥ មកអ្នកតំណាងសហគមន៍បច្ចុប្បន្នរបស់ពួកគេ បានបញ្ជូនញត្តិតវ៉ា លិខិត និងពាក្យបណ្តឹងជាច្រើនទៅបុគ្គល និងទីភ្នាក់ងារជាច្រើន រួមទាំងនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី តំណាងរាស្ត្រ សាលាក្រុងភ្នំពេញ ការិយាល័យរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ព្រមទាំងតុលាការ។ ការអង្វរករសុំឱ្យជួយ និងសុំឱ្យមានការគោរពច្បាប់ភូមិបាល របស់ពួកសហគមន៏ មិនត្រូវបានមន្ត្រីនានាអើពើឡើយ។

ដោយមិនបានការពារសិទ្ធិរបស់អ្នកភូមិ អាជ្ញាធរបានបង្ហាញឱ្យឃើញនូវឆន្ទះជាអ្នកសមគំនិតជាមួយក្រុមហ៊ុន7NG ក្នុងការគាបសង្កត់អ្នកភូមិឱ្យបោះបង់ផ្ទះសម្បែងនៅសហគមន៍ដីក្រហម។ មន្ត្រីភូមិ សង្កាត់ និង មន្ត្រីខណ្ឌនានា បានជាប់ទាក់ទិនយ៉ាងធ្ងន់ធ្ងរក្នុងកិច្ចខិតខំប្រឹងប្រែងបំភិតបំភ័យអ្នកភូមិឱ្យចាកចេញពីតំបន់នេះ។ការិយាល័យរៀបចំដែនដីនគររូបនីយកម្មនិងសំណង់ ទោះបីបានទទួលពាក្យបណ្តឹងមួយច្បាប់ពីអ្នកភូមិ ដែលពន្យល់អំពីមូលហេតុមិនគួរចាត់ទុកកិច្ចសន្យាជាមួយក្រុមហ៊ុន 7NG ថាជាកិច្ចសន្យាស្របច្បាប់ក៏ដោយ ក៏ការិយាល័យនេះនៅតែចេញប័ណ្ណកម្មសិទ្ធិមួយយ៉ាងហោចណាស់ក៏សម្រាប់ទំហំដីមួយផ្នែកនៃតំបន់សហគមន៍ដីក្រហមនេះទៅឱ្យក្រុមហ៊ុន 7NG នៅខែធ្នូ ឆ្នាំ២០០៦ រួចហើយដែរ។

ព័ត៌មាននេះមិនត្រូវបានគេផ្សព្វផ្សាយឱ្យអ្នកភូមិដឹងឮទេ។ កិច្ចសន្យាជាមួយក្រុមហ៊ុន 7NG ជាច្រើនច្បាប់ មិនត្រូវបានផ្តល់ឱ្យ ពួកគាត់ឡើយ ប៉ុន្តែពួកនេះបានឱ្យមនុស្សម្នាក់ទំលាយព័ត៌មាននេះដល់ខ្លួន។ ពួកសហគមន៍អាចរកឃើញប័ណ្ណកម្មសិទ្ធិមួយច្បាប់ផងដែរ ដែលចេញឱ្យក្រុមហ៊ុន 7NG នៅឆ្នាំ២០០៦ សំរាប់ដីទំហំ ២ ហិកតានៅភូមិ២ ប៉ុន្តែវាមិនទាន់ច្បាស់នៅឡើយទេ ថាតើក្រុមហ៊ុននេះបានទទួលប័ណ្ណកម្មសិទ្ធិសំរាប់ទំហំដី ដែលនៅសល់ក្នុងសហគមន៍ដីក្រហមដែរឬទេ។ ក្រុមហ៊ុន 7NG បានអះអាងដដែល។ថា ខ្លួនមានប័ណ្ណកម្មសិទ្ធិសំរាប់ទំហំដីទាំងអស់។ មន្ត្រីទាំងនេះមិនបានផ្តល់ការពន្យល់ណាមួយអំពីមូលដ្ឋានផ្លូវច្បាប់ចំពោះការចេញប័ណ្ណកម្មសិទ្ធិឱ្យក្រុមហ៊ុន 7NG ឬអំពីមូលហេតុ ដែលចាត់ទុកកិច្ចសន្យាក្រុមហ៊ុនថាជាកិច្ចសន្យាមានសុពលភាពឡើយ។

ដោយពួកគេគ្មានជម្រើសផ្សេងទៀតយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រមួយចំនួនដែលអ្នកភូមិបានប្រើប្រាស់ប្រកបដោយជោគជ័យខ្លះ។នោះគឺត្រូវប្រមូលផ្តុំគ្នាដើម្បីធ្វើការតវ៉ាជាទ្រង់ទ្រាយធំ។ ពួកគេបានធ្វើដូច្នេះជាច្រើនលើកមកហើយក្នុងការទាមទារឱ្យមានការដោះលែងអ្នកភូមិ ដែលត្រូវបានឃាត់ខ្លួនដោយនគរបាល ឬ អាជ្ញាធរផ្សេង។ទៀត ហើយបានធ្វើដូច្នេះផងដែរកាលពីខែសីហា ឆ្នាំ២០០៧ ដើម្បីរារាំងកុំឱ្យនគរបាល និងកម្មករសំណង់ស៊ីឈ្នួលរុះរើខ្ទមនៅដំបន់ដីក្រហមនេះ។

ប៉ុន្តែយុទ្ធសាស្ត្រនេះបានធ្វើឱ្យអ្នកភូមិនិងអ្នកតំណាងរបស់ពួកខ្លួនទទួលរងការចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ប្រសិនបើការតវ៉ារបស់ពួកគេក្លាយជាហិង្សានោះ។ ដើម្បីព្យាយាមកាត់បន្ថយការប្រឈមនឹងគ្រោះថ្នាក់នេះអ្នកតំណាងសហគមន៍បានទទួលការបណ្តុះបណ្តាលអំពីការទប់ទល់ដោយសន្តិវិធី និងអហិង្សាពីអង្គការមិនមែនរដ្ឋាភិបាលផ្សេង។ បន្ទាប់ពីមានការប្រឈមមុខដាក់គ្នានៅខែសីហា ឆ្នាំ២០០៧ ជាមួយនគរបាល និងកម្មករសំណង់កន្លងមក។ តាមបទពិសោធន៍ ដែលអ្នកតំណាងសហគមន៍បានឆ្លងកាត់កន្លងមកពួកគេនៅតែអាចប្រឈមមុខនឹងការចោទប្រកាន់បទព្រហ្មទណ្ឌ ដោយគ្មានមូលហេតុត្រឹមត្រូវទោះបីជាពួកគាត់មិនបានប្រព្រឹត្តអំពើល្មើសខាងព្រហ្មទណ្ឌនោះក៏ដោយ។

## ការសមគំនិតរបស់តុលាការ

តុលាការក្រុងភ្នំពេញបានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីកង្វះគ្មានឯករាជ្យភាព និង គ្មានអនាគតិក្នុងការចាត់ការលើពាក្យបណ្តឹងទាំងឡាយដែលត្រូវបានប្តឹងជំទាស់នឹងអ្នកភូមិសហគមន៍ដីក្រហមនេះ។ ខណៈដែលតុលាការមិនបានអើពើនឹងបណ្តឹងរបស់អ្នកភូមិ ដើម្បីការពារសិទ្ធិលើទ្រព្យសម្បត្តិរបស់ពួកគាត់ តុលាការបែរជាទទួលបណ្តឹងដោយចេតនាពីក្រុមហ៊ុន 7NG ឬ បណ្តឹងពីអាជ្ញាធរ ដែលប្តឹងជំទាស់ពួកសហគមន៍នេះទៅវិញ។

នៅឆ្នាំ២០០៦ និង ២០០៧ តុលាការមិនបានចាត់ការបណ្តឹងទាំងឡាយដែលសហគមន៍បានប្តឹងក្រុមហ៊ុន 7NG ឬ អតីតអ្នកតំណាងសហគមន៍ដែលបានចុះកិច្ចសន្យាជាមួយនិងក្រុមហ៊ុនឡើយ ។ ហេតុដូច្នេះហើយបញ្ហាសំខាន់ទាក់ទងនឹងអ្នកណាជាកម្ម-

សិទ្ធិករលើដីសហគមន៍ - និងថាតើកិច្ចសន្យានេះស្របច្បាប់ដែរ ឬទេនោះ - មិនត្រូវបានតុលាការសម្រេចទេ។ ទោះបីយ៉ាងណាក៏ដោយតុលាការបានចាត់ការម្តងហើយម្តងទៀត តែលើបណ្តឹងប្តឹងអ្នកភូមិហើយធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌភ្លាមៗ ដែលជាធម្មតាគ្មានភស្តុតាងសូម្បីតែមួយចំណិតតូចដាក់បន្ទុកលើពួកគាត់ ក៏គ្មានដែរ។ នៅពេលកំពុងសរសេរឯកសារនេះអ្នកភូមិចំនួនសរុប ១៤នាក់ រាប់ទាំងអ្នកតំណាងសហគមន៍៧នាក់ផង - ត្រូវបានតុលាការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌផ្សេងៗគ្នា។ អ្នកតំណាងម្នាក់ក្នុងចំណោមអ្នកតំណាងទាំងឡាយ ឈ្មោះ រស់ ពៅ កំពុងត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារព្រៃស ពីបទបង្ករបួសស្នាមលើកម្មករក្រុមហ៊ុនច្រើននាក់កំឡុងពេលប្រឈមមុខដាក់គ្នាមួយ ។អ្នកភូមិផ្សេងទៀតត្រូវបានអនុញ្ញាតឱ្យនៅក្រៅឃុំរង់ចាំសវនាការ ។

មានបែបផែនយ៉ាងច្បាស់លាស់មួយនៃបណ្តឹងមិនត្រឹមត្រូវពីបទព្រហ្មទណ្ឌដែលធ្វើឡើងដោយក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋាន ប្តឹងសមាជិកសហគមន៍ក្នុងការប៉ុនប៉ង ដើម្បីផ្តល់ឱ្យពួកគេនូវជម្រើសមួយដែលមិនអាចគេចផុតបាន - គឺត្រូវតែបោះបង់ផ្ទះសម្បែងរបស់អ្នក ឬក៏ត្រូវទៅពន្ធនាគារ។ នេះគឺជាវិធីដ៏ជោគជ័យរបស់ក្រុមហ៊ុន 7NG: អ្នកមួយចំនួន ដែលត្រូវបានចោទប្រកាន់បានយល់ព្រមលក់ផ្ទះសម្បែងរបស់ខ្លួនភ្លាមៗទៅឱ្យក្រុមហ៊ុន ហើយអ្នកតំណាងសហគមន៍ ដែលទទួលរងការចោទប្រកាន់ស្ទើរតែទាំងអស់បានរត់គេច ដើម្បីលាក់ខ្លួនដោយភ័យខ្លាចគេចាប់ខ្លួននៅពេលណាមួយ (ហេតុដូច្នេះហើយគ្មាន គោលជំហរនឹងបន្តធ្វើសកម្មភាព ដើម្បីរៀបចំសហគមន៍តទៅទៀតឡើយ)។

ករណីជាច្រើនបង្ហាញជាឧទាហរណ៍គួរឱ្យអស់សំណើច ចំពោះការចោទប្រកាន់ខាងព្រហ្មទណ្ឌខ្លះៗ ដែលបានធ្វើឡើងជំទាស់នឹងអ្នកតំណាងសហគមន៍ ព្រមទាំងវិធីដែលក្រុមហ៊ុន 7NG បានរិះរក ដើម្បីបង្កហេតុ ឱ្យអ្នកភូមិប្រព្រឹត្ត "បទល្មើសព្រហ្មទណ្ឌ":

- នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ អ្នកតំណាងសហគមន៍បានរៀបចំធ្វើសន្និសិទកាសែតមួយនៅសហគមន៍ដីក្រហម។ នៅពេលនោះ សន្តិសុខក្រុមហ៊ុន 7NG ម្នាក់បានព្យាយាមថតរូបអ្នកតំណាងសហគមន៍ជាស្ត្រីម្នាក់ ដោយប្រើទូរស័ព្ទដៃរបស់គាត់ហើយអ្នកតំណាងជាស្ត្រីរូបនោះបានព្យាយាមរារាំងមិនឱ្យថតដោយគ្រវែងដៃគាត់ចេញ។ សន្តិសុខនោះក៏ធ្លាក់ទូរស័ព្ទ ទៅដី ហើយគាត់មិនបានរើសទូរស័ព្ទពីដីវិញទេ-បែរជារត់ទៅកាន់ប៉ុស្តិ៍នគរបាលប្តឹងថា ស្ត្រីនេះបានលួចទូរស័ព្ទដៃខ្លួនទៅវិញ។ សមាជិកសហគមន៍បានយកទូរស័ព្ទទៅប្រគល់ឱ្យនគរបាល។ មួយសប្តាហ៍ក្រោយមក តុលាការក្រុងភ្នំពេញផ្អែកលើពាក្យ បណ្តឹងមួយច្បាប់របស់ក្រុមហ៊ុន 7NG បានធ្វើការចោទប្រកាន់អ្នកតំណាងស្ត្រីនោះពីបទឧក្រិដ្ឋប្លន់ - ដូចនេះស្ត្រីនោះនឹង ត្រូវប្រឈមការជាប់ពន្ធនាគាររហូតដល់ ១០ឆ្នាំ ប្រសិនបើ តុលាការផ្តន្ទាទោសគាត់។
- នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ ម៉ោងប្រហែល ៨:០០ យប់ បុគ្គលិកក្រុមហ៊ុន 7NG បានប៉ុនប៉ងនាំយកគ្រឿងចក្រមួយគ្រឿងសំរាប់ជីកដី ចូលទៅក្នុងដំបន់ដីក្រហមបណ្តាលឱ្យមានប្រតិកម្មខឹងសម្បាពីអ្នកភូមិដោយភ័យខ្លាចថាគ្រឿងចក្រនោះនឹងត្រូវបានប្រើប្រាស់ដើម្បីកំទេចផ្ទះសម្បែងរបស់ពួកគេ។ អ្នកភូមិមួយហ្វូងបានស្នើសុំបុគ្គលិកក្រុមហ៊ុន 7NG កុំឱ្យបើកបរគ្រឿងចក្រចូលទៅក្នុងសហគមន៍ពួកគេនៅពេលយប់ប៉ុន្តែសំណើនេះមិនត្រូវបានអើពើឡើយ។ បុគ្គលិកក្រុម

ហ៊ុននៅក្នុងកាប៊ីនគ្រឿងចក្រ ចាប់ផ្តើមបញ្ជាប្រដាប់ជីក តម្រង់ទៅហ្វូងមនុស្ស ដែលជាអំពើគ្រោះថ្នាក់មួយ អាចបង្កឱ្យមានរបួសស្នាម។ ផ្តើមចេញពីចំណុចនេះអ្នកភូមិខ្លះ ដែលភាគច្រើនជាកុមារបានចោលដុំថ្មទៅលើគ្រឿងចក្រ បណ្តាលឱ្យបែកកញ្ចក់បង្អួច ហើយវាយទៅលើកម្មករក្រុមហ៊ុនចំក្បាល។ ហ្វូងមនុស្សក៏ស្ងប់ស្ងាត់ទៅវិញ ដោយសារអ្នកតំណាងសហគមន៍បានអំពាវនាវដល់ពួកនោះតាមឧឃោសនស័ព្ទកុំឱ្យប្រើហិង្សា។ បួនថ្ងៃក្រោយមក អ្នកតំណាងដដែលចំនួន ៣នាក់ត្រូវបានតុលាការចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងបង្ករបួសស្នាមបន្ទាប់ពីមានពាក្យបណ្តឹងមួយច្បាប់របស់ក្រុមហ៊ុន 7NG ប្តឹងទៅតុលាការ។

ក្នុងករណីទាំងនេះនិងករណីដទៃ១ទៀត តុលាការបានទទួលពាក្យបណ្តឹងរបស់ក្រុមហ៊ុន - ដោយគ្មានភស្តុតាងណាមួយដែលអាចដាក់បន្ទុកជនជាប់ចោទបានឡើយ ហើយក៏ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌតែម្តង។ ជាការផ្ទុយនឹងច្បាប់ តុលាការពុំមាន គោលបំណងធ្វើការសាកសួរជនសង្ស័យឬសាក្សីឡើយ ដើម្បីទទួលការបកស្រាយពន្យល់របស់ពួកគាត់អំពីព្រឹត្តិការណ៍ដែលបានកើតឡើងមុនពេលសំរេចចោទប្រកាន់។ ដោយរំលោភបំពានទៅលើគោលការណ៍សន្មត់ជាមុនថាគ្មានទោស តុលាការបានចាត់ទុកគោលការណ៍នេះជាសារវន្តទៅឱ្យជនជាប់ចោទ ជាអ្នកបង្ហាញភស្តុតាងថាខ្លួនគ្មានពិរុទ្ធ។

## ទីតាំងលំនៅដ្ឋានថ្មី និងការទូទាត់សំណង

ចាប់តាំងពីខែសីហាឆ្នាំ២០០៦ ប្រជាពលរដ្ឋរាប់រយគ្រួសារ បានបោះបង់ដីធ្លីរបស់ពួកគាត់នៅដំបន់ដីក្រហមជាថ្នូរនឹងការទទួលយកផ្ទះល្វែងនៅទីតាំងលំនៅដ្ឋានថ្មីនៅភូមិដំណាក់ត្រយឹង ឬ ជាថ្នូរនឹងការទទួលយកប្រាក់សុទ្ធដែលក្រុមហ៊ុន 7NG ផ្តល់ឱ្យ។ ខណៈដែលក្រុមហ៊ុនអះអាងថា អ្នកភូមិទាំងអស់បានយល់ព្រមធ្វើដូច្នេះដោយស្ម័គ្រចិត្តនោះ បែបផែននៃការបំភិតបំភ័យទៅលើអ្នកស្រុកបានកើតឡើង ប៉ុន្តែអាចទំនងជាមានពួកសហគមន៍មួយចំនួនបានយល់ព្រមដូច្នេះមែនដោយសារការបង្ខិតបង្ខំ។

ក្រុមហ៊ុននិយាយថា ខ្លួនបានសាងសង់ផ្ទះល្វែងចំនួន ១.៧០០ ល្វែងនៅទីតាំងលំនៅដ្ឋានថ្មីក្នុងភូមិដំណាក់ត្រយឹង ហើយថាខ្លួនបានសាងសង់រោងចក្រមួយ(ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន)ដើម្បីផ្តល់ការងារដល់អ្នកភូមិដែលចូលទៅរស់នៅទីនោះ មានឱកាសទទួលបានការងារមួយចំនួនទៀត នៅក្នុងតំបន់នោះ ដែលមានចម្ងាយជាង ២០ គីឡូម៉ែត្រពីសហគមន៍ដីក្រហម។

បញ្ហាមួយ ទំនងជាក្រុមហ៊ុន 7NG មិនបានបំពេញរាល់កាតព្វកិច្ចរបស់ខ្លួននៅទីតាំងលំនៅដ្ឋានថ្មីតាមកិច្ចសន្យាដើមដែលអតីតអ្នកតំណាងសហគមន៍បានចុះហត្ថលេខាជាមួយខ្លួន។ កិច្ចសន្យានោះចែងយ៉ាងជាក់លាក់ថា ផ្ទះល្វែងទាំងអស់ត្រូវមានបង្គន់អនាម័យមួយ បន្ទប់ទឹកមួយ ហើយថាក្រុមហ៊ុនត្រូវភ្ជាប់ប្រពន្ធ័ទឹក និងភ្លើងឱ្យអោយរួចជាស្រេច។

ជម្រើសមួយផ្សេងទៀត ដែលក្រុមហ៊ុនដាក់សំណើទៅអ្នកភូមិដំបន់ដីក្រហមនោះ គឺថាក្រុមហ៊ុននឹងទិញផ្ទះសម្បែងរបស់ពួកគេ។ តម្លៃទិញផ្ទះដែលក្រុមហ៊ុន 7NG កំណត់ទំនងជាខុសៗគ្នា ប៉ុន្មានឆ្នាំកន្លងមកនេះ ដោយអាស្រ័យទៅលើពេលវេលានិងភាពងាយទទួលរងគ្រោះរបស់គ្រួសារនីមួយៗផងដែរ។ ទោះបីជាបែបនេះក្តី តម្លៃដែលគេហ៊ានទិញប្រហែល ២៣៤ ដុល្លារអាមេរិក ក្នុង១ម៉ែត្រក្រឡាទំនងជាអត្រាខ្ពស់បំផុត ដែលត្រូវបានដឹងនៅពេលថ្មីៗនេះ។ តម្លៃនេះទាបជាងតម្លៃទីផ្សារយ៉ាងខ្លាំង ចំពោះដីដ៏មានតម្លៃនៅតំបន់ទន្លេបាសាក់នេះ។

សំណើរបស់ក្រុមហ៊ុន - ក្នុងការផ្តល់ផ្ទះល្វែងថ្មីមួយ ឬការទូទាត់ជាប្រាក់សុទ្ធ - អនុវត្តចំពោះអ្នកដែលមានផ្ទះនៅដំបន់ដីក្រហម។ តាមអ្នកតំណាងសហគមន៍បច្ចុប្បន្នបានឱ្យដឹងថា អ្នកជួលផ្ទះខ្លះបានសូកប៉ាន់អតីតអ្នកតំណាងសហគមន៍ឱ្យបញ្ចូលឈ្មោះគ្រួសាររបស់ពួកគេ ទៅក្នុងបញ្ជីឈ្មោះអ្នកដែលមានផ្ទះ ហើយក៏ត្រូវបានគេផ្តល់ឱ្យនូវផ្ទះល្វែងដូចគេឯងនៅភូមដំណាក់ត្រយឹង។ កិច្ចសន្យាក្រុមហ៊ុន 7NG មិនមានចែងឱ្យបានជាក់លាក់ថា ក្រុមហ៊ុននឹងដោះស្រាយអ្នកជួលផ្ទះទេ ប៉ុន្តែកិច្ចសន្យានេះពិតជាបានចែងថា ផ្ទះល្វែងត្រូវចែកជូន ដល់ប្រជាពលរដ្ឋទាំងអស់ចំនួន "១.៤៦៥ គ្រួសារ"នៅដំបន់ដីក្រហម ជាតួលេខមួយ (ដែលត្រូវបានបំប៉ោង) ដោយពិតជាបានរាប់បញ្ចូលទាំងអ្នកជួលផ្ទះ យោងតាមឯកសារផ្សេងៗទៀតដែលត្រូវបានធ្វើឡើងដោយអាជ្ញាធរមូលដ្ឋាន។ អ្នកតំណាងសហគមន៍បច្ចុប្បន្ន នៅតែប្រកាន់ជំហរយ៉ាងម៉ឺងម៉ាត់ថា ពួកអ្នកជួលផ្ទះ គួរទទួលបានសំណងពីក្រុមហ៊ុន 7NG ដែរ។

## ស្ថានភាពបច្ចុប្បន្ន

មកដល់ត្រឹមខែធ្នូ ឆ្នាំ ២០០៧ យោងតាមអ្នកតំណាងសហគមន៍បច្ចុប្បន្នបានឱ្យដឹងថា មានអ្នកភូមិប្រមាណចំនួន២៨០គ្រួសារ នៅតែបន្តរស់នៅក្នុងដំបន់សហគមន៍ដីក្រហម ហើយប្រហែល ២០០គ្រួសារក្នុងចំណោមនោះជាអ្នកមានផ្ទះ និងក្រៅពីនេះគឺជាអ្នកជួលផ្ទះរយៈពេលយូរ។ នៅចុងខែសីហា ឆ្នាំ២០០៧ ស្រី សុធា ជាទីប្រឹក្សាក្រុមហ៊ុន 7NG ទទួចថាមានប្រជាពលរដ្ឋចំនួនតែ ១៧៩ គ្រួសារទេដែល "បន្តរស់នៅដោយស្របច្បាប់លើដំបន់ដីក្រហម[៥]"។ នៅក្នុងកិច្ចប្រជុំមួយជាមួយនិងអ្នកភូមិកាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៧ តាមសេចក្តីរាយការណ៍ មន្ត្រីសាលាក្រុងភ្នំពេញ បាននិយាយថា ពួកគេទទួលស្គាល់ថា ប្រជាពលរដ្ឋសេសសល់ចំនួន ១៩០គ្រួសារ មានសិទ្ធិកម្មសិទ្ធិលើដីធ្លីរបស់ខ្លួន។

ជំហររបស់ក្រុមហ៊ុននិងសាលាក្រុងចំពោះអ្នកភូមិនៅសេសសល់និងសិទ្ធិលើកម្មសិទ្ធិរបស់ពួកគេមិនស្របគ្នានិងមិនសមតាមតក្កវិជ្ជាទេ ។ ទន្ទឹមនឹងនេះ នៅពេលដែលពួកគាត់បានធ្វើសេចក្តីថ្លែងការទទួលស្គាល់ថាអ្នកភូមិខ្លះមានសិទ្ធិសុពលភាពលើកម្មសិទ្ធិពួកគេក៏បានថ្លែងផងដែរថាអ្នកភូមិត្រូវតែចាកចេញ។ជាតួយ៉ាងប៉ុន្មានថ្ងៃក្រោយពីបានថ្លែងថា អ្នកភូមិចំនួន ១៧៩គ្រួសារ បានរស់នៅស្របច្បាប់ក្នុង

[៥] ដកស្រង់ចេញពីកាសែត ឌឹ ឃាមបូឌាដេលី ចេញផ្សាយថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧

[៥] សូមមើលឧបសម្ព័ន្ធទី២៥ សំរាប់គម្រោងសាងសង់នៃផែនការអភិវឌ្ឍន៍នៅទីងកន្លែងសហគមទីដីក្រហម

ដំបន់ដីក្រហមនេះ ស្រី សុធា ត្រូវបានគេដកស្រង់សំដីដោយនិយាយថា មានអ្នកភូមិដីក្រហមចំនួន ៨៧ភាគរយបានស្ម័គ្រចិត្តចាកចេញហើយឥឡូវនេះយើងនឹងទុកឱ្យសាលាក្រុងបណ្តេញអ្នកដែលនៅសេសសល់ចេញពីព្រោះយើងបានចំណាយពេលជាច្រើនណាស់ទៅហើយក្នុងការចរចាជាមួយពួលគេ "។ ស្រដៀងគ្នានេះដែរ អ្នកភូមិនិយាយថា នៅកិច្ចប្រជុំកាលពីថ្ងៃទី២០ ខែកញ្ញា មន្ត្រីសាលាក្រុងបានទទួលស្គាល់ថា អ្នកភូមិចំនួន១៩០គ្រួសារមានសិទ្ធិលើកម្មសិទ្ធិ ប៉ុន្តែបដិសេធសំណើរបស់ពួកគេសុំឱ្យមានដំណោះស្រាយមួយដែលនឹងអនុញ្ញាតឱ្យពួកគេបន្តរស់នៅដំបន់ដីក្រហមតទៅទៀត។

បណ្តឹងស្របច្បាប់មួយដែលអ្នកភូមិសហគមន៍ដីក្រហមបានប្តឹងក្នុងគោលបំណងទាមទារសិទ្ធិលើកម្មសិទ្ធិរបស់ពួកគេ កំពុងស្ថិតនៅចំពោះ មុខតុលាការក្រុងភ្នំពេញនៅឡើយ។ ដោយសារតែមានបញ្ហាក្នុងការធានាឱ្យមានតំណាងផ្លូវច្បាប់គ្រប់គ្រាន់អង្គការមិនមែនរដ្ឋាភិបាលមួយកាលពីខែកញ្ញាឆ្នាំ ២០០៧ ក៏យល់ព្រមផ្តល់ថវិកាសំរាប់ជួលមេធាវីឯកជនម្នាក់ដើម្បីតំណាងឱ្យគ្រួសារនៅសេសសល់ក្នុងករណីនេះ។

ក្នុងគោលបំណងស្វែងរកដំណោះស្រាយមួយចំពោះរឿងវិវាទដែលកំពុងតែបន្ត អ្នកភូមិដីក្រហម បានសម្តែងចេញនូវឆន្ទៈរបស់ពួកគេចង់បែងចែកដីធ្លីនៅដំបន់ដីក្រហមនេះ ជាមួយក្រុមហ៊ុន 7NG ។ ដោយមានជំនួយពីវិស្វករជាច្រើនរូប អ្នកតំណាងសហគមន៍បានបង្កើតផែនការអភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែង ស្រដៀងគ្នាទៅនឹងផែនការ ដែលត្រូវបានដាក់ និងបង្ហាញជូនដោយអ្នកភូមិក្រុម៧៨ កាលពីខែឧសភា ឆ្នាំ២០០៧។ ផែនការនេះ ត្រូវបានបង្ហាញនៅសន្និសិទសារពត៌មានមួយកាលពីខែកញ្ញា ឆ្នាំ២០០៧ ប៉ុន្តែសហគមន៍ត្រូវតែធ្វើការវាយតម្លៃថវិកាសំរាប់គំរោងនេះ។

ផែនការអភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែង ធ្វើការព្យាករណ៍ទុកជាមុនចំពោះអ្នកភូមិដែលចូលទៅរស់នៅក្នុងអគារផ្ទះល្វែងថ្មីកំពស់៣ជាន់ នៅដំបន់សហគមន៍ដីក្រហមជាមួយ គ្រួសារដែលរស់នៅជាន់ទី២និងជាន់ទី៣ដោយប្រើប្រាស់ទីធ្លាលក់ដូរទំនិញនៅជាន់ផ្ទាល់ដីរួមគ្នា ដោយធានាឱ្យមានការងារជានិរន្តសំរាប់ពួកគេ។

ផែនការនេះបែងចែកដីទំហំ១,៥ហិកតាទៅឱ្យក្រុមហ៊ុន 7NG សំរាប់ធ្វើការអភិវឌ្ឍន៍ពាណិជ្ជកម្ម-ដីទំហំកន្លះហិកតាធំជាងដីឱ្យក្រុមហ៊ុន 7NG ត្រូវបានផ្តល់ក្រោមផែនការ អភិវឌ្ឍន៍របស់រដ្ឋាភិបាល។ អ្នកតំណាងសហគមន៍ ដែលបានបង្កើតផែនការនេះឡើងនិយាយថាទោះបីជាពួកគេជឿថាក្រុមហ៊ុន 7NG ពុំមានសិទ្ធិស្របច្បាប់លើដីធ្លីនេះ ក៏ដោយក៏ពួកគេមានបំណងចង់ធ្វើការ សំរុះសម្រួលគ្នាដើម្បីដោះស្រាយវិវាទដីធ្លីបច្ចុប្បន្ននេះដែរ។ ក្រុមហ៊ុន 7NG និងសាលាក្រុងបានបដិសេធមិនព្រមទទួលស្គាល់ឬអនុម័ត ផែនការរបស់ពួកសហគមន៍ឡើយ។

ដើម្បីលើកមកសង្ខេបនូវអង្គហេតុដែលថាសំណើរបស់ពួកគេ ស្របតាមគោលបំណងដំបូងរបស់រដ្ឋាភិបាលសំរាប់ដីសម្បទាន សង្គមកិច្ច នៅដំបន់ដីក្រហមអ្នកតំណាងសហគមន៍ បានបោះពុម្ពបដាធំៗមួយចំនួន ដែលបង្ហាញអំពីប្លង់មួយស្នើសាងសងអគារផ្ទះល្វែងអមដោយ



រូបថតលោកនាយករដ្ឋមន្ត្រីហ៊ុនសែន២ផ្ទាំង ។ផ្ទាំងរូបថតមួយក្នុងចំណោមផ្ទាំងរូបថតទាំងនេះគឺជាការផ្សព្វផ្សាយដែលផលិតដោយរដ្ឋាភិបាលស្តីអំពីការប្តេជ្ញាចិត្តរបស់លោកនាយករដ្ឋមន្ត្រីហ៊ុនសែនចំពោះ សមាគមន៏ក្រីក្រចេញផ្សាយដំណាលគ្នានឹងពេល ដែលលោកនាយករដ្ឋមន្ត្រីហ៊ុនសែនបានដាក់បញ្ចូលសហគមន៏ដីក្រហមទៅក្នុងផែនការអភិវឌ្ឍន៏របស់រដ្ឋាភិបាលសំរាប់អ្នកក្រីក្រក្នុងឆ្នាំ២០០៣។

□ □ □

# កាលប្បវត្តិនៃព្រឹត្តិការណ៍*

## ឆ្នាំ ២០០៣-២០០៤

ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៣ - ក្រោយពីមានការប្រកាសជាសាធារណៈមួយដោយនាយករដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រីបានចេញលិខិតលេខ៨៧៥ ដែលគេដឹងថាជាផែនការអភិវឌ្ឍន៍ ដើម្បីអនុម័តបង្កើត"សម្បទានដីសង្គមកិច្ចសំរាប់សហគមន៍ក្រីក្រ" ៤កន្លែងនៅទីក្រុងភ្នំពេញ។ លិខិតនោះកំណត់ថា សហគមន៍ដីក្រហមដែលមានអ្នកភូមិចំនួន ១.៤៦៥គ្រួសារ និងមនុស្សសរុបចំនួន ៥.៨៥៤នាក់ នឹងត្រូវទទួលបានដីសម្បទានសង្គមកិច្ច "សំរាប់ធ្វើការអភិវឌ្ឍន៍លំនៅដ្ឋាន" លើទំហំដី ៣,៧ ហិកតានៃផ្ទៃដីសរុបចំនួន ៤,៧ហិកតានៅដំបន់សហគមន៍ ដីក្រហម។

**ឯកសារយោង: ឧបសម្ព័ន្ធទី១**

ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤ - អភិបាលខណ្ឌចំការមន ផ្ញើរបាយការណ៍លេខ ៣.៧០០៥ ទៅសាលាក្រុងភ្នំពេញ។ របាយការណ៍នេះបង្ហាញថា ការសិក្សាទៅលើដំបន់ដីក្រហម បានកំណត់ថាមានអ្នកភូមិចំនួន ១.៤៦៥ គ្រួសារ ដោយមានមនុស្សចំនួន ៥.៧៥០ នាក់កំពុងរស់នៅទីនោះ។ (យោងតាមអ្នកតំណាងសហគមន៍ ក្រោយពីមានការចុះកិច្ចសន្យា ចំនួនគ្រួសារជាក់ស្តែងនៅពេលនោះគឺមានប្រហែល ៨០០គ្រួសារ)។ របាយការណ៍នេះនិយាយផងដែរថាការវាស់វែងដីដែលធ្វើឡើងដោយការិយាល័យរៀបចំដែនដីនគរូបនីយកម្មនិងសំណង់បានរកឃើញថា ដំបន់ដីក្រហមមានទំហំដីសរុប ៣,៦ហិកតា - តិចជាងការប៉ាន់ស្មាន នៅក្នុងការធ្វើសម្បទានដីសង្គមកិច្ច ១,១ ហិកតា ដែលបានអនុញ្ញាតដោយគណៈរដ្ឋមន្ត្រី។ របាយការណ៍នេះនិយាយថា នៅពេលធ្វើសេចក្តីរាយការណ៍ ជូនអភិបាលក្រុងអំពីលទ្ធផលនេះ លោកអភិបាលក្រុងបានថ្លែងប្រាប់ថា ដីទាំងអស់នៅដំបន់ដីក្រហមនឹងត្រូវផ្តល់ជូនសហគមន៍ ដីក្រហម ដោយមិនដកហូតចំណែកណាមួយនៃដីពីពួកគាត់ឡើយ។

របាយការណ៍នេះនិយាយផងដែរថា សហគមន៍ដីក្រហម (ដោយយោងតាមអតីតអ្នកតំណាងសហគមន៍មុនពេលចុះកិច្ចសន្យា) បានមកទំនាក់ទំនងក្រុមហ៊ុនឯកជនជាច្រើន តែគ្មានជោគជ័យ ដើម្បីលើកសំណើអំពីកិច្ចព្រមព្រៀងមួយ ក្នុងការបែងចែកដីធ្លី ៥០/៥០ម្នាក់: ក្រុមហ៊ុននឹងទទួលបានដីទំហំ១,៨ហិកតាពីដីទំហំ៣,៦ហិកតានៅដំបន់ដីក្រហមសំរាប់ការអភិវឌ្ឍន៍ពាណិជ្ជកម្ម ប្រសិន

* កំណត់សំគាល់: ១)កាលប្បវត្តិនេះ គឺផ្អែកទៅលើឯកសារនានាដែលទទួលបានតាមលទ្ធភាពដែលអាចធ្វើទៅបាន (ហើយដែលមាននៅក្នុងឧបសម្ព័ន្ធនៃរបាយការណ៍នេះ) ប៉ុន្តែក្នុងករណីខ្លះ ឯកសារពាក់ព័ន្ធមួយចំនួនមិនអាចរកបានទេ។ ២)នៅក្នុងកាលប្បវត្តិនេះ អ្នកតំណាងសហគមន៍មុនពេលចុះកិច្ចសន្យាកាលពីខែមករា ឆ្នាំ ២០០៥ ជាមួយក្រុមហ៊ុន 7NG ហៅថា "អ្នកតំណាងមុនពេលចុះកិច្ចសន្យា" រីឯអ្នកតំណាងសហគមន៍បច្ចុប្បន្នហៅថា "អ្នកតំណាងក្រោយពេលចុះកិច្ចសន្យា"។

បើក្រុមហ៊ុន សាងសង់ផ្ទះល្វែងជូនអ្នកភូមិលើដីសេសសល់ទំហំ១,៨ហិកតា ។បន្ទាប់មកសហគមន៍បានចាប់ផ្តើមពិភាក្សាជាមួយក្រុមហ៊ុនមួយស្តីអំពីការដោះ ដូរដីធ្លីទាំងអស់វិញ:ក្រុមហ៊ុនអាចទទួលបានដីទាំងអស់ទំហំ៣,៦ហិកតានៅដីបន់ដីក្រហមជាថ្នូរនិងការទទួលបានផ្ទះល្វែងសំរាប់អ្នកភូមិដែលត្រូវសាងសង់នៅសង្កាត់ចោមចៅនៃក្រុងភ្នំពេញ។ (របាយការណ៍មិនបានបញ្ជាក់ថាតើអ្នកភូមិដីក្រហមបានផ្តល់ការអនុញ្ញាតឱ្យ អ្នកតំណាងសហគមន៍ ដើម្បីប្រកាន់យកផ្លូវចរចានេះតទៅទៀត ឬយ៉ាងណាទេ)។

## ឆ្នាំ ២០០៥

### ថ្ងៃទី ១៣-១៦ ខែ មករា ឆ្នាំ ២០០៥

កិច្ចសន្យាមួយត្រូវបានចុះហត្ថលេខារវាងអ្នកតំណាងសហគមន៍មុនពេលចុះកិច្ចសន្យាចំនួន៣៦នាក់ និងក្រុមហ៊ុន 7NG ។ កិច្ចសន្យានេះផ្តល់ដីទំហំ៣,៦ហិកតាទាំងអស់នៅតំបន់ដីក្រហមឱ្យក្រុមហ៊ុន 7NG ជាថ្នូរនិងការសាងសង់ផ្ទះល្វែងថ្មីនៅភូមិដំណាក់ត្រយឹងសង្កាត់ចោមចៅ ខណ្ឌដង្កោ ជូនអ្នកភូមិ។ (យោងតាមអ្នកតំណាងភូមិក្រោយពេលចុះកិច្ចសន្យាអ្នកភូមិមិនត្រូវបានគេជូនដំណឹងអំពីកិច្ចសន្យានេះជាមុនឡើយ ហើយក៏មិនបានយល់ព្រមទៅរស់នៅកន្លែងតាំងលំនៅដ្ឋានថ្មីដែរ)។ យោងតាមកិច្ចសន្យានេះ អ្នកតំណាងសហគមន៍ទាំង ៣៦ នាក់ បានចុះហត្ថលេខានៅថ្ងៃទី១៣ ខែមករា ហើយនាយកក្រុមហ៊ុន 7NG ឈ្មោះ ស្រី ច័ន្ទ (និងសាក្សីដឹងឮ រួមមានអតីតមេភូមិ២ និងមេភូមិ១៥) បានចុះហត្ថលេខា ៣ថ្ងៃក្រោយមក។

**ឯកសារយោង: ឧបសម្ព័ន្ធទី៣**

**ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥-** អ្នកភូមិបានទទួលដំណឹងអំពីកិច្ចសន្យាកាលពីកិច្ចប្រជុំមួយជាមួយមន្ត្រីមូលដ្ឋាន រួមមានមេភូមិ និងអ្នកតំណាងសហគមន៍ មុនពេលចុះកិច្ចសន្យា ប៉ុន្តែកិច្ចសន្យានេះ គេមិនបានឱ្យទៅអ្នកភូមិទេ។ យោងតាមអ្នកតំណាងសហគមន៍ក្រោយពេលចុះកិច្ចសន្យាអ្នកភូមិត្រូវបានគេអះអាងថាកិច្ចសន្យានេះគឺជាកិច្ចសន្យាស្ម័គ្រចិត្តទាំងស្រុង-ពួកគេអាចជ្រើសរើសថា ព្រមទទួល យកសំណើរបស់ក្រុមហ៊ុន 7NG ក៏បាន ឬមិនព្រមទទួលយកក៏បាន។

**ឯកសារយោង: ឧបសម្ព័ន្ធទី៧ និងឧបសម្ព័ន្ធទី៨**

**ថ្ងៃទី ២១ ខែ មករា-ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥** - អ្នកភូមិតវ៉ាជំទាស់ភាពស្របច្បាប់នៃកិច្ចសន្យានេះ។ អ្នកភូមិឈប់ទទួលស្គាល់អ្នកតំណាងសហគមន៍មុនពេលចុះកិច្ចសន្យា ហើយតែងតាំងអ្នកតំណាងសហគមន៍ថ្មីចំនួន២៣នាក់ជំនួសវិញ ។អ្នកតំណាងក្រោយពេលចុះ កិច្ចសន្យាទាំងនេះប្រឈមនឹងការអុកឡុករំខាន ដែលក្នុងនោះអ្នកតំណាងមួយចំនួន ត្រូវបានបុគ្គលិកសន្តិសុខភូមិឃាត់ខ្លួនមួយរយៈខ្លីនៅពេលដែលពួកគេចាប់ផ្តើមដើរប្រមូលអ្នកភូមិឱ្យផ្តិតមេដៃលើញត្តិតវ៉ាមួយ ដើម្បីផ្ញើទៅសាលាក្រុងសុំមោឃ ភាពកិច្ចសន្យានេះ។ នៅថ្ងៃទី ៤ ខែ កុម្ភៈអ្នកតំណាងសហគមន៍ក្រោយពេលចុះកិច្ចសន្យាទទួលបានកិច្ចសន្យាជាមួយក្រុមហ៊ុនមួយច្បាប់ ហើយក៏ដឹងច្បាស់ថា ជាការផ្ទុយទៅនឹងអ្វីដែលគេបានប្រាប់អ្នកភូមិ កិច្ចសន្យានេះទំនងជាកិច្ចសន្យាចងកាតព្វកិច្ចខាងផ្លូវច្បាប់ (មិនមែនជាកិច្ចសន្យាដែលធ្វើឡើងដោយស្ម័គ្រចិត្តឡើយ)។ មកដល់ថ្ងៃទី ៧ ខែកុម្ភៈ ស្នាមមេដៃអ្នកភូមិ ៨០៤ គ្រួសារ ត្រូវបានប្រមូល និងញត្តិតវ៉ាក៏ត្រូវបានបញ្ជូនទៅសាលាក្រុង។ នៅថ្ងៃទី ២៥ ខែកុម្ភៈ អ្នកតំណាងសហគមន៍ចំនួន ២៣ នាក់ត្រូវបានគេកោះ

ហៅឱ្យចូលរួមក្នុងកិច្ចប្រជុំមួយនៅសាលាខណ្ឌដែលកំឡុងពេលប្រជុំនោះអ្នកតំណាងសហគមន៍ទាំងនោះ ត្រូវបានគេចោទប្រកាន់ពីបទក្លែងស្នាមមេដៃ ដែលបានផ្តិតនៅលើញត្តិតវ៉ា។ នៅថ្ងៃបន្ទាប់មកដោយសារតែចម្លើយពីសាលាក្រុងគ្មានន័យទាល់តែសោះ អ្នកតំណាងសហគមន៍ សរសេរពាក្យបណ្តឹងថ្មីមួយផ្ញើជូនទៅសមាជិករដ្ឋសភាម្នាក់ ឈ្មោះ ហូ វ៉ាន់ សុំឱ្យជួយធ្វើអន្តរាគមន៍។

**ឯកសារយោង : ឧបសម្ព័ន្ធទី៤ និងឧបសម្ព័ន្ធទី៧**

**ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០០៥** - ប្រធានសង្កាត់ទន្លេបាសាក់ចេញសេចក្តីក្រាសលេខ ០០៧ ជូនដំណឹងដល់សហគមន៍ដីក្រហម។ សេចក្តីប្រកាសនេះកំណត់ថាការិយាល័យសង្កាត់ទទួលស្គាល់តែស្ថិតិនិងបញ្ជីឈ្មោះគ្រួសារប្រជាពលរដ្ឋរស់នៅដំបន់ដីក្រហមដែលចងក្រងដោយអ្នកតំណាងសហគមន៍មុន ពេលចុះកិច្ចសន្យាស្ថិតក្រោម គណៈកម្មការចាត់តាំងឱ្យមានប៉ុណ្ណោះ។

**ឯកសារយោងៈ ឧបសម្ព័ន្ធទី៥**

**ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៥** - អង្គការជំនួយផ្នែកច្បាប់កម្ពុជា ដាក់សំណើដំបូងក្នុងនាមអ្នកភូមិសហគមន៍ដីក្រហមជូន លោកអភិបាល ក្រុងភ្នំពេញដើម្បីសុំកិច្ចអន្តរាគមន៍។ អង្គការនោះកត់សម្គាល់ថាកិច្ចសន្យាជាមួយក្រុមហ៊ុន 7NG ត្រូវបានធ្វើឡើងស្ងាត់ៗដោយអតីតអ្នកតំណាងសហគមន៍ហើយថាសាលាក្រុងមិនទាន់បានឆ្លើយតប ចំពោះសំណើម្តងហើយម្តងទៀតរបស់អ្នកភូមិនៅឡើយទេ ដើម្បីសុំកិច្ចអន្តរាគមន៍នោះ។

**ឯកសារយោងៈ ឧបសម្ព័ន្ធទី៦**

**[មិនមានចុះថ្ងៃខែ]ឆ្នាំ ២០០៥**-អ្នកតំណាងថ្មីបានព្រាងលិខិតមួយច្បាប់ផ្ញើជូនទៅឧបនាយករដ្ឋមន្ត្រី ដើម្បីជម្រាបអំពីការបំភិតបំភ័យ និង សកម្មភាពខុសច្បាប់របស់អតីតអ្នកតំណាងសហគមន៍និងជននៅក្រោមគណៈកម្មការ។ ទោះបីជាលិខិតនោះមិនបានបញ្ជូនក៏ដោយ ក៏អ្នកភូមិបានរក្សាលិខិតនោះទុកជាឯកសារបញ្ជាក់អំពីការតស៊ូរបស់ពួកគាត់ដើម្បី រក្សាបានដីធ្លី។

**ឯកសារយោងៈ ឧបសម្ព័ន្ធទី៧**

## ឆ្នាំ ២០០៦

**ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៦**-អ្នកតំណាងថ្មីដាក់បណ្តឹងជូនលោកប្រធានការិយាល័យរៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីនៅទីក្រុងភ្នំពេញ ដើម្បីពន្យល់ព័ត៌មានពិស្តារអំពីហេតុផលដែលកិច្ចសន្យានោះមិនត្រូវបានគោរពឬមិនត្រូវបានចាត់ទុកថាស្របច្បាប់។បណ្តឹងនោះលើកឡើងថាអ្នកភូមិបានទទួលរងនូវការបំភិតបំភ័យ និងការគំរាមកំហែង ដែលធ្វើឡើងដោយមានបំណងឱ្យពួកគេយល់ព្រមផ្លាស់ទីតាំងចេញពីកន្លែងបច្ចុប្បន្ន។ បណ្តឹងនោះលើកឡើងផងដែរថា កិច្ចសន្យានោះគឺ "រំលោភបំពានទាំងស្រុង [.......] ទៅលើគោលនយោបាយរបស់រាជរដ្ឋាភិបាល"។

**ឯកសារយោងៈ ឧបសម្ព័ន្ធទី៨**

**ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៦** - អ្នកតំណាងថ្មី បញ្ជូនបណ្តឹងទៅលោកឧបនាយករដ្ឋមន្ត្រី/រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងទៅរដ្ឋមន្ត្រីទទួល បន្ទុកកិច្ចការរដ្ឋសភា និងអធិការកិច្ច ដើម្បីស្នើសុំរដ្ឋមន្ត្រីទាំងពីរដោះស្រាយបណ្តឹងពួកគេ ដែលសាលាក្រុងធ្វើមិនដឹងមិនឮ។
**ឯកសារយោង: ឧបសម្ព័ន្ធទី៩**

**ខែកក្កដា និងខែសីហា ឆ្នាំ ២០០៦** - អ្នកតំណាងថ្មីប្រមូលស្នាមមេដៃអ្នកភូមិជាង ៣៧០ គ្រួសារ ដែលនៅសល់នៅសហគមន៍ដីក្រហមក្នុងការបង្ហាញអំពីសិទ្ធិអំណាចរបស់ខ្លួន ដើម្បីតំណាងឱ្យផលប្រយោជន៍/សិទ្ធិរបស់សហគមន៍ ។ឯកសារដើមទាំងឡាយដែលមានរូប ថតនិងស្នាម មេដៃ/ហត្ថលេខារបស់មេគ្រួសារនីមួយៗ ត្រូវបានដាក់ជូនសាលាខណ្ឌ។
**ឯកសារយោង: ឧបសម្ព័ន្ធទី១០**

**ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៦** - សន្តិសុខភូមិឈ្មោះ ពិក ប៉ម វាយអ្នកតំណាងថ្មី និងម្ចាស់ផ្ទះឈ្មោះ សេក សារឿន ដែលបដិសេធមិនព្រមចេញពីផ្ទះ។ (តាមអ្នកតំណាងថ្មី បានឱ្យដឹងថា ក្រោយមក ឈ្មោះ ពិក ប៉ម ត្រូវបានចោទប្រកាន់ដោយតុលាការ ពីបទបង្ករបួសស្នាម ដោយសារការប្រព្រឹត្តិនេះ ប៉ុន្តែអង្គការ លីកាដូ កាណាដា មិនអាចបញ្ជាក់ ព័ត៌មានជាផ្លូវការបានទេ។)
**ឯកសារយោង: រូបថត ១ សន្លឹក និងឧបសម្ព័ន្ធទី១១**

**ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៦** - តំណាងរាស្ត្រ ហូ វ៉ាន់ (មកពីគណៈបក្សសមរង្ស៊ី) ផ្ញើលិខិតជូននាយករដ្ឋមន្ត្រីទាក់ទងនឹងកិច្ចសន្យា និងជួយបញ្ជូនការទទួចចង់បានរបស់អ្នកតំណាងថ្មី ដែលថា ផែនការអភិវឌ្ឍន៍ដើមសំរាប់ការផ្លាស់ទីតាំងនៅនឹងកន្លែងរបស់រដ្ឋាភិបាលត្រូវតែអនុវត្ត។
**ឯកសារយោង: ឧបសម្ព័ន្ធទី១១**

**ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៦** - ការចាប់ឆ្នោតត្រូវបានរៀបចំឡើងដើម្បីធ្វើការបែងចែកផ្ទះល្វែងនៅដំណាក់ត្រយឹងជូនដល់អ្នកភូមិ ៣៨៤ គ្រួសារមកពីសហគមន៍ដីក្រហម។ គ្រួសារមួយចំនួនរាយការណ៍ថា ពួកគេត្រូវបានបង្ខំឱ្យចូលរួមតាមរយៈការគំរាមកំហែង និងការបំភិតបំភ័យ។ ប្រហែលជា៥០គ្រួសារបដិសេធមិនចូលរួម។ ការចាប់ឆ្នោតដំបូង ដែលគ្រោងរៀបចំនៅថ្ងៃទី១៤ ខែកក្កដា ត្រូវបានលុបចោលវិញដោយគ្មានអ្នកចូលរួម។ អតីតអ្នកតំណាងនិយាយថា អ្នកភូមិ ៣៨៤ គ្រួសារ ដែលចូលរួមចាប់ឆ្នោតកាលថ្ងៃទី៩ ខែសីហា បានចូលរួមដោយស្ម័គ្រចិត្ត។ ដោយលើកឡើងអំពីគ្រួសារដែលបដិសេធមិនចាកចេញពីសហគមន៍ដីក្រហម អតីតអ្នកតំណាងឈ្មោះ ផាន់ ណារិន និយាយថា "ប្រសិនបើ ពួកគេមិនចង់ទៅ យើងនឹងហៅពួកគេមកប្រជុំ ដើម្បីបញ្ចុះបញ្ចូលពួកគេឱ្យយល់"។
**ឯកសារយោង: ឧបសម្ព័ន្ធទី១២**

**ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦-** តំណាងរាស្ត្រ ហូ វ៉ាន់ ផ្ញើលិខិតមួយច្បាប់ជូនលោកអភិបាលក្រុងភ្នំពេញ ទាក់ទងនឹងសេចក្តីណែនាំផ្ញើឡើងដោយអាជ្ញាធរខណ្ឌចំពោះអ្នកលក់ដូរ នៅផ្សារសហគមន៍ដីក្រហម ឱ្យរុះរើតូបចេញ។ អ្នកលក់ដូរស្នើសុំឱ្យពួកគេអាចលក់ដូរទំនិញនៅទីនោះ ឬនៅកន្លែងមួយផ្សេងក្បែរផ្សារនោះ ដើម្បីចិញ្ចឹមគ្រួសារ។

**ឯកសារយោង: ឧបសម្ព័ន្ធទី១៣**

**ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៦ -** អ្នកតំណាងថ្មី ៤ នាក់ ដាក់ពាក្យបណ្តឹងទៅព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញប្តឹងអតីតអ្នកតំណាង ចំនួន ៣៦ នាក់ ពីបទ "រំលោភសេចក្តីទុកចិត្ត" និង "ប្រព្រឹត្តអំពើពុករលួយ និង "គៃបន្លំប្រាក់"។

**ឯកសារយោង: ឧបសម្ព័ន្ធទី១៤**

**ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០០៦ -** ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ បដិសេធពាក្យបណ្តឹង ដែលបានដាក់ជូនតុលាការកាលពីថ្ងៃទី ១ ខែកញ្ញា ឆ្នាំ ២០០៦ ដោយគ្មានការពន្យល់ហេតុផលអ្វីឡើយ។ អ្នកតំណាងថ្មីប្តឹងទៅសាលាឧទ្ធរណ៍ភ្លាមក្រោយពីបានទទួលសេចក្តីជូន ដំណឹង។ ចាប់តាំងពីពេលរបាយការណ៍នេះត្រូវបានសរសេរ គ្មានដំណឹងអ្វីពី សាលាឧទ្ធរណ៍ឡើយ។

**ឯកសារយោង: ឧបសម្ព័ន្ធទី១៥**

**ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៦ -** ចៅសង្កាត់ទន្លេបាសាក់ ចេញសេចក្តីប្រកាសទៅកាន់អ្នកភូមិសហគមន៍ដីក្រហម ដោយជម្រាបឱ្យដឹងជាមុនថា អ្នកភូមិមិនត្រូវសាងសង់ផ្ទះ ថ្មីនៅលើដី ដែលគេរុះរើផ្ទះរួចហើយឡើយ។ អ្នកភូមិមាន ៣ ថ្ងៃ ដើម្បីរុះរើផ្ទះថ្មីនោះបើមិន ដូច្នោះ អាជ្ញាធរសង្កាត់នឹងកំទេចផ្ទះទាំងនោះចោល។

**ឯកសារយោង: ឧបសម្ព័ន្ធទី១៦**

**ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៦ -** ការិយាល័យរៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី ចេញប្លង់កម្មសិទ្ធិដីធ្លីទៅឱ្យក្រុមហ៊ុន 7NG លើផ្ទៃកដីទំហំ ២ ហិកតា របស់សហគមន៍ ដីក្រហម ដែលគេដឹងថា នៅភូមិ ២។ (មិនច្បាស់លាស់ទេ ប៉ុន្តែអាចដែរថាប្លង់កម្មសិទ្ធិស្រដៀងគ្នាមួយក៏ត្រូវបានចេញផងដែរសំរាប់ដីទំហំ ១.៦ ហិកតា ដែលនៅសល់នៅសហគមន៍ដីក្រហម។ ក្រុមហ៊ុន 7NG បាននិយាយដដែលៗថា ខ្លួនមានប្លង់កម្មសិទ្ធិលើផ្ទៃដីទាំងអស់របស់សហគមន៍ដីក្រហម។)

**ឯកសារយោង: ឧបសម្ព័ន្ធទី១៧ ចំនុច ក) និង ខ)**

## ឆ្នាំ ២០០៧

**ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ២០០៧ -** អភិបាលខណ្ឌចំការមន ចេញលិខិតលេខ ០០២ ជូនដំណឹងដល់អ្នកភូមិសហគមន៍ដីក្រហមដោយទទូចថា ពួកគេត្រូវតែឈប់សាងសង់ផ្ទះថ្មី និងរក្សាផ្ទះ ចាស់ៗឱ្យស្ថិតនៅក្នុងស្ថានភាពដដែល។

**ឯកសារយោង: ឧបសម្ព័ន្ធទី១៨**

**ថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ២០០៧**-ផ្អែកលើបណ្តឹងរបស់ក្រុមហ៊ុន 7NG តុលាការក្រុងភ្នំពេញធ្វើការចោទប្រកាន់អ្នកតំណាងសហគមន៍ថ្មីចំនួន៥នាក់ (រាប់បញ្ចូលទាំងឈ្មោះ សេក សារឿន ដែលសន្តិសុខបានវាយកាលពី ខែកក្កដា ឆ្នាំ ២០០៦)ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។ បទចោទទាំងនោះ ទាក់ទងនឹងការធ្វើឱ្យខូចខាតរបងក្រុមហ៊ុន ដែលប្រព្រឹត្តឡើង ដោយអ្នកភូមិជាច្រើននាក់កាលពី ថ្ងៃទី ២៦ ២៩ និង ៣០ ខែមិថុនា។

**ប្រភព: ការថ្លែងប្រាប់ដោយមន្ត្រីតុលាការ**

**ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៧** - តុលាការក្រុងចេញដីកាកោះអ្នកភូមិចំនួន ៤៩ គ្រួសារ ឱ្យចូលខ្លួនទៅតុលាការនៅថ្ងៃទី២៧ ខែសីហា ដើម្បីពិភាក្សាបញ្ហា"មិនអនុវត្ត តាមកិច្ចសន្យា"។ គ្រួសារជាច្រើនបានបដិសេធមិនចូលរួមការចាប់ឆ្នោតកាលពីថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០០៦ ដើម្បីធ្វើការបែងចែកផ្ទះល្វែងនៅភូមិដំណាក់ត្រយឹង។ តាមអ្នកតំណាងថ្មីបានឱ្យដឹងថា គ្រួសារអ្នកភូមិត្រូវបានគេផ្តល់មតិកុំចូលទៅតុលាការនៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០០៧ ពីព្រោះតែគ្មានជំនឿទៅលើតុលាការ និងគ្មានអ្នក តំណាងផ្នែកច្បាប់។

**ឯកសារយោង: ឧបសម្ព័ន្ធទី១៩ (គំរូដីកាកោះ)**

**ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៧**

សាលាក្រុងចេញបញ្ជាមួយថា ក្រណាត់កៅស៊ូ ខ្ទម និង គ្រែទាំងឡាយនៅសហគមន៍ដីក្រហម ដែលពីមុនត្រូវបានកាន់កាប់ប្រើប្រាស់ដោយក្រុមគ្រួសារអ្នកភូមិ ដែលបានចាកចេញទៅដំណាក់ត្រយឹងរួចហើយ ត្រូវតែកំទេចចោល។

**សូមមើលឯកសារយោងទៅលើបទបញ្ជាសាលាក្រុងនៅក្នុងខ្លឹមសារបន្ថែមលេខ ២០ ក) និង ២២**



នគរបាល និងកងរាជអាវុធហត្ថ និងអ្នកបំបែកមកដល់ ថ្ងៃទី ២៩ ខែសីហា

**ថ្ងៃទី ២៩-៣១ ខែ សីហា ឆ្នាំ ២០០៧** - កងរាជអាវុធហត្ថ នគរបាលប្រដាប់ដោយអាវុធ និងកម្មករស៊ីឈ្នួល បានមកដល់សហគមន៍ដីក្រហមនៅថ្ងៃទី២៩ដើម្បីកំទេចតង់ និងជម្រកតាមបទបញ្ជារបស់សាលាក្រុងកាលពីថ្ងៃទី១៦ខែសីហា។ នៅពេលដែលអ្នកភូមិព្យាយាមការពារកុំឱ្យមានការកំទេច នគរបាលបានបញ្ជាឱ្យកម្មករសំណង់បញ្ច្រៀតចូលតាមហ្វូងអ្នកតវ៉ា ដែលបានបង្កឱ្យមានការប្រឈមមុខដាក់គ្នា ដោយហិង្សាយ៉ាងាយស្រួល។ កំឡុងកើតហេតុកម្មករក្រុមហ៊ុន 7NG ម្នាក់ដាក់ខ្នោះអ្នកតំណាងស្រីម្នាក់របស់សហគមន៍ដែលកំពុងតែធ្វើការតវ៉ាដោយសន្តិវិធីនាងត្រូវបានគេដាក់ខ្នោះជាច្រើនម៉ោង។ ជម្រកជាង ៣០ ត្រូវបានបំផ្លាញកាលពីថ្ងៃទី២៩ ខែសីហាអ្នកភូមិបានបដិសេធថា ពួកគេមិនបានសាងសង់ជម្រកនៅលើដីដែលគេចាកចេញពី មុន១នោះទេ។



កងរាជអាវុធហត្ថ នគរបាល និងកម្មករស៊ីឈ្នួលមកដល់ផងដែរ នៅថ្ងៃទី ៣០ និង ៣១ ប៉ុន្តែត្រូវបានធ្វើឱ្យជាប់កុនដោយអ្នកភូមិដែលបានប្រមូលផ្តុំគ្នានៅតាមផ្លូវ គ្រវីទង់ជ័យ និងរូបថតលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងភរិយារបស់លោក ប៊ុន រ៉ានី និងចាក់ផ្សាយសន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលនិយាយអំពីការដាក់បញ្ចូល សហគមន៍ដីក្រហមទៅក្នុងផែនការអភិវឌ្ឍន៍សំរាប់អ្នកក្រីក្ររបស់រដ្ឋាភិបាល។

**ឯកសារយោង: ឧបសម្ព័ន្ធទី២០ ចំនុច ក) និង ខ) និង ឧបសម្ព័ន្ធទី២២**

ថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០០៧ - អ្នកភូមិចំនួន ២៨៨ គ្រួសារ ផ្ញើញត្តិទៅលោកនាយករដ្ឋមន្ត្រី ដើម្បីស្នើសុំឱ្យផ្តល់ប្លង់កម្មសិទ្ធិដីធ្លីទៅលើដីទំហំ ១.៩ ហិកតា នៅសហគមន៍ ដីក្រហម និងស្នើសុំការអនុញ្ញាតដើម្បីរៀបចំគូរប្លង់ និងកសាងគម្រោងអភិវឌ្ឍន៍លំនៅដ្ឋានដោយខ្លួនឯង។

**ឯកសារយោង: ឧបសម្ព័ន្ធទី២១**

**ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧**-នៅក្នុងអត្ថបទកាសែតមួយលោកស្រីសុធាជាទីប្រឹក្សាក្រុមហ៊ុន 7NG ទទួលស្គាល់ថាក្រុមគ្រួសារមួយចំនួន ដែលនៅសល់លើតំបន់ដីក្រហម មានសិទ្ធិស្របច្បាប់ទៅលើដីរបស់ពួកគេ។ អត្ថបទកាសែតឌី ឃាមបូឌាដេលី ផ្សាយថា "លោក ស្រី សុធា ជាទីប្រឹក្សា និងជាសាច់ញាតិរបស់លោកប្រធានក្រុមហ៊ុន 7NG ឈ្មោះស្រីចាន់ធូបានមានប្រសាសន៍កាលពីថ្ងៃពុធថាមានតែ១៧៩គ្រួសារប៉ុណ្ណោះបានរស់នៅតំបន់នោះដោយស្របច្បាប់" ។កាសែតនេះបានដកស្រង់នៅពេលដែលលោកនិយាយ អំពីក្រុមគ្រួសារទាំងនេះថា "ប្រសិនបើពួកគេលក់ផ្ទះទាំងនោះ យើងនឹងទិញផ្ទះតាមតម្លៃសមស្រប ឬពួកគេអាចយកផ្ទះល្វែង [នៅដំណាក់ត្រយឹងក៏បាន]។

**ប្រភព : កាសែត ឌី ឃាមបូឌា ដេលី ចេញផ្សាយថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០៧**

**ថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០០៧** - អ្នកតំណាងសហគមន៍ដីក្រហមចំនួន ៥ នាក់ ដែលតំណាងឱ្យ ៥៦ គ្រួសារដាក់ពាក្យបណ្តឹងទៅតុលាការក្រុងប៊្លងឈ្មោះ ម៉ា សុភាព (អភិបាលរងខណ្ឌចំការមន) ឈ្មោះ ប៉ែន សុធី (អតីតចៅសង្កាត់) ឈ្មោះ ង៉ែត សំអាត (ជានគរបាលខណ្ឌដង្កោ និងជាអង្គរក្សក្រុមហ៊ុន 7NG) ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជនប្រើប្រាស់អំពើហិង្សា និង "បង្កចលាចល" នៅសហគមន៍ដីក្រហមកាលពីថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០០៧។ បណ្តឹងនោះទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៥០.០០០ ដុល្លាអាមេរិក។

**ឯកសារយោង: ឧបសម្ព័ន្ធទី២២**

**ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ ២០០៧** - លោក ស្រី សុធា ទីប្រឹក្សាក្រុមហ៊ុន 7NG ត្រូវបានដកស្រង់នៅក្នុងអត្ថបទកាសែតមួយនៅពេលដែលនិយាយថាក្រុមហ៊ុនចង់ឱ្យសាលាក្រុងបណ្តេញគ្រួសារដែលនៅសេសសល់នៅសហគមន៍ដីក្រហម។ គាត់និយាយថា "យើងបានយក

អ្នកភូមិចេញអស់ ៨៧ ភាគរយហើយ "ឥឡូវ យើងទុកឱ្យសាលាក្រុងបណ្តេញ អ្នកនៅសល់ ពីព្រោះយើងចំណាយពេលវេលាច្រើនហើយ ដើម្បីចរចាជាមួយពួកគេ។ ពួកគេកំពុងតែបន្តការតវ៉ាដើម្បីយកលុយបន្ថែមទៀតពីក្រុមហ៊ុន "។ គាត់បន្ថែមទៀតថា ក្រុមហ៊ុន7NG មានប្លង់កម្មសិទ្ធិដីធ្លី ចេញនៅឆ្នាំ ២០០៥ សំរាប់ដីនៅសហគមន៍ដីក្រហម។ ការនិយាយរបស់គាត់មានភាពផ្ទុយគ្នាទៅនឹងការថ្លែងរបស់គាត់កាលពីពេលមុននៅ ក្នុងកាសែតឌឹឃាមបូឌាដេលី ចេញផ្សាយថ្ងៃទី ៣០ ខែសីហា ដែលថាក្រុមហ៊ុនបានទទួលស្គាល់ថា ក្រុមគ្រួសារដែលនៅសល់នៅសហគមន៍ដីក្រហម គឺរស់នៅដោយស្របច្បាប់ នៅតំបន់នោះ។

**ប្រភព : កាសែតភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី ៧-៩ ខែកញ្ញា; សូមមើលឧបសម្ព័ន្ធ ២២ ចំនុច ក)**

**ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០០៧** - តុលាការក្រុងចាប់ខ្លួន អ្នកតំណាងសហគមន៍ឈ្មោះ រស់ ពៅ ពីបទបង្ករបួសស្នាម ហើយបានបញ្ជូនគាត់ទៅពន្ធនាគារព្រៃសដើម្បីឃុំខ្លួនបណ្តោះអាសន្ន។ គាត់ត្រូវបានជាប់ចោទពីបទបំពាបំពានលើរូបកាយនិងបង្ករបួសស្នាមដល់កម្មករក្រុមហ៊ុនជាច្រើននាក់កាលពីថ្ងៃទី៤ ខែសីហា នៅពេលក្រុមកម្មករក្រុមហ៊ុនបានចូល មករុះរើផ្ទះមួយចំនួននៅសហគមន៍។ (បុគ្គលិកអង្គការសិទ្ធិមនុស្សម្នាក់ដែលមានវត្តមាននៅពេលនោះមិនបានឃើញថាគាត់បានវាយ/បង្ករបួសស្នាមទៅលើនរណាម្នាក់ឡើយ។)

**ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ២០០៧**-សាលាក្រុងភ្នំពេញរៀបចំការប្រជុំមួយជាមួយអ្នកភូមិដែលនៅសេសសល់នៅសហគមន៍ដីក្រហម នៅពេលប្រជុំនោះមន្ត្រីផ្សេងៗក៏ឃោសនាអំពី កន្លែងតាំងលំនៅថ្មីនៅដំណាក់ត្រយឹង។ អ្នកតំណាងថ្មី ២ នាក់ត្រូវបានអនុញ្ញាត ឱ្យនិយាយទៅកាន់ហ្វូងមនុស្ស ប៉ុន្តែត្រូវបានហាមឃាត់មិនឱ្យបង្ហាញរូបថតទៅហ្វូងមនុស្ស នោះឡើយ។

**ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧**-អ្នកតំណាងសហគមន៍រៀបចំសន្និសិទកាសែតនៅសហគមន៍ដីក្រហម ដើម្បីជម្រាបឱ្យដឹងអំពីផែនការផ្លាស់ទីតាំងដែលពួកគាត់បានបង្កើតឡើង។ ផែនការនេះ ប្រមើលទុកជាមុនថាអ្នកភូមិត្រូវបានគេផ្តល់អគារផ្ទះល្វែងថ្មីកំពស់ ៣ ជាន់នៅសហគមន៍ដើម្បីរស់នៅ ដោយក្រុមគ្រួសារដែលរស់នៅជាន់ទី ២ និងជាន់ទី ៣ នឹងធ្វើការបែងចែកកន្លែងលក់ដូរនៅជាន់ផ្ទាល់ដីដើម្បីធានាបាននូវការងារធ្វើសំរាប់ពួកគេ។ ផែនការនេះធ្វើការបែងចែកដីទំហំ ១.៥ ហិកតាទៅឱ្យក្រុមហ៊ុន 7NG ដើម្បីអភិវឌ្ឍពាណិជ្ជកម្ម - ដីកន្លះហិកតាធំជាងទំហំដីផ្តល់ឱ្យក្រុមហ៊ុន ត្រូវបានផ្តល់ឱ្យក្រោមផែនការអភិវឌ្ឍន៍របស់រដ្ឋាភិបាល។

**ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧** - កំឡុងពេលសន្និសិទកាសែត ដែលរៀបចំឡើងដោយអ្នកតំណាងសហគមន៍ សន្តិសុខក្រុមហ៊ុន 7NG ម្នាក់ ប៉ុនប៉ងថតរូបអ្នកតំណាងស្ត្រីម្នាក់ក្នុងចំណោមអ្នកតំណាងទាំងឡាយដោយប្រើទូរស័ព្ទ។ ដើម្បីការពារកុំឱ្យគេថតអ្នកតំណាងស្រីនោះ បានរុញដៃសន្តិសុខចេញ។សន្តិសុខនោះក៏ធ្លាក់ទូរស័ព្ទពីដៃហើយ- គាត់មិនរើស ទូរស័ព្ទនោះឡើងទេ ភ្លាមនោះក៏ទៅកាន់ប៉ុស្តិ៍នគរបាលដោយប្តឹងថាអ្នកតំណាងសហគមន៍បានលួចទូរស័ព្ទខ្លួន។ សមាជិកសហគមន៍ក្រោយមកក៏បានប្រគល់ទូរស័ព្ទនោះទៅឱ្យនគរបាល។ នគរបាលក៏នាំខ្លួនអ្នកតំណាងស្ត្រីនោះទៅកាន់ប៉ុស្តិ៍នគរបាលសង្កាត់ទន្លេបាសាក់ដើម្បីសាកសួរដែលនៅទីនោះអ្នកភូមិសហគមន៍ដីក្រហមបានប្រមូលផ្តុំជាហ្វូងដ៏ធំនៅខាងក្រៅ ប៉ុស្តិ៍នគរបាលដើម្បីទាមទារឱ្យមានការដោះលែងអ្នកតំណាងស្រីនោះ។ ជាយថាហេតុ នគរបាល ក៏អនុញ្ញាតអ្នកតំណាងស្រីនោះចេញពីប៉ុស្តិ៍នគរបាល។

**ឯកសារយោង : ឧបសម្ព័ន្ធទី២៣**

**ថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧** - តុលាការក្រុងភ្នំពេញធ្វើការចោទប្រកាន់ពីបទប្លន់ទៅលើអ្នកតំណាងស្រីរបស់សហគមន៍នោះពាក់ព័ន្ធឧប្បត្តិហេតុរឿងទូរស័ព្ទកាលពីថ្ងៃទី៧ខែកញ្ញា។ អ្នកតំណាងស្រីនោះ និងអ្នកភូមិម្នាក់ទៀត ក៏ត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យផងដែរ ពាក់ព័ន្ធនឹងការធ្វើឱ្យខូចខាតម៉ូតូនគរបាលដែលបង្កឡើងដោយហ្វូង អ្នកភូមិដែលប្រមូលផ្តុំគ្នានៅខាងក្រៅប៉ុស្តិ៍នគរបាល កាលពីថ្ងៃទី២៧ ខែកញ្ញា។

**ថ្ងៃទី២២ ខែតុលា ឆ្នាំ ២០០៧** - តុលាការក្រុងភ្នំពេញធ្វើការចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិទៅលើអ្នកភូមិ ៨ នាក់ រួមទាំងអ្នកតំណាងសហគមន៍ជាច្រើននាក់ និងពីបទសមគំនិតទៅលើអ្នកភូមិមួយចំនួនដែលគេមិនស្គាល់។ បទចោទប្រកាន់នេះទាក់ទងនឹងការរុះរើបដាដែលសរសេរថា ដីក្រហមគឺជា"កន្លែងសួនសាធារណៈ "ចេញកាលពីថ្ងៃទី១៧ ខែតុលា។ បដានោះត្រូវបានចងព្យួរ ដោយមន្ត្រីសង្កាត់។

**ថ្ងៃទី៣ ខែធ្នូ ឆ្នាំ ២០០៧** - ប្រហែលជាម៉ោង ៨ យប់ បុគ្គលិលក្រុមហ៊ុន 7NG ជាច្រើននាក់មានបំណងនាំយកគ្រឿងចក្រសំរាប់ជីកចូលក្នុងសហគមន៍ដីក្រហម ដែលបានបង្ក ឱ្យមានប្រតិកម្មខឹងសម្បាពីអ្នកភូមិដែលភ័យខ្លាចថាគ្រឿងចក្រនោះនឹងត្រូវបានប្រើដើម្បីរុះរើផ្ទះរបស់ពួកគាត់។អ្នកភូមិមួយចំនួន ភាគច្រើនជាកុមារក៏ចោលដុំថ្មទៅលើគ្រឿង ចក្រនោះ បណ្តាលឱ្យបែកកញ្ចក់បង្អួច របស់គ្រឿងចក្រនិងតាមព័ត៌មានបានធ្វើឱ្យបុគ្គលិលក្រុមហ៊ុន 7NG ម្នាក់រងរបួសផង។ អ្នកតំណាងសហគមន៍ក៏អំពាវនាវដល់ហ្វូងអ្នកភូមិឱ្យស្ងប់ស្ងាត់ និងកុំឱ្យប្រើអំពើហិង្សា។

**ឯកសារយោង: ឧបសម្ព័ន្ធទី២៤**

**ថ្ងៃទី៧ ខែធ្នូ ឆ្នាំ ២០០៧**- ដោយផ្អែកលើបណ្តឹងរបស់ក្រុមហ៊ុន ៧ណអ អំពីឧប្បត្តិហេតុកាលពីថ្ងៃទី៣ តុលាការក្រុង ភ្នំពេញបានធ្វើការចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនិងបង្ករបួសស្នាមទៅលើអ្នកតំណាងសហគមន៍៣នាក់ ។ តាមពិតជនជាប់ចោទទាំង ៣ នាក់នោះ បានធ្វើការអំពាវនាវទៅកាន់ហ្វូងអ្នកភូមិឱ្យស្ងប់ស្ងាត់ និងកុំឱ្យប្រើអំពើហិង្សា ទៅលើទ្រព្យសម្បត្តិ ឬបុគ្គលិកក្រុមហ៊ុនទេ។

□ □ □

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខៈ ៤០៧៥ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៣

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ជំរាបជូន

**ឯកឧត្តម អភិបាលរាជធានីភ្នំពេញ**

កម្មវត្ថុ ៖ករណីសំណើសុំគោលការណ៍រៀបចំសម្បទានដីសង្គមកិច្ច ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន ជូនសហគមន៍ក្រីក្រ ក្នុងរាជធានីភ្នំពេញ ។

យោង ៖- លិខិតលេខ ១៩០០ របក ចុះថ្ងៃទី ២៧-៦-២០០៣ របស់សាលាក្រុងភ្នំពេញ

- ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០៤-៧-២០០៣ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជំរាបឯកឧត្តមជ្រាបថា ៖ ចំពោះ បញ្ហានេះ រាជរដ្ឋាភិបាលបានសំរេច ៖

១- យល់ព្រមអនុញ្ញាតជាគោលការណ៍អោយសាលាក្រុងភ្នំពេញបានរៀបចំសម្បទានដីសង្គមកិច្ច ជូនសហគមន៍ក្រីក្រ តាមសំណើដូចតទៅ ៖

១.១-សហគមន៍បូរីកីឡា ស្ថិតនៅសង្កាត់វាលវង់ ខណ្ឌ៧មករា មានផ្ទៃដី ១៤.១២ ហិកតា មានប្រជាពលរដ្ឋស្នាក់នៅបណ្តោះអាសន្នចំនួន ១.៧៧៦ គ្រួសារ មាន ១.៣៧៦ ផ្ទះ មនុស្ស ៩.៩៧៩ នាក់ ផ្តល់នូវសម្បទានដីសង្គមកិច្ច ៣០% លើផ្ទៃដីសរុប ១៤.១២ ហិកតា ស្មើនឹង ៤.៦០ ហិកតា ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន ។

១.២-សហគមន៍ដីក្រហម ស្ថិតនៅក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន មានទីតាំងនៅខាងត្បូងសាលមហោស្រពទន្លេបាសាក់ ជាអតីតសួនសាធារណៈ មានផ្ទៃដីទំហំ ៤.៧០ ហិកតា ផ្ទះ ១.២២០ខ្នង មានប្រជាពលរដ្ឋ ១.៤៦៥ គ្រួសារ មនុស្ស ៥.៨៥៤ នាក់ ផ្តល់នូវសម្បទានដីសង្គមកិច្ចទំហំ ៣.៧០ ហិកតា លើផ្ទៃដីសរុប ៤.៧០ ហិកតា ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន ។

១.៣-សហគមន៍សន្តិភាព(រទេះភ្លើង អា)ស្ថិតនៅក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ មានផ្ទៃដីទំហំ១០.៣២០ម$^2$ មានប្រជាជន ៧០គ្រួសារ មានផ្ទះ ៦០ខ្នង មនុស្សសរុប ៣៩០នាក់ ផ្តល់នូវសម្បទានដីសង្គមកិច្ច ២៥% លើទំហំ១០.៣២០ម$^2$ ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន។

១.៤-សហគមន៍រទេះភ្លើង បេ ស្ថិតនៅក្នុងសង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក មានផ្ទៃដីទំហំ ១០ ហិកតា មានផ្ទះ ២៣៣ ខ្នង ប្រជាជន ២៥៥គ្រួសារ មនុស្ស ១.១២៤ នាក់ ផ្តល់នូវសម្បទានដីសង្គមកិច្ចទំហំ ២.៥០ ហិកតា លើផ្ទៃដីសរុប ១០ហិកតា ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន។

២- សុំប្រកាសជូនសហគមន៍បានជ្រាប ដើម្បីហ្មឹងហ្មាត់អារម្មណ៍ និងជួយការពារកុំឱ្យមានការចាប់ដីបន្ថែម ។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និង ចាត់ចែងអនុវត្តតាមការគួរ ។

សូមឯកឧត្តមទទួលនូវការរាប់អានដ៏ស្មោះរំពីខ្ញុំ ។

ជ.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ស៊ុំ មរិនិត

ចម្លងជូនៈ

ក្រសួងមហាផ្ទៃ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- ក្រសួងសាធារណការ និងដឹកជញ្ជូន

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី

- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

- ឯកសារ-កាលប្បវត្តិ



សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម - ឯកសាររបស់អង្គការ លីកាដូ កាណាដា

**ឧបសម្ព័ន្ធទី២**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*******

សាលាក្រុងភ្នំពេញ
សាលាខណ្ឌចំការមន
លេខ [illegible]/ខណ្ឌ.

ភ្នំពេញ.ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

## របាយការណ៍

ស្តីពីលទ្ធផលនៃការរៀបចំអភិវឌ្ឍន៍ នៅនឹងកន្លែង
របស់ សហគមន៍ ដីក្រហម

========

សហគមន៍ដីក្រហម ស្ថិតនៅក្នុងភូមិ ២ និង ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន បែងចែកជា ៧ សហគមន៍ ។ ក្នុងឱកាសខួប ៥ ឆ្នាំ របស់អង្គការមូលនិធិកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា សហគមន៍ដីក្រហមត្រូវទទួលបាននូវគោលការណ៍ពីសម្តេចនាយករដ្ឋមន្ត្រី អនុញ្ញាតិអោយធ្វើការអភិវឌ្ឍន៍នៅនិងកន្លែង ជាមួយគ្នានេះ ទីស្តីការគណៈរដ្ឋមន្ត្រីក៏ចេញលិខិតលេខ ៨៧៥ ស.ជ.ណ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ ស្តីពីការយល់ព្រមអនុញ្ញាតិជាគោលការណ៍អោយសាលាក្រុងភ្នំពេញ រៀបចំសម្បទានដីសង្គមកិច្ច ជូនសហគមន៍ក្រីក្រ ពាបស់រណើរបស់សហគមន៍ចំនួន ៤ តំបន់ ក្នុង ៤ ខណ្ឌ ក្នុងនោះរួមទាំងសហគមន៍ដីក្រហមផងដែរ ។

ដើម្បីជម្រុញនៃការ អនុវត្តន៍ នូវគោលការណ៍ខាងលើ អោយមានប្រសិទ្ធភាព សាលាក្រុងភ្នំពេញបានចេញលិខិតលេខ ២៥៤ ដ.ត.ស ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មការកណ្តាល អនុវត្តគំរោងសាកល្បង នៅនិងកន្លែង ដោយមានឯកឧត្តម ចេវ គីមហេង អភិបាលរងរាជធានីភ្នំពេញជាប្រធាន ។

ខាងក្រោមនេះគឺជាលទ្ធផលនៃការអនុវត្តរៀបចំអភិវឌ្ឍន៍ នៅ និងកន្លែងរបស់សហគមន៍ដីក្រហម ចាប់ពីបានទទួលគោលការណ៍របស់រាជរដ្ឋាភិបាល ។

I. អំពីការស្រង់ស្ថិតិប្រជាពលរដ្ឋ

-សាលាក្រុងភ្នំពេញបានចេញដីកាលេខ ១៨៨ ដ.ត.ស ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មការចុះស្រង់ស្ថិតិប្រជាពលរដ្ឋ នៅក្នុងសហគមន៍ដីក្រហមដែលរួមមាន លោក អភិបាលខណ្ឌចំការមន ជាប្រធាន លោក អធិការនគរបាលខណ្ឌជាអនុប្រធាន. លោក ប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្មខណ្ឌជាសមាជិកអចិន្ត្រៃយ៍.មន្ត្រីខុទ្ទកាល័យសាលាក្រុងភ្នំពេញ.សង្កាត់ទន្លេបាសាក់ .តំណាងសហគមន៍ដីក្រហមនិង តំណាងគំរោងកាត់បន្ថយភាពក្រីក្រក្រុងភ្នំពេញ ជាសមាជិក គណៈកម្មការនេះបានដំណើរការចុះស្រង់ស្ថិតិចាប់ពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៣ រហូតដល់ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ បានចប់ជាស្ថាពរដូចមានតារាងស្ថិតិខាងក្រោម÷

| ល.រ | ឈ្មោះសហគមន៍ | ចំនួនគ្រួសារសរុប | ចំនួនមនុស្ស | | សរុប | ចំនួនគ្រួសារវៀតណាម | គ្រួសារស៊ុំបំបែក | គ្រួសារជួល.និងសន្សំ | ខ្នងផ្ទះសរុប |
|---|---|---|---|---|---|---|---|---|---|
| | | | ប្រុស | ស្រី | | | | | |
| ១ | បុរី ឱញ្ញាតិរ | ៣០៩ | ៥២៦ | ៧១០ | ១២៣៦ | ២១ | ២៨ | ១៨ | ២៩១ |
| ២ | ព្រះ ភិរុណ | ៣៥៥ | ៦១២ | ៧៣០ | ១៣៤២ | ៣ | ៥០ | ៥៩ | ២៣៦ |
| ៣ | ភូមិ ២ | ២៧០ | ៤៧៨ | ៤៨៣ | ៩៦១ | ០ | ២៩ | ១២ | ២៣០ |
| ៤ | ដីក្រហមA | ២៨៩ | ៥៤៧ | ៦២៤ | ១១៧១ | ១២ | ២៤ | ៤៥ | ២០៩ |
| ៥ | ដីក្រហម ១ | ១១១ | ២១៧ | ២៤២ | ៤៥៩ | ៨ | ០ | ០ | ១១១ |
| ៦ | ដីក្រហម ៤ | ៣៣ | ៦៦ | ៦៧ | ១៣៣ | ០ | ០ | ០ | ៣៣ |
| ៧ | ដីក្រហម ៥ | ៩៨ | ២១៥ | ២៣៣ | ៤៤៨ | ៥ | ៩ | ១៩ | ៧០ |
| | ៧ សហគមន៍ | ១៤៦៥ | ២៦៦១ | ៣០៨៩ | ៥៧៥០ | ៤៩ | ១៤០ | ១៥៣ | ១១៧២ |

សមាជិកសន្សំប្រាក់: ១៣៦៥ គ្រួសារ សរុបទឹកប្រាក់ = ២៩៣.០០០.០០៛០០ ( ម្ភៃប្រាំបួនលានបីសែនរៀលគត់ )

II.សំពីលទ្ធផលនៃការអនុវត្ត

គ.ការរៀបចំប្រជុំផ្សព្វផ្សាយ

-ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៣ ឯកឧត្តម គែប ជុតិមា អភិបាលរាជធានីភ្នំពេញ បានអញ្ជើញបកប្រជុំផ្សព្វផ្សាយ ពីគោលនយោបាយសម្បទានដីសង្គមកិច្ច ជូនដល់សហគមន៍ដីក្រហមទាំង ០៧ សហគមន៍ នៅបរិវេណមហោស្រព ទន្លេបាសាក់ ដោយមានប្រជាពលរដ្ឋចូលរួមស្តាប់ចំនួន ១៣០០ គ្រួសារ ក្នុងនោះការប្រជុំផ្សព្វផ្សាយ ឯកឧត្តម អភិបាល បានជំរាបជូនប្រជាពលរដ្ឋអោយជ្រាបពីគោលការណ៍ដែលបានសំរេចអនុញ្ញាតិ អោយសាលាក្រុងធ្វើការអភិវឌ្ឍន៍ នៅទីកន្លែង សំរាប់ជាប្រយោជន៍របស់ប្រជាពលរដ្ឋទាំង ១៤៦៥ គ្រួសារ លើផ្ទៃដី ០៤ ហិកតា ៧០អា ដែលក្នុងនោះដីនេះត្រូវទុកជូនរដ្ឋវិញចំនួន ០១ ហិកតា ។

-ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៣ តំណាងសហគមន៍ បានចូលរួមសិក្ខាសាលា ស្តីពីយុទ្ធសាស្រ្តឆ្ពោះទៅរកការអភិវឌ្ឍន៍ផែនការចែករំលែកដីធ្លីទៅសាលាក្រុងភ្នំពេញតាមរយៈពេល ០១ថ្ងៃ ។

-ថ្ងៃទី ២៨-២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ប្រជាពលរដ្ឋចំនួន ១៤៦៥ គ្រួសារ បានទៅប្រជុំនៅសាលាក្រុងភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម គែប ជុតិមា អភិបាលរាជធានីភ្នំពេញ ក្នុងការប្រជុំផ្សព្វផ្សាយនេះ ឯកឧត្តម អភិបាល បានសំរេចអោយបង្កើតគណៈកម្មការដេញថ្លៃ វាយតម្លៃ និង ប្រគល់ ទទួលសំណង់អភិវឌ្ឍន៍លំនៅដ្ឋានលើដីក្រហម ដោយមាន ឯកឧត្តម ចេច គឹមឈេង អភិបាលរងរាជធានីភ្នំពេញជាប្រធាន ហើយក៏បានសំរេចអនុញ្ញាតិ អោយចេញសេចក្តីជូនដំណឹង ស្តីពីការដាក់អោយដេញថ្លៃ ការងារអភិវឌ្ឍន៍លំនៅដ្ឋាន នៅលើដីក្រហមផងដែរ ។

-តំណាងសហគមន៍ចំនួន ១៤ នាក់ បានចូលរួមសិក្ខាសាលា ២វគ្គ នៅសាលាបឋមសិក្សាវត្តភ្នំ ស្តីពីផែនការសកម្មភាព អភិវឌ្ឍន៍សហគមន៍ដីក្រហម ។

-ក្រៅពីការប្រជុំផ្សព្វផ្សាយខាងលើ សហគមន៍ទាំង ០៧ ក៏បាន ប្រជុំដល់ប្រជាពលរដ្ឋគ្រប់គ្រួសារទាំងអស់ ដើម្បីសុំយោបល់ថា តើ ការសាងសង់លំនៅដ្ឋានធ្វើតាមរូបភាព សង់ប្រវាស់ ឬ ស្វែងរកឥណទានសាងសង់ ក្នុងនោះ ប្រជាពលរដ្ឋបានឯកភាពគ្នា លើរូបភាពសាងសង់ប្រវាស ដោយស្វែងរកក្រុមហ៊ុនសំរាប់សាងសង់ ។

ខ. អំពីការខារសិក្សា ប្លង់និង ការចាស់ចែងដី

-សហគមន៍ បានសំណូមពរសុំអោយ អង្គការ URC និង អង្គការ ACHR ជួយសិក្សា និង គូប្លង់ ក៏ប៉ុន្តែ មានការលំបាកលើផ្ទៃដីជាក់ស្តែង ហើយក៏បានទំនាក់ទំនង និងសំណូមពរការិយាល័យរៀបចំដែនដីនគរូបនីយកម្មខណ្ឌ ធ្វើការវាស់វែងជាក់ស្តែង ពេលការិយាល័យរៀបចំដែនដីនគរូបនីយកម្មចុះវាស់ ជាក់ស្តែង ដីនេះមានទំហំតែ ០៣ ហិកតា ៦០ អា ទេ គឺខុសពីរបាយការណ៍មុន ០១ ហិកតា ១០ អា ។ ករណីបាត់ដីនេះ សហគមន៍បានរាយការណ៍ ជូនឯកឧត្តមអភិបាលរាជធានីភ្នំពេញ ឯកឧត្តម បានមានប្រសាសន៍ថា: នឹងប្រគល់ដីដែលមានជាក់ស្តែងនេះនៅ សហគមន៍ទាំងអស់ ដោយពុំមានដកទុកជូនរដ្ឋវិញទេ ។

គ. អំពីការស្វែងរកក្រុមហ៊ុនដើម្បីសាងសង់លំនៅដ្ឋាន

-ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៣ សហគមន៍បានធ្វើការចរចារ ជាមួយក្រុមហ៊ុន ដាវន អ៊ីម៉ិច ដោយមាន លោក ស្រី ស៊ុយ សុដាវន ជាប្រធានក្រុមហ៊ុន រហូតដល់ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៤ ការចរចារនេះពុំបាន ឯកភាពគ្នាទេ ដោយក្រុមហ៊ុនទាមទាយកដី ០២ ហិកតា ទុក ០១ ហិកតា ៦០ អា សំរាប់សាងសង់លំនៅដ្ឋាន ឯ សហគមន៍ទាមទាដីស្មើគ្នា គឺក្រុមហ៊ុន ០១ ហិកតា ៨០ អា និង សហគមន៍ ០១ ហិកតា ៨០ អា ។

-ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៤ រហូតដល់ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ សហគមន៍បានចរចារជាមួយ ក្រុមហ៊ុន ម៉ុង រិទ្ធី គ្រុប ដើម្បីធ្វើការសង់ប្រវាស់ពាក់កណ្តាលម្នាក់ ប៉ុន្តែមិនបានឯកភាពគ្នាទេ ។

-ចាប់ពីថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០០៤ មកសហគមន៍បានចរចារដោយផ្ទាល់ជាមួយក្រុមហ៊ុន ទិញ.ឡូវ ក្នុង នោះក្រុមហ៊ុនបានយល់ព្រមធ្វើការសាងសង់លំនៅដ្ឋាន នៅសង្កាត់ចោមចៅ ខណ្ឌដង្កោ ជាថ្នូនិង ដីចំនួន ០៣ ហិកតា ៦០ អា នៅដីក្រហម ការចរចារនេះសំរេចបាន ៩០ ភាគរយហើយ ។ ចំពោះមុខនេះសាលាខណ្ឌ និង រៀបចំការ ប្រជុំរវាងក្រុមហ៊ុន និង សហគមន៍ ដើម្បីធ្វើការចរចារដល់ទីបញ្ចប់ និង សុំពោលការណ៍ដឹកនាំពីសាលាក្រុង ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តមអភិបាលមេត្តាជ្រាបជារបាយការណ៍ និង សុំមតិដឹកនាំបន្ត ដោយអនុគ្រោះ ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

អ្នកសម្របសម្រួលចំការមន

ឡាយ

ចំលងជូន:

-សាលាសង្កាត់ទន្លេបាសាក់
-អង្គការ UN HABITAT
-សហគមន៍ដីក្រហម
-ឯកសារ.កាលប្បវត្តិ

៣៦

**ឧបសម្ព័ន្ធទី៣**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

<u>កិច្ចសន្យាសាងសង់អាគារផ្ទះល្វែងលើទីតាំងថ្មី</u>

រវាងគណកម្មការសហគមន៍ដីក្រហម ជាភាគី "ក" និងលោក ស្រី ចន្ទូ នាយកក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7 NG Construction) ជាភាគី "ខ" ។

ភាគីទាំងពីបានឯកភាព ព្រមព្រៀងគ្នា សាងសង់អាគារស្នាក់នៅជូនប្រជាពលរដ្ឋក្នុងសហគមន៍ដីក្រហមចំនួន <u>១៤៧២</u>ល្វែង ដែលមានទីតាំងស្ថិតនៅភូមិដំណាក់ទ្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានចែងក្នុងលក្ខខណ្ឌដូចខាងក្រោមនេះ :

<u>ប្រការ១:</u> ភាគី "ខ" ត្រូវសាងសង់អាគារចំនួន ១៤៧២ល្វែង គឺត្រូវបានបែងចែកក្នុងលក្ខខណ្ឌដូចខាងក្រោមនេះ :

- អាគារចំនួន ១៤៦៥ល្វែង សំរាប់ធ្វើជាផ្ទះល្វែងរស់នៅអចិន្ត្រៃយ៍របស់ប្រជាពលរដ្ឋចំនួន ១៤៦៥គ្រួសារ
- អាគារចំនួន ០១ល្វែង សំរាប់ធ្វើជាទីស្នាក់ការរបស់សហគមន៍ទាំង ៧
- អាគារចំនួន ០១ល្វែង សំរាប់ធ្វើជាទីស្នាក់ភូមិ
- អាគារចំនួន ០២ល្វែងសំរាប់ធ្វើជាមត្តេយ្យសាលារបស់សហគមន៍ទាំង ៧
- អាគារចំនួន០១ល្វែង សំរាប់ធ្វើជាមណ្ឌលសុខភាពរបស់សហគមន៍ទាំង ៧
- អាគារចំនួន០២ល្វែង សំរាប់ធ្វើជាមណ្ឌលសិប្បកម្មរបស់សហគមន៍ទាំង ៧

<u>ប្រការ២:</u> ចំពោះការសាងសង់អាគារចំនួន ១៤៧២ល្វែងនេះ គឺភាគី "ក" បានសន្យាថា : ចំពោះដីទំហំ ៣ហិកតា ៦០អាពីជាដីសម្បទានសង្គមកិច្ច ដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រគល់អោយសហគមន៍ដីក្រហមទាំង ៧ មានទីតាំងស្ថិតនៅក្នុងភូមិ២ និងភូមិ ១៥ ជាប់ផ្លូវសម្តេច ហេង សំរិន របងទូតសូវៀត សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រគល់អោយក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7NG Construction) ជាថ្នូរប្តូរនិង អាគារសាងសង់ថ្មីទាំងអស់នោះ ។

<u>ប្រការ៣:</u> ភាគី "ខ" ត្រូវសាងសង់អាគារផ្ទះល្វែងទាំង ១៤៧២ល្វែងនេះ សង់អំពីឥដ្ឋ "ថ្ម" ដែលមួយល្វែងមាន ទំហំ ០៤ម ×១០ម កំពស់ ៤,៥០ម៉ែត្រ លើផ្ទៃដីទំហំ ៤៨ម៉ែត្រការ៉េ ដែលមានទទឹង ០៤ម៉ែត្រ និងបណ្តោយ ១២ម៉ែត្រ ចាក់គ្រឹះទុកសំរាប់សាងសង់ជាន់ទី១បាន និងទុកដីសំរាប់ទីធ្លាខាងមុខផ្ទះទំហំ ១៦ម៉ែត្រការ៉េ និងចាក់បេតុងរួចជាស្រេច ។

<u>ប្រការ៤:</u> ចំពោះរចនាបទនិងគ្រឿងបំពាក់របស់ផ្ទះគឺមាន ដំបូលចាក់បេតុងប្លង់សេមួយសន្លឹកទំហំ ៤៧,២០ម៉ែត្រការ៉េ ទុកកន្ទុយដែកសំរាប់សង់ជាន់ទី១ ដោយខ្លួនឯង ទ្វារខាងមុខធ្វើអំពីដែករូត ទ្វារខាងក្រោយធ្វើអំពីដែកប្រអប់ ក្រាលឥដ្ឋការ៉ូចិនលេខ ១ ជញ្ជាំងខាងក្នុងលាបស្តេគ្រូលពណ៌ស ជញ្ជាំងខាងក្រៅលាបកំបោរពណ៌ពងមាន់ ខាងក្រោយផ្ទះសាងសង់បង្គន់និងបន្ទប់ទឹកដែលមានទទឹង ១,៥ម ×២ម បំពាក់ដោយចានបង្គន់ថៃ ០១ អាងទឹក ០១ ក្រាលឥដ្ឋការ៉ូចិនលេខ១ ចំពោះដីទំនេរទំហំ ៥ម៉ែត្រការ៉េ ចាក់បេតុងរួចជាស្រេច ។

<u>ប្រការ៥:</u> ចំពោះបណ្តាញទឹកស្អាត ប្រព័ន្ធបង្ហូរទឹកស្អុយ និងប្រព័ន្ធអគ្គិសនីគឺភាគី "ខ" ត្រូវតបង្កប់នៅក្នុងផ្ទះ រួចជាស្រេច ចំពោះប្រព័ន្ធមេទាំងអស់ត្រូវបានដាក់តភ្ជាប់ដល់ខាងមុខផ្ទះ ដែលអាចប្រើប្រាស់បាន ។

<u>ប្រការ៦:</u> ចំពោះរចនាបទទីតាំងថ្មី ភាគី "ខ" ត្រូវធ្វើប្រព័ន្ធផ្លូវតភ្ជាប់ពីផ្លូវជាតិលេខ៣ មកដល់ទីតាំងថ្មី ចាក់បេតុង និងផ្លូវតភ្ជាប់ពីផ្លូវវេងស្រេងមកទីតាំងថ្មីដោយឈូសសំរួល និងពង្រីកសង់អំពីថ្មគ្រោះក្រហម ចំពោះផ្លូវ ខាងមុខផ្ទះមានទទឹង៦ម៉ែត្រខាងក្រោយ និងចំហៀងអាគារធ្វើច្រកផ្លូវទទឹង ២ម៉ែត្រ ដោយចាក់បេតុងទាំងអស់ មានប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងទឹកស្អុយ មានទីផ្សារសំរាប់លក់ដូរដែលជាកម្មសិទ្ធិរបស់ភាគី "ខ" មាន... របស់ក្រុមហ៊ុនចំនួនពីរជាកម្មសិទ្ធិក្រុមហ៊ុនសំរាប់អោយប្រជាជនមានការងារធ្វើ ហើយនៅ... មានសួនច្បារ មានចំណតរថយន្ត មានទីធ្លាលំហែរ មានបង្គោលភ្លើងបំភ្លឺ ។

<u>ប្រការ៧:</u> ចំពោះការសាងសង់អាគារត្រូវតែអោយបានខ្ពស់ជាងផ្លូវ គុណភាពគឺត្រូវបានធានាត្រឹមត្រូវ... គំរោងប្លង់សាងសង់ត្រូវមានការទទួលស្គាល់ពីមន្ទីរ និងក្រសួងដែនដីនគរូបនីយកម្ម សំណង់ ...

រៀបចំអោយមានកិច្ចសន្យាសាងសង់ និង សៀវភៅបន្ទុកសំរាប់អនុវត្តយ៉ាងត្រឹមត្រូវ និងត្រូវបានអនុញ្ញាតិអោយ មានការចូលរួមត្រួតពិនិត្យពីក្រុមអ្នកបច្ចេកទេសរបស់ក្រសួងជំនាញ និង អង្គការដែលពាក់ព័ន្ធ និងសហគមន៍ ។

ប្រការ៨: ភាគីទាំងពីរបានឯកភាពគ្នាថា: នៅពេលដែលភាគី "ខ" សាងសង់ផ្ទះបាន ២០០-៣០០ល្វែង យ៉ាងតិច គឺភាគី "ក" ត្រូវធ្វើ ការផ្លាស់ប្តូររុះរើផ្ទះពីទីតាំងចាស់ទៅនៅទីតាំងថ្មីម្តង ចំពោះការដឹកជញ្ជូនផ្ទះភាគី "ក" ជាអ្នកដោះស្រាយ ដោយ ខ្លួនឯង *ប៉ុន្តែការចូលរស់នៅក្នុងផ្ទះល្វែងថ្មីនេះ ពុំមានការបង់ប្រាក់អ្វីឡើយ* ។

ប្រការ៩: នៅគ្រប់ប្រការទាំង ៨ខាងលើ ភាគីទាំងពីរត្រូវអនុវត្ត និងគោរពអោយបានត្រឹមត្រូវតាមកិច្ចសន្យានេះ បើភាគីណាមួយមិនអនុវត្តតាមលក្ខខណ្ឌក្នុងកិច្ចសន្យានេះទេ និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ក្រែងពុំពិតប្រាកដយើងខ្ញុំសូមផ្តិតមេដៃស្តាំទុកជាភស្តុតាង ទៅថ្ងៃក្រោយ ។

ធ្វើនៅថ្ងៃទី១៣......ខែ០១.....ឆ្នាំ ២០០៥

ស្នាមមេដៃស្តាំភាគី "ក"

គណៈកម្មការសហគមន៍ដីក្រហមឆ្នាំ ៧

| ល.រ | នាម_គោត្តនាម | ល.រ | នាម_គោត្តនាម | ល.រ | នាម_គោត្តនាម | ល.រ | នាម_គោត្តនាម |
|---|---|---|---|---|---|---|---|
| ១ | គីម យ៉ាន | ១០ | សួន ឡើ | ១៩ | ឡាច គីមហ៊ួ | ២៨ | នូ ពៅ |
| ២ | ប៉ែន សុធី | ១១ | អ៊ុច សារ៉េឿន | ២០ | រិត ណារី | ២៩ | យេ សារិន |
| ៣ | សម្ម សារ៉ុត | ១២ | ស៊ីន យ៉ិក | ២១ | ពុក សុធា | ៣០ | អ៊ឺ យ៉ន |
| ៤ | អ៊ុ ណារិទ្ធស៊្រុន | ១៣ | ជួន ឌី | ២២ | សួន ឆេងរី | ៣១ | គីម ហ៊ួ |
| ៥ | លី ចាន់ភក្តី | ១៤ | ស៊ឹម ស៊ី | ២៣ | សួស សារ៉េត | ៣២ | ភេង សុផាត |
| ៦ | ផាន់ ណារិន | ១៥ | ស៊ីន សុខហេង | ២៤ | គង់ ស៊ី | ៣៣ | ញៀម យុគ្គានី |
| ៧ | ពុំ សុខអេង | ១៦ | ស៊ីក សុខ | ២៥ | សួន សឿប | ៣៤ | ញ៉េប សុទ្ធាណ្ណា |
| ៨ | ជួប លួន | ១៧ | ណា ហ៊ាង | ២៦ | ម៉ែន សុខ | ៣៥ | ព្រុំ ចាន់ថុល |
| ៩ | ជា ចលរុ | ១៨ | ហែម សារ៉ុំ | ២៧ | ម៉ម ញ៉ៀន | ៣៦ | ព្រុំ |



សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម - ឯកសាររបស់អង្គការ លីកាដូ កាណាដា

ស្នាមមេដៃ ឬ ហត្ថលេខាភាគី "ខ"

ថ្ងៃទី.១៦.......ខែ.មករា..ឆ្នាំ ២០០៥

នាយកក្រុមហ៊ុន 7NG Construction )

សាក្សីដឹងឮ

ស្រី_ចន្ទូ

ថ្ងៃទី១៦ ខែ០១ ឆ្នាំ២០០៥

ប្រធានភូមិ ២

ឆេង_ទីមុល

ថ្ងៃទី១៦ ខែ០១ ឆ្នាំ២០០៥

(ប្រធានភូមិ ១៥

អៀម_អឿន

16/01/2005

តំណាងសម្ព័ន្ធខណ្ឌចំការមន

១៦/០១.២០០៥

តំណាងអង្គការ SUPF

ម៉ែង ចំណាន

លេខ.១៣០៧/០៥ ~ ៤

បានឃើញ និងបញ្ជាក់ថា

ភាគីទាំងពីរបានឯកភាពគ្នាហើយ

ធ្វើកិច្ចសន្យាដោយផ្តិតមេដៃស្តាំ និងចុះហត្ថលេខា

នៅចំពោះមុខយើងប្រាកដមែន ។

ភ្នំពេញ.ថ្ងៃទី....១៧.....ខែ..មករា..ឆ្នាំ ២០០៥

ចៅសង្កាត់ទន្លេបាសាក់

ងា_សុវណ្ណ

**ឧបសម្ព័ន្ធទី៤**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

យើងខ្ញុំជាតំណាងឱ្យប្រជាពលរដ្ឋចំនួន ៨០៤ គ្រួសារ ដែលរស់នៅភូមិ ០២ និង ភូមិ ១៥ ក្នុងសហគមន៍ដីក្រហម ទាំង ៧ សង្កាត់ ទន្លេបាសាក់ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ។

## សូមគោរពជូន

## ឯកឧត្តម ហួរ ម៉ាន់ អ្នកតំណាងរាស្ត្រមណ្ឌលភ្នំពេញ

កម្មវត្ថុ : សុំជួយធ្វើអន្តរាគមន៍លើពាក្យបណ្តឹងដែលបានដាក់ជូនទៅសាលាក្រុងភ្នំពេញ

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំទាំងអស់គ្នាសូមជម្រាបឯកឧត្តមមេត្តាជ្រាប : កាលពីថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០៥ យើងខ្ញុំបានយកពាក្យបណ្តឹងទៅដាក់នៅសាលាក្រុងភ្នំពេញ ដោយមានស្នាមមេដៃប្រជាពលរដ្ឋគាំទ្រចំនួន ៨០៤ គ្រួសារ ដែលសុំប្តឹងបដិសេធកិច្ចសន្យារវាងគណៈកម្មាធិការសហគមន៍ដីក្រហមទាំង ៧ ជាមួយនឹងក្រុមហ៊ុន សេវ៉ែនអ៊ិនជី (7NG Construction) ដែលបានធ្វើកិច្ចព្រមព្រៀងដោយមិនពិគ្រោះយោបល់ពីសមាជិកលើទីតាំងថ្មី ដែលស្ថិតនៅឆ្ងាយពីទីក្រុង ។

រហូតដល់ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ទើបខាងសាលាខណ្ឌចំការមន ធ្វើការកោះអញ្ជើញអ្នកតំណាងទាំង ២៣ នាក់ឱ្យមកធ្វើការប្រជុំដើម្បីដោះស្រាយពីបញ្ហានេះ ។ ប៉ុន្តែនៅមុនពេលប្រជុំ មានបាតុភាពមិនប្រក្រតីមួយចំនួនបានកើតឡើងគឺ ខាងសាលាខ័ណ្ឌ មិនអនុញ្ញាតឱ្យប្រជាពលរដ្ឋក្នុងសហគមន៍ដែលមានបំណងចង់ចូលរួមស្តាប់នោះ ចូលរួមស្តាប់ឡើយ មិនតែប៉ុណ្ណោះ អ្នកសារពត៌ បុគ្គលអង្គការក្រៅរដ្ឋាភិបាល ក៏មិនត្រូវបានអនុញ្ញាតឱ្យចូលរួមស្តាប់អង្គប្រជុំដែរ ។ នៅពេលប្រជុំដែលមានរយៈពេលមិនដល់កន្លះម៉ោងផងនោះ ដែលមានការចូលរួមពីតំណាងខណ្ឌ តំណាងសង្កាត់ តំណាងសហគមន៍ តំណាងសម្ព័ន្ធខណ្ឌ (SUPPF) មេភូមិ និងអ្នកតំណាងទាំង ២៣ នាក់ផងនោះ គឺរបៀបវារៈរបស់ខ័ណ្ឌ គឺមានតែបញ្ហាស្នាមមេដៃពិត ឬ ក្លែងបន្លំ ហើយខាងខ័ណ្ឌនឹងចាត់ឱ្យមានគណៈកម្មការមួយដើរត្រួតពិនិត្យស្នាមមេដៃនោះតាមផ្ទះ ។ ខាងសាលាខ័ណ្ឌបានបង្ហើបឱ្យដឹងផងដែរថា ស្នាមមេដៃខាងសហគមន៍នោះគឺមានរហូតដល់ទៅជាង ១០០០ គ្រួសារហើយ ។

រីឯសំណូមពរ ដែលអ្នកតំណាងរបស់យើងបានលើកឡើង សូមឱ្យផ្អាកកិច្ចសន្យាសាងសង់នោះមួយរយៈសិនទម្រាំដោះស្រាយរឿងមេដៃរួច ហើយសូមកុំឱ្យខាងក្រុមហ៊ុន ឬ ខាងសហគមន៍លើកផ្លាកផ្សេងៗដែលអាចធ្វើឱ្យប្រជាជនមានការភ្ញាក់ផ្អើលនោះ ក៏ខាងសាលាខ័ណ្ឌមិនទាន់ឆ្លើយជាមួយយើងដែរ ដោយនិយាយថា ចាំឆ្លងយោបល់ពីលោកអភិបាល

ខ័ណ្ឌ សិន ។ ប៉ុន្តែនៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥ នេះ មានដំណឹងលេចលឺថា ខាងសហគមន៍នឹងលើកផ្លាក សាជាថ្មីម្តងទៀត ។

តាមរយៈការដោះស្រាយកន្លងមកនេះ បានធ្វើឱ្យប្រជាពលរដ្ឋយើងកាន់តែគ្មានជំនឿទៅលើអ្វីដែលអាជ្ញាធរបាន ដំណោះស្រាយឱ្យ ពិព្រោះសកម្មភាពនៅតែកើតមាន ហើយការអូសបន្លាយពេលវេលានៅតែបន្ត ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជួយធ្វើអន្តរគមន៍យ៉ាងណាដើម្បីបញ្ឈប់ការអនុវត្តន៍កិច្ចសន្យារវាងសហ គមន៍ និង ក្រុមហ៊ុន សេវ៉ែនអ៊ិនជី **(7NG Construction)** ដើម្បីឱ្យប្រជាពលរដ្ឋអាចបន្តរស់នៅលើទីតាំងចាស់ទម្រាំ អាចស្វែងរកដៃគូក្រុមហ៊ុនថ្មី ដែលប្រជាពលរដ្ឋអាចទទួលយកបានទាំងអស់គ្នា ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំទាំងអស់គ្នា ។

ភ្ជាប់មកជាមួយនូវ

- ស្នាមមេដៃចតចំលងរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ដីក្រហមទាំង ៧ (ភូមិ ០២ និង ភូមិ ១៥) ចំនួន ៨០៤ គ្រួសារ
- ឈ្មោះអ្នកតំណាង ២៣ រូប ដែលគាំទ្រដោយប្រជាពលរដ្ឋទាំង ៨០៤ គ្រួសារ
- កិច្ចសន្យាសាងសង់អាគារផ្ទះល្វែងលើទីតាំងថ្មី ១ ច្បាប់
- ពាក្យបណ្តឹង ១ ច្បាប់

ភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥

តំណាងប្រជាពលរដ្ឋទាំង ៨០៤ គ្រួសារ

**ឡោ សីហា**

**ឧបសម្ព័ន្ធទី៥**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខណ្ឌចំការមន

សាលាសង្កាត់ទន្លេបាសាក់

ភ្នំពេញ.ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៥

លេខ ០០៧ .ស.ជ.ណ

# សេចក្តីជូនដំណឹង

## សាលាសង្កាត់ទន្លេបាសាក់

## សូមជូនដំណឹង

ដល់បងប្អូនប្រជាជនភូមិ១៥ ( តំបន់ដីក្រហមទាំង ៧សហគមន៍ ) អោយបានជ្រាបថា :

កន្លងមកសភាពការណ៍ជាក់ស្តែងចំពោះមុខ ដែលស្របពេលកំពុងអភិវឌ្ឍន៍ទីតាំងថ្មីខាងលើ បានលេចចេញនូវភាពឥតសណ្តាប់ធ្នាប់ ក្នុងការផ្លាស់ប្តូរឈ្មោះ ការលក់ដូរ ការធ្វើអំណោយ ការស្នាក់នៅឥតច្បាប់ ។ល។ សាលាសង្កាត់ទន្លេបាសាក់ ពុំទទួលខុសត្រូវ រាល់ទង្វើនេះទេ គឺ ទទួលស្គាល់តែឈ្មោះក្នុងបញ្ជីរបស់គណៈកម្មការចំរុះថ្នាក់ខណ្ឌ បានចុះត្រួតពិនិត្យជាក់ស្តែងជាស្ថាពររួចរាល់ហើយ ។

បើជនណាប្រព្រឹត្តផ្ទុយពីសេចក្តីជូនដំណឹងនេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ជាធរមាន ។

សាលាសង្កាត់ទន្លេបាសាក់ មានសង្ឃឹមជឿជាក់យ៉ាងមុតមាំថា លោក-លោកស្រី និងអនុវត្តន៍ តាមខ្លឹមសារនៃសេចក្តីជូនដំណឹង នេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

<u>ចម្លងជូន</u>

- សាលាខណ្ឌចំការមន
- អធិការដ្ឋានខណ្ឌចំការមន
- កងរាជអាវុធហត្ថខណ្ឌចំការមន

} ដើម្បីជូនជ្រាប

- នគរបាលប៉ុស្តិ៍
- ប្រធានភូមិ២និងភូមិ១៥
- សហគមន៍ដីក្រហមទាំង៧

} ដើម្បីអនុវត្តន៍

- ឯកសារកាលប្បវត្តិ

ចៅសង្កាត់ទន្លេបាសាក់



សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម – ឯកសាររបស់អង្គការ លីកាដូ កាណាដា

**ឧបសម្ព័ន្ធទី៦**

ជំនួយ ផ្នែកច្បាប់ នៃកម្ពុជា

**Legal Aid of Cambodia**

N°.43, ST.306, P.O.Box: 1197, Sangkat Boeung Kengkang I, Cham Karmorn, Phnom Penh, Cambodia
Tel: (855-23) 215-274 / 360-708 / 214 824, Fax: (855-23, 212-206, Email: lac@bigpond.com.kh

LAC Offices in CAMBODIA:

**Phnom Penh:** N°. 43, St. 306, P.O.Box: 1197, Sangkat Boeung Kengkang I, Khan Cham Karmorn, Phnom Penh. Tel: 023 215 274, 023 360 708

**Battambang:** N°. 48, Group 2, ...mchek 4 Village, ...tatanak Commune, Battambang District, Battambang. Tel: 053 370 027

**Kampong Cham:** N°. 404, Group 3, Village 15, Kg.Cham District. Tel: 042 941 271

**Kandal:** N°. 23, St.108, Khum Takmao, Srok Takmao, Kandal. Tel: 023 360 752

**Koh Kong:** Group 1, Phum 2, Smach Meanchey District, Koh Kong. Tel: 035 936 052

**Kratie:** N°. 588, St. Samdack Sihanouk, Vatt Village, Kratie Commune, Kratie District. Tel: 072 971 471

**Siem Reap:** N°. 0316, Vatt Bo, Siem Reap Dist. Siem Reap. Tel: 063 380 026

**Sihanouk Ville:** N°. 94, Group 1, Center 1, Sangkat II, Khan Mittapheap, Kampong Som. Tel: 034 320 142

**Svay Rieng:** Mephleung Village, Svay Rieng Commune, Svay Rieng District. Tel: 044 945 716

ខ្ញុំបាទឈ្មោះ ជីន ម៊ុនថន មេធាវីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា អាសយដ្ឋានផ្ទះលេខ ៤៣ ផ្លូវ ៣០៦ សង្កាត់បឹងកេងកង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

សូមគោរពជូនចំពោះ

ឯកឧត្តម អភិបាលរាជធានីភ្នំពេញ

*សូមទានជ្រាប ។*

កម្មវត្ថុ : សំណើសុំជួយធ្វើអន្តរាគមន៍ដល់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងភូមិ ២ និងភូមិ ១៥ សង្កាត់ទន្លេបាសាក់ ដែលត្រូវបានប្រធានសហគមន៍ចាស់ទាំង ៣៦រូប មានឧបាយកលដេញប្រជាពលរដ្ឋឱ្យទៅរស់នៅភូមិថ្មីដំណាក់ត្រយឹង សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ ។

យោង :
- លិខិតលេខ ៨៧៥ សជណ.ចុះថ្ងៃទី ៨ កក្កដា ២០០៣ ត្រង់ចំណុច ១.២
- របាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំអភិវឌ្ឍន៍នៅនឹងកន្លែងរបស់សហគមន៍ដីក្រហម លេខ ៣៧០/០៥ រមក.ចុះថ្ងៃទី ៣០/០៩/០៤
- កិច្ចសន្យា[illegible]ផ្ទះល្វែងលើទី[illegible]៣/០១/០៥

តបតាមកម្មវត្ថុ និង យោង ខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបឯកឧត្តមថា : ប្រជាពលរដ្ឋដែលកំពុងរស់នៅភូមិ ២ និង ភូមិ ១៥ ដែលជាសហគមន៍ដីក្រហម មានការព្រួយបារម្ភយ៉ាងខ្លាំង ដោយសារតែលោកប្រធាន និង សមាជិកសហគមន៍ចាស់ ៣៦ រូប បានឃុបឃិតលួចចុះកិច្ចសន្យាសាងសង់ផ្ទះថ្មីនៅតំបន់ឆ្ងាយ សំរាប់ផ្តល់ឱ្យប្រជាពលរដ្ឋនៅសហគមន៍ដីក្រហមរស់នៅ ។ ប្រជាពលរដ្ឋទាំងនោះបានដឹងច្បាស់ថា : សម្តេចនាយករដ្ឋមន្ត្រី បានសំរេចឱ្យពួកគាត់ធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង ជាមួយនោះ សាលាក្រុងភ្នំពេញ ក៏បានចេញលិខិតលេខ ២៥៤ ជ.ត.ស ចុះថ្ងៃទី ២៧/១១/០៣ ស្តីពីការបង្កើតគណៈកម្មការកណ្តាលអនុវត្តគំរោងសាកល្បង. បង្កើតគណៈកម្មការស្រង់ស្ថិតិ និង មានការចុះវាស់វែងជាក់ស្តែងនូវផ្ទៃដីដែលនឹងត្រូវអភិវឌ្ឍន៍ទៀតផង ។

ឯកឧត្តមជាទីគោរព នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៥ ប្រធានសហគមន៍ដីក្រហមទាំង ៧ បានលួចចុះកិច្ចសន្យាជាមួយនឹងក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7NG Construction) ដោយពុំបាន

មេធាវី បំរើជនក្រីក្រកម្ពុជា ដោយឥតគិតថ្លៃ

LAWYERS SERVING CAMBODIA'S POOR

ឱ្យដំណឹងដល់ប្រជាពលរដ្ឋឡើយ ជាហេតុធ្វើឱ្យប្រជាពលរដ្ឋមានការខកចិត្តទៅនឹងទង្វើរបស់ប្រធានសហគមន៍ទាំង ៧ នឹងបានធ្វើការបដិសេធមិនទទួលស្គាល់ចាប់ពីថ្ងៃបានឃើញកិច្ចសន្យានេះមក ពិព្រោះអ្នកទាំង ៣៦ រូបនេះពុំមានការស្មោះត្រង់ចំពោះសមាជិករបស់ខ្លួនឡើយ ។

ផ្អែកតាមចំណុច ១.២ នៃលិខិតលេខ ៨៧៥ សជណ.របស់ទីស្តីការគណៈរដ្ឋមន្ត្រី បានចែងយ៉ាងច្បាស់ថា : "ផ្តល់នូវសម្បទានដីសង្គមកិច្ចទំហំ ៣.៧០ ហិកតា លើផ្ទៃដីសរុប ៤.៧០ ហិកតា ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន ។" ចុះហេតុដូចម្តេច បានជាប្រធានសហគមន៍ដីក្រហមទាំង ៧ មិនព្រមគោរពតាមខ្លឹមសារលិខិតនេះសោះ មិនតែប៉ុណ្ណោះ បែរជានាំគ្នាឃុបឃិតចុះកិច្ចសន្យាផ្ទុយពីនេះទៅវិញ ហើយដែលធ្វើឱ្យប្រជាពលរដ្ឋទាំង ២ ភូមិមានការភ្ញាក់ផ្អើល និងធ្វើការប្រឆាំងតវ៉ាជាមួយប្រធានសហគមន៍ទាំង៧ នេះជាបន្តបន្ទាប់ និងប្តេជ្ញាមិនព្រមទៅរស់នៅទីកន្លែងថ្មីដែលឆ្ងាយពីទីប្រជុំជន ដែលធ្វើឱ្យពួកគាត់ជួបការលំបាកក្នុងការប្រកបមុខរបរប្រចាំជីវិត ។

ជាមួយគ្នានេះដែរ រាល់សំណើសុំរបស់ប្រជាពលរដ្ឋកន្លងមកដែលដាក់ជូនទៅសាលាក្រុងដើម្បីជួយដោះស្រាយនោះ ពុំដែលបានឃើញចំលើយតបអ្វីសូម្បីបន្តិចឡើយ ហើយរឹងរឹតតែបានដៃមកលើប្រធានសហគមន៍ ដើរបំផិតបំភ័យប្រជាពលរដ្ឋឱ្យបាក់បបខ្លបខ្លាចថែមទៀត។ នៅពេលថ្មីៗនេះ ក្រោយពីសាលាក្រុងភ្នំពេញបានអញ្ជើញប្រធានសហគមន៍ទៅប្រជុំកាលពីថ្ងៃទី ០៩ ឧសភា ប្រធានសហគមន៍ បានមកបំភ័យប្រជាពលរដ្ឋជាថ្មីមកទៀត ដោយនិយាយថា "សាលាក្រុងបានយល់ព្រមហើយ ចំពោះអ្នកដែលប្រឆាំងចាំមើលសាលាក្រុងនឹងមានវិធានការយ៉ាងណានោះចាំតែមើលទៅ" ។

អាស្រ័យដូចបានជំរាបជូនខាងលើ ឯកឧត្តមមេត្តាពិនិត្យ និង ជួយធ្វើអន្តរាគមន៍ដល់ប្រជាពលរដ្ឋទាំងនោះ តាមសំណើសុំដោយអនុគ្រោះ និង សូមឯកឧត្តមមេត្តាជួយបង្កើតឱ្យមានវេទិការជាសាធារណៈសំរាប់ប្រជាពលរដ្ឋ ដើម្បីបានសម្តែងមតិផ្ទាល់ខ្លួន ជៀសវាងស្តាប់តែមតិម្ខាងៗ ។

សូមឯកឧត្តមមេត្តាទទួលការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

ភ្នំពេញ ថ្ងៃទី 14 ខែ ឧសភា ឆ្នាំ ២០០៥

អគ្គលេខា

17.5.2005

AVOCAT ATTORNEY AT LAW
KINGDOM OF CAMBODIA

មេធាវី.ជិន.ប៊ុនថន

**ឧបសម្ព័ន្ធទី៧**

## របាយការណ៍សកម្មភាពរបស់មេសហគមន៍ មេភូមិ ចៅសង្កាត់ សាលាខណ្ឌ និង សាលាក្រុងភ្នំពេញ មកលើប្រជាពលរដ្ឋ

យើងខ្ញុំជាតំណាងប្រជាពលរដ្ឋ សូមជម្រាបឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មេត្តាជ្រាប : កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៣ រាជរដ្ឋាភិបាលបានធ្វើសម្បទានដីសង្គមកិច្ច តាមចំណារ របស់សម្តេចនាយកចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៣ ដល់សហគមន៍ដីក្រហម ស្ថិតនៅ ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន មានទីតាំងនៅខាងត្បូងសាលមហោស្រពទន្លេបាសាក់ ជាអតីតសួនសាធារណៈ ទំហំ ៣.៧០ ហិកតា លើផ្ទៃដីសរុបទំហំ ៤.៧០ហិកតា ដល់ប្រជាពលរដ្ឋ ១.៤៦៥ គ្រួសារ ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន ។

នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ តំណាងសហគមន៍ដីក្រហមទាំង៧ ដែលមានសមាជិកទាំង៣៦ រូប បានចុះកិច្ចសន្យាមួយដើម្បីធ្វើការដោះដូរលំនៅដ្ឋានជាមួយនឹងក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7NG Construction) លើទីតាំងថ្មីដែលស្ថិតនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយពុំបានពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ឡើយ ។ លុះដល់រសៀលថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥ ទើបចៅសង្កាត់ មេភូមិ ២ មេភូមិ ១៥ ព្រមទាំងតំណាងសហគមន៍ បានប្រាប់ប្រជាពលរដ្ឋឱ្យមកប្រជុំនៅសាលមហោស្រពទន្លេបាសាក់ ដើម្បីប្រាប់អំពីរឿងដោះដូរលំនៅដ្ឋាននេះ ។ នៅពេលនោះ លោកចៅសង្កាត់ និងប្រធានសហគមន៍បាននិយាយថា មានក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7NG Construction) គេចង់មកដូរដីយើង ដោយគេធ្វើផ្ទះទទឹង ៤ ម៉ែត្រ និង បណ្តោយ ១០ ម៉ែត្រ ចាក់បូងសេ និង ទុកដែកបណ្តុះឱ្យសង់ដល់ជាន់ទី ១ បានទៀត (ក្រុមហ៊ុនសាងសង់ឱ្យតែផ្ទះជាន់ផ្ទាល់ដីទេ) ហើយសម្តីលោកចៅសង្កាត់បានបញ្ជាក់ថែមទៀតថា ការនេះគ្មានអ្នកណាបង្ខំឡើយ បើបងប្អូនចង់ទៅ ផ្តិតមេដៃក្នុងកិច្ចសន្យាយល់ព្រម បើមិនទៅទេគ្មានអ្នកណាបង្ខំឡើយ ។ ចាប់តាំងពីថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ រហូតដល់ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៥ យើងខ្ញុំ តែងតែឮពាក្យចចាមអារាមពីសំណាក់បងប្អូនជាច្រើន ដែលនិយាយពីប្រធានសហគមន៍ដែលតែងតែលើកឡើងថា :

- អ្នកណាផ្តិតមេដៃបានមុនបានផ្ទះនៅមុខ អ្នកណាផ្តិតមេដៃក្រោយបានផ្ទះនៅក្រោយ ហើយអ្នកណាមិនផ្តិតទេ សហគមន៍មិនទទួលខុសត្រូវក្នុងការបានផ្ទះថ្មីឡើយ ។
- ការផ្តិតមេដៃនេះមានរយៈពេលកំណត់មិនយូរទេ
- អ្នកដែលប្រឆាំង ចាំមើលមិនរួចពីការឆេះផ្ទះទេ
- បើមិនដូច្នេះ ដល់ថ្ងៃកំណត់គេពង្វ័របងឱ្យនៅក្នុងនោះ ចង់ចេញចូលទាល់តែបើកយន្តហោះ ព្រោះគេបានផ្តាច់ទាំងទឹក ទាំងភ្លើង ។
- មិនបាច់តវ៉ាទេ ព្រោះពួកគេមានខ្នងនៅពីក្រោយតាំងពីភូមិ សង្កាត់ ខណ្ឌ សាលាក្រុងភ្នំពេញ និង សម្តេច ហ៊ុន សែន ហើយ ធ្វើមិនឈ្នះគេទេ នេះជាបញ្ជាថ្នាក់លើ ។

ប្រជាពលរដ្ឋភាគច្រើន បានត្អូញត្អែរយ៉ាងខ្លាំង ចំពោះការដោះដូរលំនៅដ្ឋានថ្មីនេះ ព្រោះវាស្ថិតនៅឆ្ងាយពីទីប្រជុំជនពេក ដែលធ្វើឱ្យពួកគាត់មិនមានលទ្ធភាពធ្វើដំណើរមកប្រកបរបរចិញ្ចឹមជីវិត ព្រោះពួកគាត់ភាគច្រើនជា

- ជនពិការ ហើយជាអ្នកសុំទាន

- ជាស្ត្រីមេម៉ាយដែលលក់គ្រាប់ឪឡឹក គ្រាប់ស្កូវ លក់ទឹកសុទ្ធ លក់នំបញ្ចុក លក់អំពៅសាង ... លើសួនច្បារសាធារណៈ និងមាត់ទន្លេមុខវាំង

- ចំណែកបុរសវិញ ជាកម្មករសំណង់ អ្នករត់ម៉ូតូឌុប ... ។ល។

ដោយបានឮពាក្យទាំងនេះ និងការភិតភ័យពីប្រជាពលរដ្ឋផងនោះ ទើប យើងខ្ញុំបានផ្តល់ជាយោបល់ដល់បងប្អូនថា : បើអ្នកណាមានចិត្តមិនចង់ទៅរស់នៅលើទីតាំងថ្មីដែលក្រុមហ៊ុនបំរុងនឹងសាងសង់ឱ្យទេ សូមផ្តិតមេដៃមក ដើម្បីយើងខ្ញុំអាចយកទៅដាក់នៅភូមិ សាលាសង្កាត់ សាលាខណ្ឌ និងសាលាក្រុង ដើម្បីឱ្យអាជ្ញាធរជួយដោះស្រាយឱ្យ ។ នៅពេលដែលបងប្អូននាំគ្នាផ្តិតមេដៃបានប្រហែលជា ៩០ គ្រួសារ ស្រាប់តែមានសន្តិសុខភូមិ១៥ ចំនួន ៣ នាក់ មកឃាត់ខ្លួនលោក **ឡោ ស៊ីហា** ទៅស្នាក់ការភូមិ ១៥ អស់រយៈពេល ៣ ម៉ោង តាំងពីម៉ោង ១១:៣០ នាទី រហូតដល់ម៉ោង ២:៣០ នាទី រសៀល ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៥ ។ លុះដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ ២០០៥ ប្រជាពលរដ្ឋបានទៅសាលាសង្កាត់ទន្លេបាសាក់ ដើម្បីសុំឱ្យលោកចៅសង្កាត់ជួយដោះស្រាយ កុំឱ្យមានការគំរាមកំហែងពីសំណាក់មេភូមិ និងសហគមន៍ទាំងនោះទៀត និង សូមឱ្យពួកយើងខ្ញុំជាតំណាង មានសិទ្ធិក្នុងការដើរផ្តិតមេដៃពីសំណាក់បងប្អូនដែលមិនសុខចិត្តទៅរស់នៅកន្លែងថ្មី ។ ពេលនោះ សមាជិកក្រុមប្រឹក្សាសង្កាត់ក៏បានឯកភាពតាមការស្នើសុំ និងមានការដឹងឮពីសំណាក់មេភូមិ ១៥ ដែលនៅទីនោះផងដែរ ។ ដល់ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ សន្តិសុខភូមិ ១៥ បានចាប់ខ្លួនលោក **ហែម ឡាយ** មកដាក់ស្នាក់ការភូមិ១៥ ទៀត នៅខណៈពេលដែលរូបគាត់បានដើរឱ្យប្រជាពលរដ្ឋផ្តិតមេដៃ ។ ពេលនោះ ប្រជាពលរដ្ឋប្រហែលជា ១៥០ នាក់បានមកដល់ស្នាក់ការភូមិ១៥ ស្រែកនិយាយគាំទ្រលោក **ហែម ឡាយ** ទើបគេបើកទ្វារឱ្យរូបគាត់ចេញមកវិញ ។ ដោយសារតែមានសកម្មភាពនៃការតវ៉ានេះកាន់តែរីកធំឡើងៗ ទើបមានអ្នកកាសែតចុះមកសំភាសន៍ផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋ និង មានការសំភាសន៍ពីអង្គការសិទ្ធិមនុស្សកម្ពុជា របស់លោក កឹម សុខា ផងដែរ ។ នៅថ្ងៃនោះដែរ យើងខ្ញុំបានទទួលនូវលិខិតកិច្ចសន្យារវាងសហគមន៍ដីក្រហមទាំង ៧ ដែលមានសមាជិកទាំង ៣៦ រូប បានចុះកិច្ចសន្យាជាមួយនឹងក្រុមហ៊ុនសេវែនអ៊ិនជី **(7NG Construction)** ដោយមានប្រថាប់ត្រាបញ្ជាក់ពីលោកចៅសង្កាត់ផងដែរនោះ ពីមនុស្សម្នាក់ដែល យើងខ្ញុំមិនបានស្គាល់ឈ្មោះ ។ តាមខ្លឹមសារដែលមានចែងនៅក្នុងកិច្ចសន្យា គឺវាខុសគ្នាទាំងស្រុងទៅនឹងអ្វីដែលលោកចៅសង្កាត់ និង តំណាងសហគមន៍បានលើកឡើងនៅក្នុងអង្គប្រជុំកាលពីថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥ ព្រោះនៅពេលនោះពួកគាត់បាននិយាយថា អ្នកណាចង់ទៅក៏ទៅៗ ហើយអ្នកណាមិនចង់ទៅទេក៏អត់ទៅ ប៉ុន្តែខ្លឹមសារនៅក្នុងកិច្ចសន្យា គឺជាកិច្ចសន្យា

ដែលសហគមន៍បានចុះ ដោយសន្យាថានឹងដូរដីទាំងអស់ទៅឱ្យក្រុមហ៊ុន មិនមែនតាមការចង់ដូររបស់ប្រជាជនឡើយ ។

ក្រោយពី យើងខ្ញុំទទួលបាននូវស្នាមមេដៃរបស់ប្រជាពលរដ្ឋចំនួន ៨០៤ គ្រួសារ ដែលមិនយល់ព្រមធ្វើការដោះដូរជាមួយនឹងក្រុមហ៊ុនសេវែនអ៊ិនជី (7NG Construction) ហើយ យើងខ្ញុំក៏បានធ្វើជាពាក្យបណ្ដឹងមួយដាក់ជូនទៅសាលាក្រុងភ្នំពេញ ដោយមានការចំលងជូនទៅសាលាខណ្ឌចំការមន សាលាសង្កាត់ទន្លេបាសាក់ មេភូមិ ២ និង មេភូមិ ១៥ នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០៥ ដោយមានតំណាងចំនួន ២៣ រូប ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ចជួយធ្វើការដោះស្រាយបញ្ហា ដែលមិនចុះសំរុងគ្នាជាមួយនឹងសហគមន៍នេះ។ រហូតដល់ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ទើបសាលាខណ្ឌចំការមន អញ្ជើញ យើងខ្ញុំទាំង ២៣ រូបដែលជាតំណាងទៅចូលរួមប្រជុំដើម្បីធ្វើការដោះស្រាយបណ្ដឹងបដិសេធរវាងគណៈកម្មការសហគមន៍ដីក្រហម ។ នៅក្នុងអង្គប្រជុំ ដែលមានរយៈពេលមិនដល់កន្លះម៉ោងផងនោះ ហើយសូម្បីតែប្រជាពលរដ្ឋដែលចង់ចូលរួមស្ដាប់ អ្នកសារពត៌មាន បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ក៏តំណាងសាលាខណ្ឌមិនអនុញ្ញាតឱ្យចូលរួមដែរ ។ ចំពោះរបៀបវារៈនៃអង្គប្រជុំទាំងមូល គឺលើកឡើងតែពីបញ្ហាស្នាមមេដៃតែប៉ុណ្ណោះ ។ **លោកស្រី កែវ ចាន់ដួង និងលោក ចាន់ សៅ** ដែលជាតំណាងខណ្ឌ បាននិយាយថា សាលាខណ្ឌនឹងបង្កើតគណៈកម្មការចំរុះមួយ ដើម្បីធ្វើកោសល្យវិច័យ បើស្នាមមេដៃនោះពិតជាត្រឹមត្រូវ សាលាខណ្ឌនឹងធ្វើការដោះស្រាយ តែបើមិនពិតទេនោះ អ្នកតំណាងត្រូវតែទទួលខុសត្រូវនៅចំពោះមុខច្បាប់ ហើយក៏បានប្រកាសបិទអង្គប្រជុំ ។ ពេលនោះ យើងខ្ញុំដែលជាតំណាង បានសំណូមពរសូមឱ្យផ្អាកសកម្មភាពរវាងសហគមន៍ និង ក្រុមហ៊ុនសិន ទម្រាំដោះស្រាយបញ្ហានេះចប់សព្វគ្រប់ ។ ការប្រជុំលើកនេះ មិនបានលើកឡើង នូវបញ្ហាដែល យើងខ្ញុំទាំងអស់គ្នាចង់បាន មកធ្វើការដោះស្រាយនោះទេ ។ រហូតមកដល់ពេលនេះ ពុំទាន់មានដំណោះស្រាយណាមួយពីអាជ្ញាធរ ស្របតាមសំណូមពររបស់ប្រជាពលរដ្ឋដែលចង់បានឡើយ ។ មិនតែប៉ុណ្ណោះ បាតុភាពនៃការបង្ខិតបង្ខំ គំរាមកំហែង ដែលធ្វើឡើងដោយប្រធានសហគមន៍នៅតែបន្តឥតឈប់ឈរចំពោះប្រជាពលរដ្ឋដែលក្រាញនៀលមិនព្រមធ្វើការដោះដូរ ។

នៅយប់ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៥ មានការបោះដុំឈើគូសមកលើផ្ទះអ្នកតំណាងដែលធ្វើការទាមទារមិនឱ្យមានការដោះដូរដីនោះ តែដោយមានការប្រុងប្រយត្ន័ជាមុនទើបប្រជាពលរដ្ឋនាំគ្នាមកពន្លត់ភ្លើងឈើគូសនោះបានទាន់ពេលវេលា ។ បញ្ហានេះ ពួកយើងខ្ញុំក៏បានប្ដឹងទៅលោកប្រធានភូមិ ១៥ ទាំងយប់ដែរ តែមិនជួបលុះព្រឹកឡើង គាត់បាននិយាយថា បញ្ហានេះគាត់ក៏បានដឹងដែរ តែពេលនោះគាត់មិនបាននៅនឹងកន្លែងទេ ។

នៅល្ងាចថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០០៥ លោក អៀម អឿន ប្រធានភូមិ ១៥ ឱ្យហៅអ្នកតំណាងយើងខ្ញុំទៅទីស្នាកការភូមិ ហើយហាមឃាត់មិនឱ្យពួកយើងខ្ញុំដើរផ្ដិតមេដៃទៀតទេ ដោយសំឡុតគំរាមកំហែងយ៉ាងខ្លាំងរហូតដល់មានការជ្រួលច្របល់ពីប្រជាពលរដ្ឋនៅមុខទីស្នាកការភូមិ ។

នៅយប់ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៥ មានប៉េអឹម ដែលជាក្រុមរបស់មេសហគមន៍ឈ្មោះ **ផាន់ ណារិន** បានជិះម៉ូតូ ក្រឡឹងពេញភូមិ ហើយលាត់ចង្កេះបញ្ចេញកាំភ្លើងខ្លីសំញ៉ែញនៅមុខផ្ទះពួកអ្នកតំណាងទៀតផង លុះប្រហែលជាម៉ោង ១ យប់ មានស្នូរកាំភ្លើងមួយគ្រាប់នៅក្បែរផ្ទះអ្នកតំណាង នាំឱ្យមានការជ្រួលច្របល់យ៉ាងខ្លាំងនៅក្នុងភូមិ ។

លុះព្រឹកឡើងនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៥ លោក អៀម អឿន ប្រធានភូមិ ១៥ បានហៅតំណាងមកទីស្នាក់ការភូមិ ហើយនិយាយពីរឿងបាញ់កាំភ្លើងពីយប់មិញនោះថា គេដឹងមុខអ្នកបាញ់ហើយ គឺចាប់ពីផ្ទះអ្នកតំណាងទៅខាងជើងនោះ គឺត្រូវចាប់ខ្លួនម្នាក់ ។

នៅល្ងាចថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០០៥ ពេលដែលពួកអ្នកតំណាង បានដើរប្រាប់ប្រជាពលរដ្ឋឱ្យមកផ្តិតមេដៃនៅក្នុងផ្ទះរបស់គាត់ ស្រាប់តែពួកសហគមន៍ ដឹកនាំដោយអ្នកស្រី **កែវ ចាន់ដួង** ប្រធានសហគមន៍ភូមិ២ បានមកស្រែកជេរពួកអ្នកតំណាង និង ប្រជាពលរដ្ឋទាំងកំរោលថា : **ពួកអាឯ្អងមិនមានសិទ្ធិតវ៉ាទេ ព្រោះប្រធានសហគមន៍ទាំងអស់ចាត់តាំងដោយសាលាក្រុងភ្នំពេញ ដូច្នេះការដូរដីនេះស្រេចទៅលើពួកសហគមន៍ជាអ្នកសំរេច ពួកអាឯ្អងគ្មានសិទ្ធិសំរេចអ្វីទេ !**

ពេលនោះ លោក **ផាន់ ណារិន** ប្រធានសហគមន៍ បានទូរស័ព្ទទៅហៅពួកប៉េអឹម ដោយចោទថាពួកអ្នកតំណាងបានយកដំបងមកវាយពួកខ្លួន ។ រយៈពេលប្រហែលជា ១ ម៉ោងក្រោយមក ពួកប៉េអឹមក៏បានមកដល់ តែដោយមានប្រជាជនច្រើនពេក ដែលនិយាយពីភាពមិនពិតរបស់មេសហគមន៍ប្រាប់ទៅប៉េអឹមនោះ ទើបប៉េអឹមនោះមិនមានសកម្មភាពអ្វីឡើយ ។ តែពួកប៉េអឹមបាននិយាយថា ហៅតំណាងយើងម្នាក់ឱ្យទៅដោះស្រាយនៅទីស្នាក់ការរបស់ខ្លួន តែប្រជាពលរដ្ឋស្រែកឡើងថា មិនឱ្យទៅ! ពេលនោះពួកប៉េអឹម ក៏បានត្រឡប់ទៅវិញ ។ លើសពីនេះទៅទៀត អ្នកស្រី **កែវ ចាន់ដួង** និង ប្រធានសហគមន៍ បានស្រែកឡើងទៀតថា **អាតំណាងជើងខ្លាំងពួកឯ្អងមិនយូរមិនឆាប់គង់តែដឹងខ្លួនទេ !**

ជាមួយនឹងសកម្មភាពទាំងអស់នេះ ជារៀងរាល់យប់តែងតែមានការគប់ដុំថ្មមកលើដំបូលផ្ទះរបស់តំណាងយើងខ្ញុំ ធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិ និង ធ្លុះធ្លាយដំបូលផ្ទះ ដោយមិនដឹងមុខអ្នកប្រព្រឹត្តឡើយ ។

រាល់ផលវិបាកដែលពួកយើងខ្ញុំជួបប្រទះ តែងតែជំរាបទៅលោកចៅសង្កាត់ សមាជិកក្រុមប្រឹក្សាសង្កាត់ លោកមេភូមិជានិច្ច តែភាពព្រងើយកន្តើយ និងមិនយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរដែនដី ធ្វើឱ្យពួកយើងខ្ញុំមានសេចក្តីអស់សង្ឃឹមយ៉ាងខ្លាំង មិនតែប៉ុណ្ណោះការចូលរួមអន្តរាគមន៍របស់អ្នកស្រី កែវ ចាន់ដួង ដែលជាប្រធានសហគមន៍ កាន់តែធ្វើឱ្យប្រជាពលរដ្ឋមិនសប្បាយចិត្តថែមទៀត ។ បញ្ហានេះ គឺមកពីការឃុបឃិតគ្នារវាងអ្នកទាំងនោះ ក្នុងការតម្លើងតួលេខចំនួនខ្នងផ្ទះ និង ប្រជាជនស្នាក់នៅរហូតដល់ចំនួន ១៤៦៥ គ្រួសារ ព្រោះបើតាមការពិតចំនួននេះរួមបញ្ចូលទាំងចិននៅអូរឫស្សី អូឡាំពិក និង សមាជិករបស់លោកប្រធានសហគមន៍

ប្រធានភូមិ... ដែលសូម្បីតែកូននៅក្នុងអង្រឹងក៏មានខ្ទង់ផ្ទះ និង សៀវភៅសន្សំប្រាក់ដែរនោះ ។ រីឯប្រជាពលរដ្ឋដែលក្រីក្រពិតប្រាកដប្រែជាគ្មានផ្ទះ គ្មានដី គ្មានសៀវភៅសន្សំប្រាក់ ឬក៏កាត់ឈ្មោះគ្នាចោល ហើយលក់បន្តយកលុយដាក់ហោប៉ៅរៀងខ្លួន ហើយដែលបច្ចុប្បន្ននេះសៀវសន្សំប្រាក់ ០១ ក្បាលអាចលក់ក្នុងតំលៃពី ៣,០០០ ទៅ ៣,៥០០ ដុល្លារអាមេរិក។ ពេលដែលប្រជាពលរដ្ឋត្រូវការធ្វើលិខិតស្នាមអ្វីមួយ ដូចជាសៀវភៅសន្សំប្រាក់ សុទ្ធតែទារជាង ១០០ ដុល្លារអាមេរិកទើបធ្វើឱ្យ តើគ្នាមានលុយឯណានឹងបង់ឱ្យ ។ ហើយបើគ្នាមិនធ្វើទេ សុទ្ធតែគំរាមថានឹងលុបឈ្មោះចេញពីបញ្ជី ... ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ សូមឯកឧត្តម មេត្តាជួយដោះស្រាយយ៉ាងណាដើម្បីឱ្យយើងខ្ញុំអាចបន្តរស់នៅលើទីតាំងចាស់ជាធម្មតាវិញ ទម្រាំអាចរកបាននូវក្រុមហ៊ុនថ្មីដែលមានលក្ខខណ្ឌសមស្រប ដែលអាចឱ្យយើងខ្ញុំទាំងអស់គ្នាទទួលយកបាន ។

**ជាមួយគ្នានេះដែរ សូមឯកឧត្តម មេត្តា**

-ជួយធ្វើការផ្លាស់ប្តូរប្រធានសហគមន៍ទាំង ៣៦ រូប ដោយធ្វើការបោះឆ្នោតជ្រើសរើសប្រធានសហគមន៍ ថ្មី ដែលបំរើដល់ផលប្រយោជន៍របស់ប្រជាជនពិត១

- សូមឱ្យពួកសហគមន៍ចាស់ប្រគល់ប្រាក់សន្សំមកឱ្យប្រជាជនវិញឱ្យបានគ្រប់ចំនួន

- បង្កើតនូវគណៈកម្មការពិនិត្យខ្ទង់ផ្ទះ ចំនួនគ្រួសារដែលបានស្នាក់នៅពិតប្រាកដ ព្រោះតួលេខដែលបានស្នើឡើងទៅលើពីមុននោះ វាហួសពីការពិត ដែលនាំឱ្យពួកគេទាំងអស់គ្នាឃុបឃិតគ្នាជាមួយសាលាសង្កាត់ មេប៉ុស្តិ៍ ប្រធានភូមិ ប្រធានសហគមន៍ទាំង ៣៦ រូបគំនិតគ្នាធ្វើបាបប្រជាពលរដ្ឋ ។ ដោយសារតែតួលេខច្រើនដូច្នេះហើយ ទើបមិនមានក្រុមហ៊ុនណាមួយហ៊ានមកធ្វើការសាងសង់ប្រវាស់បាន ។

- ជួយធ្វើការផ្លាស់ប្តូរប្រធានភូមិ និង សន្តិសុខភូមិ ១៥ ព្រោះអ្នកទាំងនេះគាបសង្កត់គំរាមកំហែងពួកយើងខ្ញុំ ដោយយកច្បាប់ព្រៃមកប្រើ និងអាងអំណាចរបស់ខ្លួន ។

- សូមជួយណែនាំដល់លោកចៅសង្កាត់ ឱ្យចេះជួយដោះស្រាយបញ្ហាផ្សេង១របស់ប្រជាពលរដ្ឋ ដែលជួបការលំបាកផង កុំឱ្យមានភាពលំអៀងទៅម្ខាង១ និង ប្រើច្បាប់ព្រៃមកលើប្រជាពលរដ្ឋ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា ។

**ឧបសម្ព័ន្ធទី៨**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

6.611 13.07.06

## ពាក្យបណ្តឹង

យើងខ្ញុំទាំងអស់គ្នាមានចំនួន ៣៧ នាក់ ដែលជាតំណាងថ្មីរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងសហគមន៍ដីក្រហម ស្ថិតនៅក្នុងភូមិ ២ និង ភូមិ ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

**សូមគោរពចូលមក**

**លោកប្រធាន មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានីភ្នំពេញ**

**កម្មវត្ថុ** : សុំប្តឹងបដិសេធ

១- កិច្ចសន្យាសាងសង់អាគារផ្ទះល្វែងលើទីតាំងថ្មី របស់គណៈកម្មការសហគមន៍ ដីក្រហម និង ក្រុមហ៊ុន **សេវ៉ែនអ៊ិនជី** ( 7NG Construction ) ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ ។

២- សេចក្តីជូនដំណឹងលេខ ០៥៨ សជណ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ចេញដោយអភិបាលខណ្ឌចំការមន

**យោង** : លិខិតលេខ ៨៧៥ សជណ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ ចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី ។

លោកប្រធានការិយាល័យភូមិបាលខណ្ឌជាទីគោរព !យើងខ្ញុំទាំងអស់គ្នាជាតំណាងនិងប្រជាពលរដ្ឋរស់នៅ ក្នុងសហគមន៍ដីក្រហម ភូមិ ២ និង ភូមិ ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន មានកិត្តិយសជំរាបជូនលោកប្រធាន មេត្តាជ្រាបថា:

កាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ រាជរដ្ឋាភិបាលដែលមានសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ជាប្រមុខ លោកបានសម្បទានដី សង្គមកិច្ច ទំហំ ៣.៧០ ហិកតា លើផ្ទៃដីសរុប ៤.៧០ ហិកតា ដែលមានទីតាំងខាងជើងស្ថានទូតរុស្ស៊ី ខាងត្បូងសាលមហោស្រពទន្លេបាសាក់ ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមនដែលមានឈ្មោះថាសហគមន៍ដីក្រហម ដើម្បីអោយប្រជាពលរដ្ឋអភិវឌ្ឍន៍លំនៅដ្ឋាន នៅនឹងកន្លែង ។

ប៉ុន្តែនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ ប្រធានសហគមន៍ឈ្មោះ **គីម យ៉ាន** ស្នាក់នៅផ្ទះលេខ ១៣៧ ក្រុម ១០៦ ភូមិ ១៥ និង **ជាន់ ណារិន** ស្នាក់នៅផ្ទះលេខ ក២៥០ ក្រុម ១០៤ ភូមិ ១៥ ព្រមទាំងសមាជិកដទៃទៀតទាំងអស់ចំនួន ៣៦ នាក់ បានឃុបឃិតគ្នាលួចចុះកិច្ចសន្យាមួយដើម្បីធ្វើការដោះដូរ លំនៅដ្ឋានជាមួយនិងក្រុមហ៊ុន **សេវ៉ែន អ៊ិនជី** ( 7NG Construction ) លើទីតាំងថ្មីដែលស្ថិតនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ ដោយពុំបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ឡើង ។ លុះដល់ រសៀលថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥ ទើបចៅសង្កាត់ មេភូមិ និង គណៈកម្មការសហគមន៍បានប្រជុំប្រាប់ប្រជាពលរដ្ឋ អំពីការដោះដូរដី ហើយលោកចៅសង្កាត់

បាននិយាយថា បើនរណាចង់ទៅទីតាំងថ្មីត្រូវផ្តិតមេដៃក្នុងកិច្ចសន្យា ហើយបើ នរណាមិនចង់ទៅក៏គ្មាននរណាបង្ខំឡើយ ពេលនោះប្រជាពលរដ្ឋភាគច្រើនមិនឯកភាពលើការដូរដីនោះទេ ហើយពួកគេ នៅតែបន្តកិច្ចសន្យាដោយមិនបានគិតគូរ ពីផលប្រយោជន៍របស់ប្រជាពលរដ្ឋឡើយ ហើយក្នុងកិច្ចសន្យានោះវិញ ត្រង់ជំពូក ទី ៨ បានចែងយ៉ាងច្បាស់ថា នៅពេលដែល ភាគី "ខ" សាងសង់ផ្ទះបានចំនួន ២០០ ទៅ ៣០០ ល្វែងគឺភាគី "ក" ត្រូវធ្វើ ការផ្លាស់ប្តូររុះរើផ្ទះពីទីតាំងចាស់ទៅ ទីតាំងថ្មីតែម្តង មិនមែនតាមការចង់ដូររបស់ប្រជាពលរដ្ឋឡើយ ។ ក្រោយមក ប្រធាន និង គណៈកម្មការសហគមន៍ចេះតែដើរបញ្ចុះបញ្ចូល បំភិតបំភ័យ គំរាមគំហែងប្រជាពលរដ្ឋអោយផ្តិតមេដៃចាក ចេញ ព្រមទាំងគំរាមថា ប្រយ័ត្នភ្លើងឆេះផ្ទះបើនរណាមិនព្រមចេញ ហើយគេនឹងមានវិធានការណ៍ក្តៅដោយប្រើ កំលាំងរុះរើ និង ហ៊ុំពទ្ធ័របងទៀតផង ។

ហេតុដូច្នេះហើយ ជារៀងរាល់ថ្ងៃប្រជាពលរដ្ឋមានការតួញត្អែរ មិនសប្បាយចិត្ត និងព្រួយបារម្ភនូវអំពើររបស់ប្រធានសហគមន៍ទាំងនោះ រហូតដល់អ្នកខ្លះសំរានមិនលក់មិនហ៊ានចាកចេញទៅប្រកបមុខរបររកស៊ី ព្រោះខ្លាចមានរឿងហេតុអ្វីកើតឡើងដោយមិនដឹងខ្លួន ។

ដូច្នេះអំពើរបស់ប្រធាន និង គណៈកម្មការសហគមន៍ដីក្រហមទាំងអស់ដែលហ៊ានសំរេចចិត្តយកដីសម្បទានសង្គមកិច្ចដែលរាជរដ្ឋាភិបាល មានសម្តេច **ហ៊ុន សែន** ជាអ្នកដឹកនាំយល់ពីសុខទុក្ខរបស់ប្រជាពលរដ្ឋលោកបានសម្បទាន ដីអោយសំរាប់ជាកម្មសិទ្ធិសមូហភាពរបស់ប្រជាជនក្រីក្រ ដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាននៅទីឯកន្លែងនេះ ទៅដោះដូរនឹង ក្រុមហ៊ុន សេវិន អ៊ិនជី ( 7NG Construction ) ដោយមិនអោយប្រជាពលរដ្ឋដឹងជាមុន នេះគឺជាអំពើមួយដែលផ្ទុយ ទៅនឹងមាត្រាទី ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង គោលនយោបាយរបស់រាជរដ្ឋាភិបាលទាំងស្រុង ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ សូមលោកប្រធានមន្ទីរ មេត្តាជួយរកយុត្តិធម៌ជូនដល់តំណាងយើងខ្ញុំទាំងអស់ ៣៧ រូប និង ផ្តន្ទាទោសចំពោះប្រធានគណៈកម្មការសហគមន៍ទាំង ៣៦នាក់នោះទៅតាមផ្លូវច្បាប់ដោយក្តីអនុគ្រោះ ។

សូមលោកប្រធាន ការិយាល័យភូមិបាលខ័ណ្ឌមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំទាំងអស់ ។

ភ្នំពេញ . ថ្ងៃទី ............ខែ កក្កដា ឆ្នាំ ២០០៦

តំណាងប្រជាពលរដ្ឋ

ជូនភ្ជាប់ជាមួយ :

-សេចក្តីជូនដំណឹងរបស់សាលាខណ្ឌចំការមន ០១ ច្បាប់

-កិច្ចសន្យាសាងសង់ផ្ទះល្វែង ០១ ច្បាប់

-លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ០១ ច្បាប់

- ស្នាមមេដៃ តំណាងប្រជាពលរដ្ឋ ៣៧ នាក់

**ឧបសម្ព័ន្ធទី៩**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

18.7.08 9h00

**ពាក្យបណ្តឹង**

យើងខ្ញុំជាតំណាងប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ដីក្រហម ស្ថិតនៅភូមិ ២ និង ភូមិ ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ : សុំប្តឹងបដិសេធ**

១. កិច្ចសន្យាសាងសង់អាគារផ្ទះល្វែងលើទីតាំងថ្មីរបស់គណៈកម្មការសហគមន៍ដីក្រហម និង ក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7 NG Construction) ចុះថ្ងៃទី ១៣ មករា ២០០៥ ។

២. សេចក្តីជូនដំណឹងលេខ ០៥៨ សជណ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ចេញដោយអភិបាលខណ្ឌចំការមន ។

៣. មិនទទួលស្គាល់តួលេខប្រជាពលរដ្ឋចំនួន ១៤៦៥ គ្រួសារ ។

៤. មិនទទួលស្គាល់ប្រធាន និង គណៈកម្មការសហគមន៍ទាំង ៧ តទៅទៀត ។

**យោង** : លិខិតលេខ ៨៧៥ សជណ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៣ ចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី ។

ឯកឧត្តមជាទីគោរព! យើងខ្ញុំទាំងអស់គ្នាជាតំណាង និងជាប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ដីក្រហមភូមិ ២ និង ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន មានកិត្តិយសសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា :

កាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ រាជរដ្ឋាភិបាលដែលមានសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាប្រមុខ លោកបានសម្បទានដីសង្គមកិច្ចទំហំ ៣.៧០ ហិកតា ដែលមានទីតាំងខាងត្បូងសាលមហោស្រពទន្លេបាសាក់ ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានឈ្មោះថាសហគមន៍ដីក្រហម ដើម្បីឱ្យប្រជាពលរដ្ឋអភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែង ។

ប៉ុន្តែនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ តំណាងសហគមន៍ទាំង ៧ ដែលមានសមាជិកទាំងអស់ចំនួន ៣៦ រូប បានឃុបឃិតគ្នាលួចចុះកិច្ចសន្យាមួយដើម្បីធ្វើការដោះដូរលំនៅដ្ឋានជាមួយនឹងក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7 NG Construction) លើទីតាំងថ្មីដែលស្ថិតនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ដោយពុំបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ឡើយ ។ ក្រោយមក

ប្រជាពលរដ្ឋមានការភ្ញាក់ផ្អើល ហើយបានធ្វើពាក្យបណ្តឹងទៅសាលាក្រុងភ្នំពេញដើម្បីសុំការជួយដោះអំពីបញ្ហានេះ ។ ប៉ុន្តែសាលាក្រុងពុំបានដោះស្រាយជូនប្រជាពលរដ្ឋយើងខ្ញុំឡើយ រហូតដល់ពេលនេះមេសហគមន៍ និង អាជ្ញាធរមូលដ្ឋានបំភិតបំភ័យគំរាមកំហែងប្រជាពលរដ្ឋឱ្យផ្តិតមេដៃចាកចេញ ។

ហេតុដូច្នេះហើយ ចំពោះកិច្ចសន្យាដែលមេសហគមន៍ និង ក្រុមហ៊ុន សេវ៉ែនអ៊ិនជី (7 NG Construction) យើងខ្ញុំពុំទទួលស្គាល់ឡើយ ។

ចំពោះតួលេខដែលមានចំនួន១៨៦៥ គ្រួសារនោះពុំពិតប្រាកដឡើយ ព្រោះតួលេខនេះ គឺជាតួលេខបំប៉ោង តាមការពិតប្រជាពលរដ្ឋមានមិនដល់ចំនួនខាងលើឡើយ ។

ដោយសារតែអំពើពុករលួយ និង ការប្រើអំណាចរបស់ពួកគេមកគាបសង្កត់ គំរាមកំហែងជេរប្រមាថមកលើប្រជាពលរដ្ឋយ៉ាងឃោរឃៅដូចនេះ ទើបពួកយើងខ្ញុំឈប់ទទួលស្គាល់ និង ឈប់ទទួលស្គាល់តទៅទៀត ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ សូមឯកឧត្តមមេត្តាជួយដោះស្រាយដល់យើងខ្ញុំទាំងអស់ឱ្យបានរស់នៅនឹងកន្លែងតទៅទៀត សមតាមបំណងរបស់សម្តេច ហ៊ុន សែន និងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលដឹកនាំដោយសម្តេចដ៏ខ្ពង់ខ្ពស់ ។ ជាមួយគ្នានេះដែរ សូមឯកឧត្តមមេត្តាបញ្ឈប់ជាបន្ទាន់នូវសកម្មភាពរបស់មេភូមិ និង មេសហគមន៍ដែលធ្វើការរុះរើផ្ទះដែលដើរទិញបានផ្ទះពីប្រជាពលរដ្ឋ ដើម្បីបញ្ចៀសនូវការរុះផ្ទះមួយខ្នង បំប៉ោងផ្ទះពីបីខ្នង ទៅប្រាំពីរខ្នង ។ សូមឱ្យឯកឧត្តម មេត្តាធ្វើការរឹបអូសយកផ្ទះដែលមេភូមិ មេសហគមន៍បានទិញពីប្រជាពលរដ្ឋ មកទុកជាសម្បត្តិរួម ព្រោះអំពើនេះវាផ្ទុយទៅនឹងលក្ខន្តិកៈសហគមន៍ដែលត្រូវអនុវត្តលំនៅដ្ឋានដល់ជនក្រីក្រ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំទាំងអស់គ្នា ។

ភ្នំពេញ,ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦

តំណាងប្រជាពលរដ្ឋ



ឡោ សីហា

ជូនភ្ជាប់មកជាមួយ

| | |
|---|---|
| -ស្នាមមេដៃផតចំលងប្រជាពលរដ្ឋចំនួន ៨០៤ គ្រួសារ | ០១ ច្បាប់ |
| -ស្នាមមេដៃផតចំលងផ្តល់សិទ្ធប្រជាពលរដ្ឋចំនួន | ០១ ច្បាប់ |
| -ស្នាមមេដៃតំណាងប្រជាពលរដ្ឋចំនួន | ០១ ច្បាប់ |
| -កិច្ចសន្យាសាងសង់ផ្ទះល្វែង | ០១ ច្បាប់ |
| -លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី | ០១ ច្បាប់ |
| -របាយការរបស់សាលាខណ្ឌចំការមន | ០១ ច្បាប់ |
| -សេចក្តីជូនដំណឹងរបស់សាលាខណ្ឌចំការមន | ០១ ច្បាប់ |
| -ឯកសារកាសែត | ០៣ ច្បាប់ |
| -របាយការណ៏ | ០១ ច្បាប់ |
| -ពាក្យបណ្តឹងមេធាវីទៅសាលាក្រុង | ០២ ច្បាប់ |

57/06
14 07 06

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

# ពាក្យបណ្តឹង

យើងខ្ញុំជាតំណាងប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ដីក្រហម ស្ថិតនៅភូមិ ២ និង ភូមិ ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

## សូមគោរពចូលមក

## លោកជំទាវ ម៉ែន សំអន ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងសភា ព្រឹទ្ធសភា និង អធិការកិច្ច

**កម្មវត្ថុ : សុំប្តឹងបដិសេធ**

៥. កិច្ចសន្យាសាងសង់អាគារផ្ទះល្វែងលើទីតាំងថ្មីរបស់គណៈកម្មការសហគមន៍ដីក្រហម និង ក្រុមហ៊ុន សេវ៉ែនអ៊ិនជី (7 NG Construction) ចុះថ្ងៃទី ១៣ មករា ២០០៥ ។

៦. សេចក្តីជូនដំណឹងលេខ ០៥៨ សជណ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ចេញដោយអភិបាលខណ្ឌចំការមន ។

៧. មិនទទួលស្គាល់តួលេខប្រជាពលរដ្ឋចំនួន ១៤៦៥ គ្រួសារ ។

៨. មិនទទួលស្គាល់ប្រធាន និង គណៈកម្មការសហគមន៍ទាំង ៧ តទៅទៀត ។

**យោង :** លិខិតលេខ ៨៧៥ សជណ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៣ ចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី ។

លោកជំទាវជាទីគោរព! យើងខ្ញុំទាំងអស់គ្នាជាតំណាង និងជាប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ដីក្រហមភូមិ ២ និង ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន មានកិត្តិយសសូមជំរាបជូនលោកជំទាវមេត្តាជ្រាបថា :

កាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ រាជរដ្ឋាភិបាលដែលមានសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាប្រមុខ លោកបានសម្បទានដីសង្គមកិច្ចទំហំ ៣.៧០ ហិកតា ដែលមានទីតាំងខាងត្បូងសាលមហោស្រពទន្លេបាសាក់ ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានឈ្មោះថាសហគមន៍ដីក្រហម ដើម្បីឱ្យប្រជាពលរដ្ឋអភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែង ។



ប៉ុន្តែនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ តំណាងសហគមន៍ទាំង ៧ ដែលមានសមាជិកទាំងអស់ចំនួន ៣៦ រូប បានឃុបឃិតគ្នាលួចចុះកិច្ចសន្យាមួយដើម្បីធ្វើការដោះដូរលំនៅដ្ឋានជាមួយនឹងក្រុមហ៊ុនសេវ៉ែនអ៊ិនជី (7 NG Construction) លើទីតាំងថ្មីដែលស្ថិតនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ដោយពុំបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ឡើយ ។ ក្រោយមក

ប្រជាពលរដ្ឋមានការភ្ញាក់ផ្អើល ហើយបានធ្វើពាក្យបណ្តឹងទៅសាលាក្រុងភ្នំពេញដើម្បីសុំការជួយដោះអំពីបញ្ហានេះ ។ ប៉ុន្តែសាលាក្រុងពុំបានដោះស្រាយជូនប្រជាពលរដ្ឋយើងខ្ញុំឡើយ រហូតដល់ពេលនេះ មេសហគមន៍ និង អាជ្ញាធរមូលដ្ឋានបំភិតបំភ័យគំរាមកំហែងប្រជាពលរដ្ឋឱ្យផ្តិតមេដៃចាកចេញ ។

ហេតុដូច្នេះហើយ ចំពោះកិច្ចសន្យាដែលមេសហគមន៍ និង ក្រុមហ៊ុន សេវ៉េនអ៊ិនជី (7 NG Construction) យើងខ្ញុំពុំទទួលស្គាល់ឡើយ ។

ចំពោះតួលេខដែលមានចំនួន១៤៦៥ គ្រួសារនោះពុំពិតប្រាកដឡើយ ព្រោះតួលេខនេះ គឺជាតួលេខបំប៉ោង តាមការពិតប្រជាពលរដ្ឋមានមិនដល់ចំនួនខាងលើឡើយ ។

ដោយសារតែអំពើពុករលួយ និង ការប្រើអំណាចរបស់ពួកគេមកគាបសង្កត់ គំរាមកំហែងជេរប្រមាថមកលើប្រជាពលរដ្ឋយ៉ាងឃោរឃៅដូចនេះ ទើបពួកយើងខ្ញុំឈប់ទទួលស្គាល់ និង ឈប់ទទួលស្គាល់តទៅទៀត ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ សូមលោកជំទាវមេត្តាជួយដោះស្រាយដល់យើងខ្ញុំទាំងអស់ឱ្យបានរស់នៅនឹងកន្លែងតទៅទៀត សមតាមបំណងរបស់សម្តេច ហ៊ុន សែន និងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលដឹកនាំដោយសម្តេចដ៏ខ្ពង់ខ្ពស់ ។ជាមួយគ្នានេះដែរ សូមលោកជំទាវមេត្តាបញ្ឈប់ជាបន្ទាន់នូវសកម្មភាពរបស់មេភូមិ និង មេសហគមន៍ដែលធ្វើការរុះរើផ្ទះដែលដើរទិញបានផ្ទះពីប្រជាពលរដ្ឋ ដើម្បីបញ្ចៀសនូវការរុះផ្ទះមួយខ្នងបំបោងផ្ទះពីបីខ្នងទៅប្រាំពីរខ្នង ។ សូមឱ្យលោកជំទាវ មេត្តាធ្វើការរឹបអូសយកផ្ទះដែលមេភូមិ មេសហគមន៍បានទិញពីប្រជាពលរដ្ឋ មកទុកជាសម្បត្តិរួម ព្រោះអំពើនេះវាផ្ទុយទៅនឹងលក្ខន្តិកៈសហគមន៍ដែលត្រូវអនុវត្តលំនៅដ្ឋានដល់ជនក្រីក្រ ។

សូមលោកជំទាវ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំទាំងអស់គ្នា ។

ភ្នំពេញ,ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦

ជូនភ្ជាប់មកជាមួយ

-ស្នាមមេដៃផ្តិតចំលងប្រជាពលរដ្ឋចំនួន ៨០៤ គ្រួសារ ០១ ច្បាប់
-កិច្ចសន្យាសាងសង់ផ្ទះល្វែង ០១ ច្បាប់
-លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ០១ ច្បាប់
-របាយការរបស់សាលាខណ្ឌចំការមន ០១ ច្បាប់
-សេចក្តីជូនដំណឹងរបស់សាលាខណ្ឌចំការមន ០១ ច្បាប់
-ឯកសារកាសែត ០៣ ច្បាប់
-របាយការណ៍ ០១ ច្បាប់

**ឧបសម្ព័ន្ធទី១០**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

__លិខិតផ្ដល់សិទ្ធ__

ខ្ញុំបាទ នាងខ្ញុំឈ្មោះ..............................អាយុ..43...ឆ្នាំ ស្នាក់នៅផ្ទះលេខ..............ក្រុម...........ភូមិ...15.... សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ អត្តសញ្ញាណប័ណ្ណលេខ........................................

ខ្ញុំបាទ នាងខ្ញុំសូមផ្ដល់សិទ្ធទៅអោយតំណាងថ្មីដែលមានរាយឈ្មោះដូចខាងក្រោម:

| | | | | |
|---|---|---|---|---|
| ១- ឡេា សីហា | ៧- លី វិសុទ្ធ | ១៣- ទិត្យ សុគន្ធារី | ១៩- ឡេង គីមធឿន | ២៥- ភិត ឡៃហឿន |
| ២- ចាន់ វិចិត្រ | ៨- ចាច់ វ៉ាង | ១៤- គង់ ស្រីអូន | ២០- តូច ស៊ីផាត | ២៦- ទូច សាមុត |
| ៣- ហែម ឡាយ | ៩- កែវ សុធិន | ១៥- ម៉ៅ គីម | ២១- លី ហុង | ២៧- សួន ស៊ីណេត |
| ៤- ដាំង សារុំ | ១០- ត្រេង សុខរិទ្ធ | ១៦- អន វណ្ណា | ២២- ភួង វដ្ដា | ២៨- សោម ចន្ទា |
| ៥- សែត សុខខៃ | ១១- ទូច វដ្ដា | ១៧- ចាច់ ហាន | ២៣- ផេង ភូរ | ២៩- ឡាញ់ លីណា |
| ៦- ហ៊ុន សារ៉ន | ១២- សុខ សុភា | ១៨- នូ ណារិន | ២៤- សាន់ ណេាត | ៣០- កែវ មន្នី |

ដើម្បីអោយពួកគាត់ធ្វើជាតំណាងរបស់ខ្ញុំបាទ នាងខ្ញុំចាប់ពីថ្ងៃផ្ដិតមេដៃនេះតទៅក្នុងន័យជួយធ្វើការ តវ៉ា ចំពោះគណៈកម្មការសហគមន៍ចាស់ទាំង៧ នៅក្នុងភូមិ២ និងភូមិ១៥ ដែលបានឃុបឃិតគ្នាលួចផ្ដិតមេដៃ ដោះដូរដីដែលរាជរដ្ឋាភិបាល បានសម្បទាន អោយប្រជាពលរដ្ឋ អភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែង ទៅអោយក្រុមហ៊ុន ដែលមានទីតាំងនៅឆ្ងាយពីទីតាំងចាស់សព្វថ្ងៃ ។ ទង្វើនេះ វាផ្ទុយ ពីឆន្ទះរបស់ខ្ញុំបាទ នាងខ្ញុំ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ដែលមានសម្ដេច ហ៊ុន សែនជាប្រមុខ ។ ដូច្នេះខ្ញុំបាទ នាងខ្ញុំ ជាប្រជាពលរដ្ឋ សូមបដិសេធទាំងស្រុងនូវកិច្ចព្រមព្រៀងដូរដីរបស់គណៈកម្មការសហគមន៍ទាំង៧នោះចោល និងសូមទាមទាអោយមានការ អភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែងវិញ ។ ហើយឈប់ទទួលស្គាល់ប្រធាននិង គណៈកម្មការសហគមន៍ទាំង៧ នោះតទៅទៀត ។

ភ្នំពេញថ្ងៃទី...16....ខែ...7......ឆ្នាំ២០០៦

ស្នាមមេដៃស្ដាំ



ភ្ជាប់ជាមួយ

-រូបថតមួយសន្លឹក

-អត្តសញ្ញាណប័ណ្ណ ឬ ប័ណ្ណស្នាក់នៅ

ឧបសម្ព័ន្ធទី១១

( មិនមានឯកសារជាភាសាខ្មែរ )

**Kingdom of Cambodia**

**Nation Religion King**

**&'**

**National Assembly**
**To**
**Samdech Prime Minister of the Royal Government of Cambodia**

Through : The president of National Assembly
Objective : A lawsuit of people living in Dey Krahorm Community to maintain on-site resident in Sangkat Tonle Bassac, Khan Chamkarmorn, Phnom Penh.
Reference : - Letter of notification numbered 875 សជណ. issued on July 08, 2003 by Council of Ministers
- Community Chiefs and 7NG Construction's house construction contract dated January 13, 2005
- A lawsuit of people's representative living in Village II and XV in Dey Krahorm community dated May 20, 2006

According to the objective and references above, I would like to inform Samdech Prime Minister that the people whose address is as mentioned above are satisfactorily in favor of the Council of Ministers decision No. 875, point I and II, to render a social land concession of 3.75 hectares out of the total land 4.7 hectares to the people to develop as on-site residential development. It was not until January 13, 2005 that the community chiefs as well as 7NG Construction Company conspired together to secretly sign a housing construction contract and agreed to move the people to another location, at Damnak Troyeung Village, Sangkat Choam Chao, Khan Dangkor, Phnom Penh. This really made people very outraged and they accused the community chief who signed the contract personally without having any collective consent from people who are villagers there. On July 06, 2006, the Khan Chamkarmorn Office issued an announcement to the people to join a lottery for new apartments [in Damnak Troyeung], which is contrary to the aspirations of the people completely. Both threats and force were used by village and sangkat authorities, and on July 22, 2006 at 12 o'clock there was an attack by one village security guard in Village XV named Pik Pam on a resident named Sek Saroeun on his head and it was bleeding

Those acts indicate that the people in Dey Krahorm Community really want to live and develop the on-site residences according to the written message from Council Ministers.

As the above mention, would Samdech please kindly allow the people to live in the same place and please also help to annul completely the house construction contract of the company.

Please Samdech kindly accept my deep and high respect to you.

Phnom Penh, July 25, 2006
Signed

**Mr. Ho Vann**
**Lawmaker in P.P.**

No.: 875 រស
Having Seen and disseminated to
Samdech Prime Minister Hun Sen
To check and decide favorably
P.P, July 31, 2006
President of National Assembly
Signed and Stamped

**Heng Samrin**

Copy to:

- Cabinet of the King
- Ministry of Interior
- Ministry of Relation of National Assembly, Senate and Inspection
- National Authority to Land Conflict Resolution
- Municipality
- Human Right Organizations
- Local and International Medias "for information"

**រូបថតទី១**



កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៦ សេក សាវឿន បានទទួលរងការបង្ករបួសស្នាំ ដែលប្រព្រឹត្តដោយសន្តិសុខក្រុមហ៊ុន 7NG ឈ្មោះ ពិក ប៉ា ម ។ ពិក ប៉ា ម ក្រោយមកត្រូវបានគេរាយការណ៍ថា ត្រូវបានកាត់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សានេះ ។

**ឧបសម្ព័ន្ធទី១៣**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

ជម្រាបជូន

ឯកឧត្តមអភិបាលរាជធានីភ្នំពេញ

តាមរយៈ : ប្រធានរដ្ឋសភា

កម្មវត្ថុ : សំណើសុំរក្សាតូបលក់ដូរ និងរកកន្លែងលក់ដូរជូនអាជីវករ នៅក្នុងសហគមន៍ដីក្រហម ស្ថិតនៅសង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន ។

យោង : -លិខិតរបស់តំណាងអាជីវករ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា : បងប្អូនអាជីវកររស់នៅភូមិ១៥ ខ្លះទិញតូបពីគេបន្ត ខ្លះទៀតជួលកន្លែងមុខផ្ទះគេលក់ និងអ្នកខ្លះទៀតមានការយល់ព្រមពីអាជ្ញាធរមូលដ្ឋានក្នុងការតាំងទីលក់ដូរនៅក្នុងភូមិ១៥នេះ ។

ស្រាប់តែមកដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៦ នេះ មានលិខិតរបស់អាជ្ញាធរសង្កាត់បានបង្ខំអោយពួកគាត់រុះរើក្នុងរយៈពេល៣ថ្ងៃ ហើយពេលនោះពួកគាត់ក៏បានធ្វើការតវ៉ាសុំលក់ដូរនៅកន្លែងនោះដដែលទំរាំប្រជាពលរដ្ឋនៅភូមិដីក្រហមរុះរើលំនៅដ្ឋានរួចរាល់ ឬមួយបើចង់រុះរើបន្ទាន់ សូមអោយអាជ្ញាធរសង្កាត់រកកន្លែងសមរម្យមួយជិតកន្លែងចាស់ ដើម្បីអោយពួកគាត់បានគ្រាន់នឹងចិញ្ចឹមឆ្នាំងផង ព្រោះអាជីវករទាំងនោះមានជីវភាពក្រីក្រលំបាកណាស់ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាពិនិត្យ និងសំរេចដោះស្រាយការពារអាជីវករទាំងនោះអោយបានលក់ដូរជាធម្មតាដោយក្តីអនុគ្រោះ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ ។

លេខ:...............

ភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦

ហួរ ទាវ៉ន់

តំណាងរាស្ត្រមណ្ឌល ភ្នំពេញ

បានឃើញ និងបញ្ជូនមក

ឯកឧត្តម អភិបាលរាជធានីភ្នំពេញ

ដើម្បីពិនិត្យ និងសំរេច តាមការគួរ ។

ភ្នំពេញ ថ្ងៃទី....ខែ សីហា ឆ្នាំ ២០០៦

ប្រធានរដ្ឋសភា

ហេង សំរិន

ចំលងជូន និង ជូន :

-ខុទ្ទកាល័យព្រះមហាក្សត្រ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អង្គការសិទ្ធិមនុស្សនានា
-សារព័ត៌មានជាតិ និងអន្តរជាតិ "ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ

វិថីសម្តេចសុធារស សង្កាត់ចតុមុខ ភ្នំពេញ ទូរស័ព្ទលេខ : (៨៥៥-២៣) ២១២ ៥៧៥, ២១ ៧៥ ៣៥, ទូរសារលេខ : (៨៥៥-២៣) ២១៧ ៧៦៩

**ឧបសម្ព័ន្ធទី១៤**

ចូលថ្ងៃ 01 ខែ 9 ឆ្នាំ 2006
...លេខ 1775

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>ពាក្យបណ្តឹង</u>

យើងខ្ញុំឈ្មោះ :

១- **ឡោ សីហា** ភេទ ប្រុស អាយុ ៣៩ ឆ្នាំ ស្នាក់នៅផ្ទះលេខ ២០៩ ភូមិ ១៥

២- **ចាន់ ចិចិត្រ** ភេទ ប្រុស ស្នាក់នៅផ្ទះលេខ ១៤៥ ភូមិ ១៥

៣- **ហែម ឡាល** ភេទ ប្រុស ស្នាក់នៅផ្ទះលេខ ១៤៥ ភូមិ ១៥

៤- **សួន ស៊ីណាត** ភេទ ប្រុស អាយុ ៣៩ ឆ្នាំ ស្នាក់នៅផ្ទះលេខ ២៥៤ ភូមិ ១៥

សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

**<u>សូមគោរពជូន</u>**

**លោកប្រធាន ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ**

*សូមជ្រាប ។*

**<u>កម្មវត្ថុ</u>** : សុំប្តឹងឈ្មោះ :

១- **គីម យ៉ាន** ភេទ ប្រុស អាយុ ៥៦ ឆ្នាំ ស្នាក់នៅផ្ទះលេខ ខ១៣៦ ភូមិ ១៥

២- **ណា ម៉ាច** ភេទ ប្រុស អាយុ ៥៥ ឆ្នាំ ស្នាក់នៅផ្ទះលេខ [illegible] ភូមិ ១៥

៣- **ម៉ម គឿន** ភេទ ប្រុស អាយុ ៣៩ ឆ្នាំ ស្នាក់នៅផ្ទះលេខ គ២៥៦ ភូមិ ១៥

៤- **ផាន់ ណារិន** ភេទ ប្រុស អាយុ ៤៨ ឆ្នាំ ស្នាក់នៅផ្ទះលេខ ក២៥០ ភូមិ ១៥

៥- **សីន យីគូ** ភេទ ស្រី អាយុ ៥៣ ឆ្នាំ ស្នាក់នៅផ្ទះលេខ គ១៣០ ភូមិ ១៥

៦- **កេង សុផាត** ភេទ ស្រី អាយុ ៣៥ ឆ្នាំ ស្នាក់នៅផ្ទះលេខ............ ភូមិ ២

៧- **អៀម អឿន** ប្រធានភូមិ ១៥

៨- **ពេជ ចិន្តុល** ប្រធាភូមិ ២



ព្រមទាំងគូកនសរុប ៣៦ រូប ដែលជាសមាជិកប្រធានសហគមន៍ ។

១- ពីបទរំលោភលើសេចក្តីទុកចិត្ត

២- ប្រព្រឹត្តអំពើពុករលួយ និង កេងប្រវ័ញ្ច

**<u>មូលហេតុ</u>** : តបតាមកម្មវត្ថុខាងលើ យើងខ្ញុំជាតំណាងប្រជាពលរដ្ឋនៅភូមិ២ និង ភូមិ ១៥ សូមជំរាបលោកប្រធានមេត្តាជ្រាបថា កាលពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ ប្រធានសហគមន៍ដែលមានឈ្មោះខាងលើ ព្រមទាំងសមាជិករបស់ពួកគេចំនួន ៣៦ នាក់ បានលួចចុះកិច្ចសន្យាដូរដីជាមួយ

ក្រុមហ៊ុន សេវ៉ែន អ៊ិនជី (7NG) ដោយពុំអោយយើងខ្ញុំដែលជាប្រជាពលរដ្ឋក្នុងភូមិដឹងឡើយ មិនតែប៉ុណ្ណោះ ពួកគេបានឃុបឃិតគ្នាជាមួយប្រធានភូមិទាំងពីរ បំប៉ោងតួលេខ ចំនួនគ្រួសារ និងខ្នងផ្ទះខុសពីការពិត ដើម្បីបំរើផលប្រយោជន៍ ពួកគេថែមទៀត ។

ខ្ញុំសូមជំរាបលោកប្រធានដីដែលពួកយើងខ្ញុំស្នាក់នៅក្នុងភូមិទាំងពីរ ជាដីសម្បទានសង្គមកិច្ចរបស់រដ្ឋាភិបាល ដែលបានផ្តល់អោយយើងខ្ញុំដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាននៅលើដីនេះតែម្តង។ ដោយសារតែអំពើកេងប្រវ័ញ្ច ពុករលួយរបស់ពួកគេ បានលួចដូរដីនេះជាមួយក្រុមហ៊ុនដែលផ្ទុយទៅនឹងច្បាប់សម្បទានដីសង្គមកិច្ចក្នុងមាត្រា ១៨ ដែលពួកយើងខ្ញុំពុំទាន់បានរស់នៅដល់ទៅប្រាំឆ្នាំផងដែរ ។

ចំណែក ប្រធានភូមិទាំងពីរភូមិវិញ ត្រូវបំប៉ោងខ្នងផ្ទះ ដើម្បីយកមកបំរើផលប្រយោជន៍របស់ខ្លួន ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមលោកប្រធានមេត្តាចោទប្រកាន់ជនទាំងនេះតាមច្បាប់ និង រកយុត្តិធម៌ជូនដល់យើងខ្ញុំដែលជាជនស្លូតត្រង់ដោយអនុគ្រោះ ។

សូមលោកប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

សូមភ្ជាប់មកជាមួយនឹងឈ្មោះសហគមន៍ទាំង ៣៦ រូប មួយច្បាប់ ។

ភ្នំពេញ,ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៦



ឡោ ស៊ីហា　　ចាន់ វិចិត្រ　　ហ៊ែម ឡាល　　សួន ស៊ីណាត

តារាងឈ្មោះគណៈកម្មការសហគមន៍

នៅក្នុងភូមិ២ និង ភូមិ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ដែលបានលួចចុះកិច្ចសន្យាដូរដីជាមួយក្រុមហ៊ុន សេវ៉េន អ៊ិនជី (7NG)

កាលពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ ដោយពុំអោយប្រជាពលរដ្ឋបានដឹង

១- គីម យ៉ាន
២- ប៉ែន សុធី
៣- សម សារ៉េត
៤- អ៊ូ ណាំស្រ៊ុន
៥- លី ចាន់ភក្តី
៦- ផាន់ ណារិន
៧- ពុំ សុខអេង
៨- ជួប លុន
៩- ជា ថុល
១០- សួង ទឿ
១១- អ៊ុច សាមឿន
១២- សឹន យីគួ
១៣- ជុន ឌី
១៤- ស៊ឹម ស៊ី
១៥- សឹន សុខហេង
១៦- សឹក សុខ
១៧- ណា ប៉ាង
១៨- ហែម សាមុំ
១៩- ឡាង គីមហួរ
២០- វិត ណារី
២១- ពុក សុធា
២២- សង ឆេងរី
២៣- សួស សារ៉េត
២៤- គង់ សី
២៥- សួន សៀត
២៦- ម៉េង សួង
២៧- ម៉ម ព្រឿង
២៨- នូ ពៅ
២៩- យេ សារិន
៣០- អ៊ុំ យ៉ន
៣១- គីម ហួរ
៣២- កង សុផាត
៣៣- យ៉ែម យុត្តានី
៣៤- ញ៉ែម សុវណ្ណ
៣៥- ព្រំ ចាន់ថុល
៣៦- ព្រំ អេង





សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម - ឯកសាររបស់អង្គការ លីកាដូ កាណាដា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការ អមតុលាការ

ក្រុងភ្នំពេញ

******

លេខ ៩៦

ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៦

សំណុំរឿង [illegible]

លេខ 1857

ចុះថ្ងៃទី០៤ ខែ ១០ ឆ្នាំ2006

## សេចក្ដីសុំប្ដឹងតវ៉ា

ឆ្នាំពីរពាន់ ប្រាំមួយ ខែ តុលា ថ្ងៃទី ដប់ពីរ វេលាម៉ោង [illegible]

យើង ហ៊ុន ប៊ុនហួរ ក្រឡាបញ្ជីអយ្យការអមតុលាការក្រុងភ្នំពេញ

បានឃើញឈ្មោះ [illegible] 305 [illegible] ថ្ងៃទី 29 ខែ កញ្ញា ឆ្នាំ 2006 [illegible]

ឈ្មោះនេះទទួលថានឹងធ្វើពាក្យប្ដឹងបន្ថែមអោយទាន់ពេលវេលា ក្រែងពុំប្រាកដ យើងសូត្រសេចក្ដីនេះ អោយឈ្មោះ [illegible] ស្ដាប់ ហើយអោយចុះហត្ថលេខា ឬផ្ដិតមេដៃ ជាមួយយើង ។

អ្នកប្ដឹង

ស្នាមមេដៃ ឬហត្ថលេខា

[illegible]

ក្រឡាបញ្ជី

ហត្ថលេខា

ហ៊ុន ប៊ុនហួរ

បានឃើញ

ភ្នំពេញថ្ងៃទី១២ ខែតុលា ឆ្នាំ ២០០៦

ព្រះរាជអាជ្ញា

អ៊ុក_សាវុធ

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញថ្ងៃទី១២ ខែ តុលា ឆ្នាំ ២០០៦

ក្រឡាបញ្ជី

ហ៊ុន ប៊ុនហួរ

**ឧបសម្ព័ន្ធទី១៥**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមតុលាការ
ក្រុងភ្នំពេញ

## លិខិតជូនដំណឹង

លេខ : [illegible]

យើង [illegible] ព្រះរាជអាជ្ញា អយ្យការអមតុលាការក្រុងភ្នំពេញ

ជំរាបមក

លោក-លោកស្រី [illegible]
ទីលំនៅបច្ចុប្បន្ន [illegible]
ត្បិតពាក្យបណ្តឹងរបស់លោក-លោកស្រី ប្តឹងពីឈ្មោះ [illegible]
ទីលំនៅបច្ចុប្បន្ន [illegible]
ពីដំណើររឿង [illegible]
នោះយើងបានសំរេច [illegible]
តាមដីកាសំរេចលេខ [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ 2006 រួចហើយ ។

"១" លោក-លោកស្រី មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

[illegible] ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦
ព្រះរាជអាជ្ញា

ង៉ែត សារ៉ាវុធ

[illegible]
ថ្ងៃ [illegible] ២០០៦

[illegible]

កំណត់សំគាល់ : "១" មានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល២ខែ គិតពីថ្ងៃបានទទួលលិខិតជូនដំណឹងនេះ ។

**ឧបសម្ព័ន្ធទី១៦**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខណ្ឌចំការមន

សាលាសង្កាត់ទន្លេបាសាក់

លេខ.០១៩/០៦.ស.ទ.បស

## សេចក្តីជូនដំណឹង

**យោង:** - សេចក្តីជូនដំណឹងលេខ ០១៥/០៦ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៦

- សេចក្តីជូនដំណឹងលេខ ០១៧/០៦ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៦

របស់សាលាសង្កាត់ទន្លេបាសាក់

សាលាសង្កាត់ទន្លេបាសាក់ សូមជំរាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅសហគមន៍ទាំង ៧ ក្នុងភូមិ១ ភូមិ២ និង ភូមិ១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន បានជ្រាបថា :

កន្លងមកសាលាសង្កាត់ទន្លេបាសាក់ បានចេញសេចក្តីជូនដំណឹងជាបន្តបន្ទាប់ជូនចំពោះបងប្អូនមួយចំនួនដែលឆ្លៀតឱកាសយកបង្គោលបោះរបងហ៊ុំព័ទ្ធលើទីតាំងដីដែលបានរុះរើផ្ទះរួចនិងដីប្រហោងចន្លោះ។ មួយផ្នែកទៀតក៏មានតសំយ៉ាប-ជួសជុលបន្ថែម-បាំងជញ្ជាំងកន្លែងរោងលក់ដូរដើម្បីអោយក្លាយជាផ្ទះស្នាក់នៅ ធ្វើអោយការអភិវឌ្ឍន៍មានដំណើរយឺតយ៉ាវ ។

ដូចនេះ ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ ចៀសវាងភាពអនាធិបតេយ្យ សូមបងប្អូនទាំងឡាយណាដែលបានបោះបង្គោលរបងហ៊ុំព័ទ្ធ តសំយ៉ាបពង្រីកបន្ថែមនិងបាំងជញ្ជាំងរោងលក់ដូរដើម្បីអោយក្លាយជាផ្ទះ ស្នាក់នៅនោះមេត្តារុះ រើចេញដោយខ្លួនឯងក្នុងរយះពេល ០៣ថ្ងៃ គិតចាប់ពីថ្ងៃដែលបានចេញសេចក្តីជូនដំណឹងនេះ ។

មួយវិញទៀតចំពោះបងប្អូនដែលមានផ្ទះជួលអោយអ្នកដទៃស្នាក់នៅ សូមបងប្អូនជាម្ចាស់ផ្ទះជំរាបឱ្យអ្នកជួលចេញទៅរកលំនៅដ្ឋានថ្មី ហើយបងប្អូនដែលជាម្ចាស់ផ្ទះ មេត្តាអញ្ជើញមកទំនាក់ទំនងជាមួយ អាជ្ញាធរមូលដ្ឋានដើម្បីបំពេញទំរង់បែបបទទៅយកផ្ទះថ្មីនៅតំបន់អភិវឌ្ឍន៍ ក្នុងរយះពេលមួយសប្តាហ៍ ។

បើហួសកាលបរិច្ឆេតខាងលើនេះ មានបងប្អូនណាដែលមិនអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះទេ សាលាសង្កាត់ទន្លេបាសាក់និងមានវិធានការរុះរើ ហើយមិនទទួលខុសត្រូវលើការខូចខាតសំភារះ និងផ្ទះសម្បែងរបស់បងប្អូនឡើយ ។

សាលាសង្កាត់ទន្លេបាសាក់ សង្ឃឹម និង ជឿជាក់លើស្មារតីអនុវត្តសេចក្តីជូនដំណឹងនេះអោយមានប្រសិទ្ធភាពនិងដោយសន្តិវិធី ។

ភ្នំពេញ. ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**ចៅសង្កាត់ទន្លេបាសាក់**

[illegible]

**ចម្លងជូន :**

- សាលាខណ្ឌចំការមន
- អធិការដ្ឋាននគរបាលខណ្ឌចំការមន
- កងរាជអាវុធហត្ថខណ្ឌចំការមន

" ដើម្បីជូនជ្រាប "

- នគរបាលប៉ុស្តិ៍រដ្ឋបាលទន្លេបាសាក់
- ប្រធានភូមិ ១.២.១៥

" ដើម្បីអនុវត្ត "

- ឯកសារ. កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១៧ (ក)

ឈ្មោះដី : ........ លេខក្បាលដី : ឆ 2

ផ្ទៃដី : ........ ប៊្លូតិ៍លេខ : 122

F : 96

ព្រំប្រទល់ :

ខាងជើង : ........ ផ្លូវ ៥៧ស៊ុ ........

ខាងត្បូង : ........ ផ្លូវ ៥៧ស៊ុ ........

ខាងកើត : ........ ផ្លូវ ៥៧ស៊ុ ........

ខាងលិច : ........ ផ្ទះលេខ 124 ........

ចំការមន ថ្ងៃទី 14 ខែ ធ្នូ ឆ្នាំ 2006

ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

### ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ

លេខ : គព 09413

សង្កាត់ : ........ ទន្លេបាសាក់

ខណ្ឌ : ........ ចំការមន

ក្រុង : ........ ភ្នំពេញ

ភ្នំពេញ ថ្ងៃទី 14 ខែ ធ្នូ ឆ្នាំ 2006

ត.ប រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី

រាជធានីភ្នំពេញ

ឆាយ_ឫទ្ធិសែន



សេចក្តីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម – ឯកសាររបស់អង្គការ លីកាដូ កាណាដា

# ឧបសម្ព័ន្ធទី១៧ (ខ)

លេខ : 255 IV 0116

សន្លឹកបញ្ជីលេខ S 17

| ពិពណ៌នាក្បាលដី | | | | អត្រានុកូលដ្ឋានអ្នកកាន់កាប់ | | | | ការផ្លាស់ប្ដូរ | | |
|---|---|---|---|---|---|---|---|---|---|---|
| ប្រភេទដី | ទំហំ | | | នាមត្រកូល និងនាមខ្លួន ទាំងប្ដី ប្រពន្ធ | ថ្ងៃ ខែ ឆ្នាំ និងស្រុកកំណើត | សាវតារ | លេខរៀង | សេចក្ដីដកស្រង់ដោយសង្ខេបនៃលិខិត សញ្ញា និងសាលក្រមតុលាការ | [illegible] | សេចក្ដីផ្សេងៗ |
| | ហ | អ | ស | | | | | | | |
| [illegible] | 02 | 03 | 95 | ក្រុមហ៊ុន 7 អិនជីខន - ស្ត្រាក់សិន ខូអិលធីឌី | | | | ផ្ទេរ មកក្រុមហ៊ុន 7 អិនជីខនស្ត្រាក់ - សិន ខូអិលធីឌី តាមកំណត់ហេតុ [illegible] ថ្ងៃ 13.12.2006 លេខ 5 Aa013/06 | | [illegible] 559 [illegible] ចុះថ្ងៃ 04-4-2006 [illegible] 130/05 [illegible] ចុះថ្ងៃ 19-01-2005 |



សេចក្ដីពន្យល់ករណីដីធ្លីនៅសហគមន៍ដីក្រហម - ឯកសាររបស់អង្គការ លីកាដូ កាណាដា

**ឧបសម្ព័ន្ធទី១៨**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខណ្ឌចំការមន
សាលាសង្កាត់ទន្លេបាសាក់
លេខ :០០៧/០៧...ស.ជ.ណ

ភ្នំពេញ,ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៧

# សេចក្ដីជូនដំណឹង

<u>យោង</u> : លិខិតលេខ ១០៨ ឆ.ត.ស ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៧ របស់សាលាក្រុងភ្នំពេញ ។

ចៅសង្កាត់ទន្លេបាសាក់សូមជូនដំណឹងដល់ប្រជាពលរដ្ឋ នៅសហគមន៍ដីក្រហម ភូមិ២ និងភូមិ ១៥ អោយបានជ្រាបថា : ដើម្បីរក្សាសុវត្ថិភាពសណ្ដាប់ធ្នាប់ក្នុងមូលដ្ឋានអោយបានល្អប្រសើរ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ដែលមានលំនៅដ្ឋានក្នុងតំបន់សហគមន៍ដីក្រហមភូមិ២ និងភូមិ១៥ រក្សាភាពស្ងប់ស្ងៀម និងកុំបន្តការសាងសង់បន្ថែមថ្មីទៀតអោយសោះ ។ ពិសេសចំពោះបងប្អូនយើងមួយចំនួនបានធ្វើការតយ៉ាបក្នុងអំឡុងពេលបោះឆ្នោតក្រុមប្រឹក្សាសង្កាត់អាណត្តិទី២ កន្លងមកនេះ។ សូមបងប្អូនរុះរើដោយខ្លួនឯងវិញ ក្នុងរយៈពេល១៥ថ្ងៃ គិតចាប់តាំងពីថ្ងៃជូនដំណឹងនេះតទៅ ។

ខាងលើនេះ សូមបងប្អូនយោគយល់ អ្វីដែលមានចាស់សូមរក្សានៅដដែល កុំបន្តរសកម្មភាពអ្វីអោយវាខុសនឹងលំនាំដើម ។ មួយផ្នែកទៀតចំពោះបងប្អូនដែលតាំងកន្លែងលក់ដូរញើទ្រូងផ្លូវ សូមមេត្តាបញ្ឈប់ការដាក់លក់លើទីតាំងនេះជាបន្ទាន់។ ព្រោះកន្លងមកធ្វើអោយផ្លូវនេះតូចចង្អៀត ដែលអាចបង្ករអោយមានគ្រោះថ្នាក់ចរាចរជាយថាហេតុនិងបាត់បង់សណ្ដាប់ធ្នាប់សាធារណៈ ។

ក្នុងករណីមិនស្ដាប់តាមការណែនាំ និងជូនដំណឹងនេះ សាលាសង្កាត់ និងមានវិធានការស្របច្បាប់ដោយពុំទទួលខុសត្រូវលើការខូចខាតបាត់បង់ផលប្រយោជន៍ និងសំភារៈបងប្អូនឡើយ ។

សាលាសង្កាត់មានជំនឿជឿជាក់ថាបងប្អូន និងអនុវត្តតាមសេចក្ដីជូនដំណឹងនេះ ។

ចៅសង្កាត់ទន្លេបាសាក់

កាន់_ណារិទ្ធ

<u>ចំលងជូន</u> :
- សាលាខណ្ឌចំការមន
- អធិការនគរបាលខណ្ឌចំការមន
- បញ្ជាការកងរាជអាវុធហត្ថខណ្ឌចំការមន

(ដើម្បីជូនជ្រាប)
- នគរបាលប៉ុស្តិ៍
- ប្រធានភូមិ ២ , ភូមិ ១៥

(ដើម្បីអនុវត្ត)
- ឯកសារ

**ឧបសម្ព័ន្ធទី១៩**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង

[illegible]

*******

សំណុំរឿង [illegible]

លេខ : [illegible]

## ដីកាកោះ

យើង [illegible] តុលាការខេត្ត-ក្រុង [illegible]

អញ្ជើញឈ្មោះ [illegible] ជា [illegible]

ទីលំនៅសព្វថ្ងៃ [illegible]

អោយចូលទៅកាន់ [illegible]

នៅថ្ងៃទី 27 ខែ 08 ឆ្នាំ 2007 វេលាម៉ោង 7:30 [illegible]

ដើម្បី [illegible]

ពីដំណើរ [illegible]

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះអោយបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅ [illegible] ថ្ងៃទី 16 ខែ 8 ឆ្នាំ 2007

"១"

**ឧបសម្ព័ន្ធទី២០ (ខ)**

**ក្រុមការងារពិសេសសិទ្ធិលំនៅឋាន**

Housing Rights Task Force (HRTF)

ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០៧

*សម្រាប់ការចេញផ្សាយជាបន្ទាន់*

*សេចក្តីថ្លែងការណ៍ និង រូបថត*

**ការប្រើកម្លាំងហួសហេតុក្នុងការបណ្តេញប្រជាពលរដ្ឋនៅសហគមន៍ដីក្រហម**

ក្រុមការងារពិសេសសិទ្ធិលំនៅឋាន សូមថ្កោលទោសចំពោះលក្ខណៈនិងវិធីសាស្ត្រដែលបានប្រើដោយកងរាជអាវុធហត្ថ និងក្រុមហ៊ុនសេវិនអិនជី (7NG) នៅក្នុងការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅឋាននៅភូមិដី ក្រហមនៃខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៧។ ជាពិសេសយើងខ្ញុំសូមបដិសេធចំពោះការប្រើ "ក្រុមកម្មករសំណង់" ប្រដាប់ដោយដំបងដែកនិងកាំបិត ក្នុងការបំបែកក្រុមអ្នកភូមិ. បដិសេធការប្រើកម្លាំងក្នុងការដាក់ខ្នោះប្រជាពលរដ្ឋ និងការសម្រេចដោយកងនគរបាលដែលមិនព្រមការពារអ្នកភូមិ នៅពេលដែលបុគ្គលិករបស់ក្រុមហ៊ុន 7NG ប្រើកម្លាំងបាយបំពានលើអ្នកស្រី។

លោក ប៉ា សុជាតិវង្ស អភិបាលរងក្រុងភ្នំពេញ បានមានប្រសាសន៍ថាព្រឹត្តិការណ៍ដែលបានកើតឡើងនោះជា "ការប្រឈមមុខគ្នាតូចមួយដោយគ្មានអំពើហិង្សា" (*អត្ថបទរបស់កាសែត ឌឹ ឃែមបូឌា ដេលី ចុះផ្សាយថ្ងៃទី៣០ខែសីហាឆ្នាំ២០០៧*) គឺជាការនិយាយបំភាន់និងមិនត្រឹមត្រូវទេ។ តាមភស្តុតាងរូបថតនិងវីដេអូបានបង្ហាញយ៉ាងច្បាស់ថា មានប្រើកម្លាំងយ៉ាងហួសហេតុដោយកងនគរបាល។

ជាឧទាហរណ៍ជាក់ស្តែង ស្ត្រីដែលគ្មានអាវុធរូបនោះបានតវ៉ាដោយសន្តិវិធីចំពោះការរុះរើទីជម្រកជាច្រើននៅក្នុងសហគមន៍នេះ នៅពេលនោះតំណាងក្រុមហ៊ុន 7NG ដែលមានខ្នោះបានចូលទៅចាប់អ្នកស្រីផ្តួលលើដីដោយមានកងរាជអាវុធហត្ថជួយ។ តំណាងក្រុមហ៊ុន 7NG ក្រោយមកក៏បានឱ្យខ្នោះទៅកងរាជអាវុធហត្ថម្នាក់ ដើម្បីដាក់ខ្នោះដៃអ្នកស្រី។

ក្រុមការងារពិសេសសិទ្ធិលំនៅឋាន សូមសំដែងនូវការបារម្ភចំពោះករណីដូចខាងក្រោមនេះ:

- កងរាជអាវុធហត្ថមិនគួរមានវត្តមាននៅទីនោះទេ ព្រោះថាករណីនោះវាពាក់ព័ន្ធតែជាមួយប្រជាពលរដ្ឋស៊ីវិលតែប៉ុណ្ណោះ ហេតុដូច្នេះហើយ វាមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនទេ។
- កងរាជអាវុធហត្ថខ្លះបានដោះផ្លាកឈ្មោះរបស់ខ្លួនចេញពីឯកសណ្ឋានរបស់ខ្លួន។
- កម្មករសំណង់ដែលមានកាន់ដំបងដែកស្រួចត្រូវបានបញ្ជាជាច្រើនលើកច្រើនសារដោយមន្ត្រីនគរបាលជាន់ខ្ពស់ ដើម្បីបំបែកក្រុមអ្នកតវ៉ាដោយសន្តិវិធីនោះ។ ការប្រើកម្មករស៊ីឈ្នួលទាំងនោះដើម្បីបំបែកក្រុមអ្នកតវ៉ាដោយអហិង្សា អាចបណ្តាលឱ្យមានការប្រឈមមុខដាក់គ្នាយ៉ាងងាយបំផុត នៅពេលដែលក្រុមកម្មករ

Address: #54, Street 306, Sangkat Boeung Keng kong I, Khan Chamkarmorn, Phnom Penh
Contact: Tel: (855) 23 215 590, Fax: (855) 23 211 723, E-mail: cam.hrtf@gmail.com

សំណង់ទាំងនោះមានអាវុធនៅដៃនិងរុញច្រានក្រុមអ្នកតវ៉ាដោយកម្លាំងបាយ ។ ការធ្វើរបៀបនេះធ្វើឱ្យមានបញ្ហាថា តើកងរាជអាវុធហត្ថព្យាយាមចង់បានអ្វីតាមរយៈប្រើវិធីនេះ ។

- កងនគរបាលនិងកងរាជអាវុធហត្ថមិនបានព្យាយាមគ្រប់គ្រាន់ដើម្បីបំបែកស្ថានភាពតានតឹង ឬព្យាយាមបំបាត់សភាពគ្រោះថ្នាក់ដែលកាន់តែកើនឡើង ដែលនៅក្នុងនោះគេដឹងថា ពិតជាមានស្ថានភាពតានតឹងយ៉ាងខ្លាំងនៅកន្លែងដ៏តូចចង្អៀតដូច្នេះ ។ ឧទាហរណ៍ គេមានកាំភ្លើងខ្លីជាប់នឹងខ្លួន ដែលមានមួយនោះធ្លាក់មកដី ដែលអ្នកឈរមើលនៅជុំវិញនោះអាចរើសយកបានយ៉ាងងាយ (នៅក្នុងរូបថតមួយបង្ហាញយ៉ាងច្បាស់ ថាមានដៃពីរផ្សេងគ្នាកំពុងឈោងយកកាំភ្លើងខ្លីនោះ) ។
- ទោះបីជាមានវត្តមានរបស់កងនគរបាល និងកងរាជអាវុធហត្ថក៏ដោយ គឺតំណាងរបស់ក្រុមហ៊ុនទេដែលព្យាយាមប្រើកម្លាំងដាក់ខ្នោះសមាជិកសហគមន៍ដែលគ្មានអាវុធទៅវិញ ។ តាមផ្លូវច្បាប់ តំណាងរបស់ក្រុមហ៊ុនឯកជនរូបនោះ គ្មានមូលដ្ឋានណាមួយក្នុងការឃុំខ្លួនប្រជាពលរដ្ឋឡើយ ។
- ក្រោយពីព្រឹត្តិការណ៍ដាក់ខ្នោះនោះ ប្រជាពលរដ្ឋនៅក្នុងសហគមន៍ បាននាំគ្នាដើរ ដោយមានស្ត្រីដែលជាប់ខ្នោះនោះ ទៅរដ្ឋសភា ។ នៅទីនោះ មុនដំបូងកងនគរបាលបានបដិសេធថាមិនបានដាក់ខ្នោះស្ត្រីរូបនោះទេ ព្រមទាំងបាននិយាយថា គេមិនដឹងថាអ្នកណាមានកូនសោ ។ អ្នកស្រីនៅជាប់ខ្នោះយ៉ាងដូច្នោះអស់រយៈពេលជាច្រើនម៉ោង ។

ជាថ្មីម្តងទៀត ក្រុមការងារពិសេសសិទ្ធិលំនៅឋាន សូមអំពាវនាវសុំឱ្យបញ្ឈប់ជាបណ្តោះអាសន្នចំពោះការរុះរើនោះ រហូតដល់មានដំណើរការត្រឹមត្រូវមួយដើម្បីធានាបាននូវការការពារសិទ្ធិមនុស្សនិងសិទ្ធិប្រជាពលរដ្ឋដូចមានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ម្យ៉ាងទៀត ក្រុមការងារពិសេសសិទ្ធិលំនៅឋាន សូមអំពាវនាវ សុំឱ្យបញ្ឈប់ជាបន្ទាន់ចំពោះវិធីសាស្ត្រដែលឱ្យកម្មករសំណង់ឯកជនដោយគាំទ្រពីកងនគរបាល បំបែកក្រុមអ្នកតវ៉ានោះ ។ ចុងក្រោយនេះ យើងសូមអំពាវសុំបញ្ចប់ជាបន្ទាន់ចំពោះការបណ្តេញប្រជាពលរដ្ឋដោយប្រើកម្លាំង ។

លើសពីនេះទៅទៀត ក្រុមការងារពិសេសសិទ្ធិលំនៅឋាន សូមរំលឹករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអំពីការទទួលខុសត្រូវរបស់ខ្លួន ក្នុងការការពារជនដែលងាយរងគ្រោះនៅសហគមន៍ និងសូមរំលឹកថា គម្រោងដីធ្លីទ្រង់ទ្រាយធំបែបនេះមិនត្រូវរំលោភលើសិទ្ធិប្រជាពលរដ្ឋនៅតាមសហគមន៍ឡើយ ។

*សូមមើលរូបថតពីរខាងក្រោមនេះ ដែលបង្ហាញពីព្រឹត្តិការណ៍ដាក់ខ្នោះ នៅថ្ងៃទី២៩ខែសីហាឆ្នាំ២០០៧ ។*

Address: #54, Street 306, Sangkat Boeung Keng kong I, Khan Chamkarmorn, Phnom Penh
Contact: Tel: (855) 23 215 590, Fax: (855) 23 211 723, E-mail: cam.hrtf@gmail.com

*ក្រុមការងារពិសេសសិទ្ធិលំនៅឋាន គឺជាសម្ព័ន្ធភាពមួយដែលបង្កើតឡើងដោយអង្គការជាតិ និងអន្តរជាតិ ជាង២០អង្គការ ដែលបូជាកម្លាំងនិងពេលវេលាចំពោះការងារការពារសិទ្ធិលំនៅឋាន និងបញ្ឈប់អំពើរំលោភសិទ្ធិលំនៅឋាន រួមមានដូចជា ការបណ្តេញដោយបង្ខំដែលមិនត្រឹមត្រូវតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ជាតិ។ ក្រុមការងារពិសេសសិទ្ធិលំនៅស្ថានកំពុងបំពេញបេសកកម្មដើម្បី គាំទ្រសកម្មភាពរបស់សហគមន៍ និងពង្រឹងអង្គការសង្គមស៊ីវិលដើម្បីលើកកំពស់សិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង: លោក ផាន់ ស៊ីថាន លេខាធិការដ្ឋានក្រុមការងារពិសេសសិទ្ធិលំនៅឋាន ទូរស័ព្ទលេខ: ០២៣ ២១៥ ៥៩០ អ៊ីម៉ែល: cam.hrtf@yahoo.com ។*





Address: #54, Street 306, Sangkat Boeung Keng kong I, Khan Chamkarmorn, Phnom Penh
Contact: Tel: (855) 23 215 590, Fax: (855) 23 211 723, E-mail: cam.hrtf@gmail.com

**ឧបសម្ព័ន្ធទី២១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

យើងខ្ញុំទាំងអស់គ្នាជាប្រជាពលរដ្ឋក្នុងសហគមន៍ដីក្រហម ចំនួន ៣០៤គ្រួសារ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**សូមគោរពជូន**

**សម្តេច ហេង សំរិន ប្រធានរដ្ឋសភា**

**ជាទីគោរពដ៏ខ្ពង់ខ្ពស់។**

**កម្មវត្ថុ** : -ស្នើសុំអភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែងលើដីសម្បទានសង្គមកិច្ច សុំបំណ្ណកម្មសិទ្ធិកាន់កាប់ និងសុំឱ្យក្រុមហ៊ុន សេវែនអ៊ិនជី (7NG Construction) និងអាជ្ញាធរបញ្ឈប់ការប្រើប្រាស់អំពើហិង្សាមកលើប្រជាពលរដ្ឋ។

**យោង** : -សេចក្តីជូនដំណឹងលេខ៨៧៥ សជណ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

-របាយការណ៍លេខ១៧០/០៤របក របស់សាលាខណ្ឌចំការមន ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៤ ។

-អនុក្រឹត្យលេខ ១៩ អនក្រ.បក ស្តីពីដីសម្បទានសង្គមកិច្ច ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំទាំងអស់គ្នាជាប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ដីក្រហម មានកិត្តិយសសូមជំរាបជូនសម្តេចប្រធានរដ្ឋសភា មេត្តាជ្រាបៈកាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៣ ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញសេចក្តីជូនដំណឹងដោយយោងតាមចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** អនុញ្ញាតឱ្យសាលាក្រុងភ្នំពេញរៀបចំដីសម្បទានសង្គមកិច្ចទំហំ ៣.៧០ហិកតា ជូនសហគមន៍ដីក្រហមដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែង ។

ចាប់តាំងពីថ្ងៃដែលរាជរដ្ឋាភិបាល ដែលមានសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ជាប្រមុខបានសម្បទានដីសង្គមកិច្ចនេះជូនដល់យើងខ្ញុំទាំងអស់គ្នាដើម្បីអភិវឌ្ឍន៍លំនៅដ្ឋាន យើងខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំង ព្រោះសម្តេចបានផ្តល់ឱ្យយើងខ្ញុំទាំងអស់គ្នាមានដីធ្លីដើម្បីរស់នៅដោយសមរម្យសំរាប់ក្រុមគ្រួសារ និងកូនចៅ ដែលអាចរស់នៅ រៀនសូត្រ និងប្រកបកិច្ចការងារផ្សេងៗក្នុងទីក្រុងបានដូចគេឯងដទៃទៀត ។

ប៉ុន្តែនៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៥ តំណាងសហគមន៍ទាំង ៧ ដែលមានសមាជិកទាំងអស់ ៣៦ រូប បានឃុបឃិតគ្នាលួចចុះកិច្ចសន្យាធ្វើការដោះដូរលំនៅដ្ឋានជាមួយនឹងក្រុមហ៊ុនសេវែនអ៊ិនជី (7NG Construction) លើទីតាំងថ្មីដែលស្ថិតនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ដោយពុំបានពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ឡើយ ។ លុះដល់ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៥ ទើបលោកចៅសង្កាត់ទន្លេបាសាក់ កោះប្រជុំប្រាប់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ដីក្រហម ដោយនិយាយថា នេះជាសិទ្ធិរបស់បងប្អូនក្នុងការសំរេចចិត្តដូរ ឬមិនដូរ គ្មាននរណាបង្ខំបងប្អូនឡើយ ។

ក្រោយពេលបានដឹងពីបញ្ហានេះ យើងខ្ញុំបានធ្វើការប្តឹងទាស់ទៅនឹងកិច្ចសន្យានេះគ្រប់សមត្ថកិច្ច និងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ដើម្បីធ្វើការដោះស្រាយឱ្យយើងខ្ញុំបានអភិវឌ្ឍន៍លំនៅដ្ឋានតាមប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលបានប្រកាសនៅក្នុងឱកាសខួប ៥ឆ្នាំ របស់អង្គការមូលនិធិកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង ឱ្យយើងខ្ញុំអភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែង ។

សម្តេចជាទីគោរព! ចាប់តាំងពីយើងខ្ញុំបានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរដែនដី និងសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ដើម្បីសុំឱ្យជួយដោះស្រាយនោះ ពុំមានអាជ្ញាធរណាមួយចេញមុខដោះស្រាយឱ្យឡើយរហូតមកទល់នឹងពេលនេះ ។ ផ្ទុយទៅវិញមានតែការគាបសង្កត់ បំភិតបំភ័យ និងគំរាមកំហែងគ្រប់សព្វបែបយ៉ាងពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីបណ្តេញយើងខ្ញុំឱ្យទៅរស់នៅតំបន់ថ្មី ជាក់ស្តែងដូចជានៅព្រឹកថ្ងៃ ពុធ ទី ២៩ ខែ សីហា ឆ្នាំ ២០០៧ ក្រុមហ៊ុន និងអាជ្ញាធរបាននាំកំលាំងប៉ូលីស ប៉េអឹម មកវាយធ្វើបាប ដាក់ខ្នោះ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិប្រជាពលរដ្ឋស្លូតត្រង់ និងគំរាមបាញ់សម្លាប់ ដុតផ្ទះប្រសិនបើមិនព្រមចាកចេញពីដីនេះទេនោះ។ ទង្វើទាំងនេះ ធ្វើឱ្យយើងខ្ញុំទាំងអស់គ្នាដែលជាប្រជាពលរដ្ឋមិនអាចទទួលយកបានឡើយ ព្រោះការដែលអាជ្ញាធរ និងក្រុមហ៊ុនយកកំលាំងមកធ្វើបាប ដើរគំរាមកំហែងប្រជាពលរដ្ឋគឺជាអំពើមួយដែលផ្ទុយទៅនឹងច្បាប់ទាំងស្រុង មិនតែប៉ុណ្ណោះ ពេលដែលយើងខ្ញុំដែលជាប្រជាពលរដ្ឋជួបប្រទះនូវការរំលោភបំពានពីសំណាក់បុគ្គលិករបស់ក្រុមហ៊ុន ឬអាជ្ញាធរ ហើយប្តឹងទៅសមត្ថកិច្ចនោះ មិនដែលឃើញមានដំណោះស្រាយម្តងណាឡើយ។ ការនេះ ធ្វើឱ្យយើងខ្ញុំអស់សង្ឃឹមយ៉ាងខ្លាំង ដូចដែលសម្តេចធ្លាប់បានជ្រាបពីមុនរួចមកហើយពីសេចក្តីទុក្ខវេទនារបស់ប្រជាពលរដ្ឋ ដែលជាកូនចៅរបស់សម្តេច និងភាពព្រងើយកន្តើយរបស់អាជ្ញាធរ ចាប់តាំងពីពេលដែលអាជ្ញាធរ និងក្រុមហ៊ុនចង់ធ្វើការរុះរើផ្សារ និងមិនឱ្យប្រជាពលរដ្ឋលក់ដូរបន្តទៅទៀតលើដីសាធារណៈមកម្ល៉េះ ។

មិនតែប៉ុននោះ សម្តេចក៏ធ្លាប់មានចំណារឱ្យឯកឧត្តម កែប ជុតិមា ដោះស្រាយបញ្ហានេះ ប៉ុន្តែរហូតមកសព្វថ្ងៃយើងខ្ញុំពុំទទួលបានដំណោះស្រាយសមស្របណាមួយពីសាលាក្រុងភ្នំពេញឡើយ។ ផ្ទុយទៅវិញមានតែការគាបសង្កត់តាមគ្រប់មធ្យោបាយ ដើម្បីបង្ខំឱ្យប្រជាពលរដ្ឋចាកចេញ រហូតដល់មានការប្រើអំពើហិង្សាថែមទៀតផង។

សម្តេចជាទីគោរព! ដើម្បីអាចអភិវឌ្ឍន៍លំនៅដ្ឋាន ឱ្យបានសមស្របទៅនឹងគោលការណ៍របស់សាលាក្រុងភ្នំពេញ និងប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលបានមានប្រសាសន៍នៅក្នុងឱកាសខួប ៥ ឆ្នាំ របស់អង្គការមូលនិធិកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង ដែលបានអនុញ្ញាតិឱ្យយើងខ្ញុំអភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែង យើងខ្ញុំទាំងអស់គ្នាសុំគោលការណ៍អនុញ្ញាតពីសម្តេច ដើម្បីធ្វើការបែងចែកផ្ទៃដីជាមួយនឹងក្រុមហ៊ុនសេវែនអ៊ុនជី (7NG Construction) លើចំណែកផ្ទៃដីសម្បទានសង្គមកិច្ច និងសុំប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លី ដើម្បីធ្វើការអភិវឌ្ឍន៍លំនៅដ្ឋានដោយខ្លួនឯងលើចំណែកដីដែលយើងខ្ញុំបានកាន់កាប់ជាង ១.៩០ ហិកតា ដោយធ្វើការសាងសង់អនុវត្តតាមប្លង់ ដែលគូរដោយអង្គការក្រៅរដ្ឋាភិបាលដូចមានភ្ជាប់មកជាមួយ និងដោយគោរពយ៉ាងត្រឹមត្រូវទៅតាមបទដ្ឋានបច្ចេកទេសសំណង់របស់សាលាក្រុងភ្នំពេញ និងក្រសួងរៀបចំដែនដីនគរូបនីយកម្មសំណង់និងសុរិយោដី ព្រោះបច្ចុប្បន្ននេះ យើងខ្ញុំទាំងអស់គ្នាមានថវិកាមួយចំនួនបំរុងទុក និងមានអង្គការមួយចំនួនទៀតព្រមផ្តល់ជាឥណទានរយៈពេលវែងសំរាប់ឱ្យយើងខ្ញុំអាចមានលទ្ធភាពសាងសង់អាគារសំរាប់រស់នៅបានដោយខ្លួនឯង។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ សូមសម្តេចមេត្តាអនុញ្ញាតជាគោលការណ៍ដើម្បីឱ្យយើងខ្ញុំទាំងអស់គ្នាអាចអភិវឌ្ឍន៍លំនៅដ្ឋានបាននៅនឹងកន្លែង មានកម្មសិទ្ធិរស់នៅដោយស្របច្បាប់ និងជៀសផុតពីការគំរាមកំហែង និងការប្រើអំពើហិង្សាពីសំណាក់អាជ្ញាធរ និងក្រុមហ៊ុនមកលើយើងខ្ញុំដែលជាប្រជាពលរដ្ឋ។ សូមសម្តេច ជួយឱ្យកូនចៅរបស់សម្តេចរស់នៅដោយសុខសាន្ត និងជៀសផុតពីការបំពារបំពានដោយអមនុស្សធម៌ពីសំណាក់អាជ្ញាធរដែលគ្មានឧត្តមគតិនិងពួកក្រុមហ៊ុនដែលឃើញតែពីលុយដោយមិនគិតពីសេចក្តីទុក្ខវេទនារបស់ប្រជាពលរដ្ឋដែលរស់នៅមានត្រឹមតែមួយជំរក។

សូមសម្តេច មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា និងសូមជូនពរសម្តេចសូមជួបប្រទះតែនឹងសេចក្តីសុខ និងទទួលបាននូវជ័យជំនះគ្រប់ភារកិច្ច។

ភ្នំពេញ, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៧

**តំណាងប្រជាពលរដ្ឋ**

សូមជូនភ្ជាប់មកជាមួយនូវៈ

-ស្នាមមេដៃប្រជាពលរដ្ឋក្នុងសហគមន៍ដីក្រហម

-សេចក្តីជូនដំណឹងរបស់សាលាសង្កាត់ទន្លេបាសាក់
សាលាខណ្ឌចំការមន និងសាលាក្រុងភ្នំពេញ

-រូបថតដែលអាជ្ញាធរ និងក្រុមហ៊ុនសេវ៉ែនអ៊ិនជី
(7NG Construction)បានធ្វើបាបប្រជាពលរដ្ឋ

-ប្លង់សុំអភិវឌ្ឍន៍លំនៅដ្ឋាននៅនឹងកន្លែង

-សេចក្តីជូនដំណឹងស្តីពីដីសម្បទានសង្គមកិច្ច

-របាយការណ៍ខួប ៥ ឆ្នាំ របស់អង្គការមូលនិធិកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង

-តួលេខបំពោងដែលអាជ្ញាធរ និងសហគមន៍បានឃុបឃិតគ្នា

-ឯកសារសារពត៌មាន

-ពាក្យបណ្តឹងដែលបានដាក់ទៅអាជ្ញាធរ

-មេភូមិបង្កភាពអាណាធិបតេយ្យ (បាញ់អាចោង)

-បំណ្ណសមាជិកគណៈប្រជាជនកម្ពុជា

## ឧបសម្ព័ន្ធទី២២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

[illegible] ថ្ងៃ 03 ខែ 09 ឆ្នាំ 07
[illegible]...1714

# ពាក្យបណ្តឹង

ខ្ញុំបាទ/នាងខ្ញុំ ដូចមានឈ្មោះខាងក្រោម :

១.ឈ្មោះ **ហែម វុធី** ភេទ ប្រុស អាយុ ៤៥ ឆ្នាំ ២.ឈ្មោះ **ឆន ស្រី** ភេទ ស្រី អាយុ ៤០ ឆ្នាំ

៣.ឈ្មោះ **ឡុង ស្រីលក្ខ័** ភេទ ស្រី អាយុ ៣១ ឆ្នាំ ៤.ឈ្មោះ **អ៊ុង ស៊ីនួន** ភេទ ប្រុស អាយុ ៣៦ ឆ្នាំ

៥.ឈ្មោះ **អ៊ុន សំអាត** ភេទ ស្រី អាយុ ៥៣ ឆ្នាំ និងប្រជាពលរដ្ឋចំនួន ៥៦ គ្រួសារ បច្ចុប្បន្នស្នាក់នៅក្នុងសហគមន៍ដីក្រហមភូមិ ២ និងភូមិ ១៥ សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

## សូមគោរពជូន

## លោកព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ

**កម្មវត្ថុ:** សុំប្តឹង

-លោក **ម៉ា សុភាព** អភិបាលរងខណ្ឌចំការមន រាជធានីភ្នំពេញ

-អ្នកស្រី **ប៉ែន សុធី** ប្រធានសហគមន៍ចាស់ សព្វថ្ងៃស្នាក់នៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ

-លោក ង៉ែត សំអាត ជាប៉ូលីសខណ្ឌដង្កោ និងជាអង្គរក្សនាយកក្រុមហ៊ុន 7NG

-**ក្រុមហ៊ុន 7NG** និងបក្សពួកមានទីស្នាក់ការនៅភូមិដំណាក់ត្រយឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ

**ពីបទ : ១.**បំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកដទៃដោយចេតនា

**២.**ប្រើអំពើហិង្សាមកលើប្រជាពលរដ្ឋ និងបង្ករបួសស្នាមដោយចេតនា **៣.**បង្កភាពចលាចលនៅក្នុងភូមិ។

តបតាមកម្មវត្ថុ ខាងលើយើងខ្ញុំទាំងអស់គ្នាមានកិត្តិយសសូមជំរាបលោកព្រះរាជអាជ្ញាមេត្តាជ្រាបៈ កាលពីថ្ងៃ ទី ២៩ ខែ សីហា ឆ្នាំ ២០០៧ ក្រុមហ៊ុន 7NG បាននាំកំលាំងកម្មករ និងសមត្ថកិច្ចចំរុះដែលរួមមានប៉ូលីស ប៉េអឹម ដឹកនាំដោយលោក **ម៉ា សុភាព** អភិបាលរងខណ្ឌចំការមន និងអ្នកស្រី **ប៉ែន សុធី** ប្រធានសហគមន៍ចាស់ បានចុះមកធ្វើការរុះរើ បំផ្លិចបំផ្លាញរឹបអូសយកទ្រព្យសម្បត្តិរបស់យើងខ្ញុំដែលរួមមាន តង់ គ្រែ ចាន ឆ្នាំង ចង្រ្កានហ្គាស ធុងអង្ករ មុង កន្ទេល លុយ ខោអាវ សញ្ញាប័ត្រ អត្តសញ្ញាណប័ណ្ណ.... ខ្ទេចខ្ទីអស់គ្មានសល់អ្វីឡើយ ។ មិនតែប៉ុណ្ណោះ ពួកគេបានវាយធ្វើបាបមកលើពួកយើងខ្ញុំដែលជាប្រជាពលរដ្ឋដោយគ្មានត្រាប្រណីមិនថា ក្មេង ឬ ចាស់ ស្រី ឬ ប្រុសនោះឡើយ លើសពីនេះទៅទៀតឈ្មោះ **ង៉ែត សំអាត** បានយកខ្នោះមកដាក់ពួកយើងខ្ញុំ វាយតប់ធាក់ និងគំរាមបាញ់សម្លាប់ ចាប់ដាក់គុកថែមទៀត ។ ទង្វើរបស់ពួកគេដែលបានប្រព្រឹត្តមកលើពួកយើងខ្ញុំ គឺជាទង្វើមួយដែលផ្ទុយទៅនឹងច្បាប់ និងលិខិតរដ្ឋបាលទាំងស្រុង ព្រោះនៅក្នុងសេចក្តីជូនដំណឹងរបស់សាលាក្រុងភ្នំពេញលេខ ២៧៦ ឆត.ខ ចេញថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៧ គឺឱ្យធ្វើការរុះរើតែ តង់ រោង និងគ្រែ សង់លើដីដែលប្រជាពលរដ្ឋបានរុះរើផ្ទះចេញទៅរស់នៅទីតាំងថ្មីរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយដីរបស់ក្រុមហ៊ុនដែលយកពីអ្នកដែលព្រមធ្វើការដោះដូរហើយនោះ សុទ្ធតែស្រះរបងបន្ទាលូសទាំងអស់

គ្មានអ្នកណាទៅសង់នៅពីលើឡើយ ។ ផ្ទុយទៅវិញពួកក្រុមហ៊ុន និងអាជ្ញាធរដែនដីបែរជាមកធ្វើការរុះរើ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ តង់ រោង និងគ្រែ របស់យើងខ្ញុំដែលស្ថិតនៅលើដីកម្មសិទ្ធិប្រជាពលរដ្ឋ និងនៅលើផ្លូវទៅវិញ។

មូលហេតុដូចបានជំរាបជូនខាងលើ សូមលោកព្រះរាជអាជ្ញា មេត្តាចោទប្រកាន់ និងធ្វើការផ្តន្ទាទោសលើឈ្មោះ **ម៉ា សុភាព ប៉ែន សុធី ង៉ែត សំអាត** និងក្រុមហ៊ុន7NG ទៅតាមផ្លូវច្បាប់ជាធរមាន និងទាមទារជំងឺចិត្ត និងសងថ្លៃខូចខាតចំនួន **$50,000** ( ប្រាំម៉ឺនដុល្លារអាមេរិក) ។

អាស្រ័យដូចនេះ សូមលោកព្រះរាជអាជ្ញាមេត្តារកយុត្តិធម៌ឱ្យយើងខ្ញុំជាជនរងគ្រោះដោយក្តីអនុគ្រោះ ។

សូមលោកព្រះរាជអាជ្ញា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា ។

សូមជូនភ្ជាប់មកជាមួយនូវ

-ស្នាមមេដៃប្រជាពលរដ្ឋ

-ភស្តុតាងផ្សេងៗ និងលិខិតរបស់សាលាក្រុងភ្នំពេញ

ធ្វើនៅភ្នំពេញ,ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៧

**ស្នាមមេដៃតំណាងប្រជាពលរដ្ឋ**



LICADHO

#16 Street 99, P. O. Box 499
Phnom Penh, Cambodia
Tel: (855) 23 360 965 / 364 901
Fax: (855) 23 360 965 / 217 626
or +1 (815) 550 4474
Email: contact@licadho.org
Web Site: http://www.licadho.org/

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

Media statement, September 27, 2007

## DEY KRAHORM – COMMUNITY REPRESENTATIVE UNDER THREAT OF ARREST

LICADHO is concerned that Phnom Penh police may seek to arrest a representative of the Dey Krahorm community on unjustified allegations of stealing or damaging a mobile phone.

The community representative, a woman, was involved in an incident with a 7NG company security guard during a news media conference by the Dey Krahorm community this morning. The security guard approached the woman, who was standing several meters away from the media conference, and attempted to photograph her with his mobile phone. The woman brushed the security guard's hand away, trying to prevent him from photographing her, and the phone fell to the floor. The security guard then left the area, without picking up his telephone, and made a complaint to local police that the woman had stolen his phone. The phone was later given to the police by Dey Krahorm community members.

Police took the woman to the Sangkat Tonle Basaac police station for questioning, which prompted a large crowd of Dey Krahorm villagers to gather outside the police station to seek her release. At one point, the police instructed the woman to go outside of the police station and to tell the gathered villagers to leave the area. The woman left the police station and, surrounded by villagers, fell unconscious from shock and heat. She was carried back to her home by villagers.

Police later stated that the woman had fled the police station without their permission and that they would be seeking a warrant from Phnom Penh Court for her arrest on charges relating to the security guard's mobile phone.

LICADHO believes that there is no evidence that the community representative intended to steal or to damage the security guard's mobile phone, and as such there is no justification for her arrest. The Dey Krahorm community has been subjected to repeated acts of intimidation or violence in the past weeks, and the security guard's attempt to photograph the representative should be seen in that light.

LICADHO urges the Phnom Penh police and court authorities to respect the law and not to make any arrest without sufficient evidence of a crime having been committed.

*For further information, please contact:*
Am Sam Ath, Monitoring Technical Supervisor, 012-327-770
Chheng Sophors, Investigator, 012-879-795

**ឧបសម្ព័ន្ធទី២៤**

សម្ព័ន្ធខ្មែរជំរឿនិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS

#16 Street 99, P. O. Box 499
Phnom Penh, Cambodia
Tel: (855) 23 360 965 / 364 901
Fax: (855) 23 360 965 / 217 626
or +1 (815) 550 4474
Email: contact@licadho.org
Web Site: http://www.licadho.org/

ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៧

## សេចក្តីប្រកាសព័ត៌មាន

### សកម្មភាពបង្កហេតុរបស់ក្រុមហ៊ុន សេរិន អិន ជី នៅលើប្រជាជនតំបន់ដីក្រហម

អង្គការ លីកាដូ មានការព្រួយបារម្ភជាខ្លាំងចំពោះសកម្មភាពបង្កហេតុជាបន្តបន្ទាប់ របស់ក្រុមហ៊ុន សេរិន អិន ជី ទៅលើប្រជាជនរស់នៅតំបន់ដីក្រហម ក្នុងគោលបំណងបណ្តេញពួកគាត់ចេញពីទីនោះ ។

ឧប្បត្តិហេតុចុងក្រោយបំផុតបានកើតឡើងកាលពីយប់មិញ នៅខណៈដែលបុគ្គលិករបស់ក្រុមហ៊ុន សេរិន អិន ជី មានបំណងនាំយកគ្រឿងចក្រជីកដីយ៉ាងធំចូលទៅតំបន់ដីក្រហម ដែលនេះបង្កឱ្យមានប្រតិកម្មខឹងសម្បារពីប្រជាជនក្នុងសហគមន៍ ដោយសារតែខ្លាចគ្រឿងចក្រនេះនឹងបំផ្លាញផ្ទះសំបែងរបស់ពួកគាត់ ។

នៅវេលាម៉ោងប្រហែល ៨យប់ រថយន្តដ៏ធំមួយដែលមានផ្ទុកគ្រឿងចក្រជីកដី បានឈប់នៅលើផ្លូវច្រកចូលខាងត្បូងនៃតំបន់ដីក្រហម ។ ប្រជាជនក្នុងសហគមន៍បានជួបជុំគ្នានៅលើផ្លូវនោះ និងសុំមិនឱ្យបុគ្គលិកក្រុមហ៊ុន សេរិន អិន ជី និងគ្រឿងចក្រ ចូលទៅក្នុងដីសហគមន៍របស់ពួកគេនៅពេលយប់ ។ ដោយមិនអើពើនឹងសំនើរបស់ពួកគាត់ អ្នកបើកបររថយន្តដ៏ធំនេះបានចាប់ផ្តើមបើកថយន្តចូលទៅក្នុងតំបន់ដីក្រហម ដើម្បីទំលាក់គ្រឿងចក្រចុះនៅទីនោះ ។ នៅខណៈដែលហ្វូងប្រជាជនបានមកជួបជុំគ្នា បុគ្គលិកក្រុមហ៊ុន សេរិន អិន ជី ម្នាក់ដែលស្ថិតនៅក្នុងគ្រឿងចក្របានបញ្ជាទំពួកគ្រឿងចក្រតំរង់ហ្វូងប្រជាជននោះ ដែលទង្វើនេះនឹងបង្កឱ្យមានគ្រោះថ្នាក់ជាខ្លាំង ។

នៅខណៈពេលបង្កហេតុនោះ អ្នកខ្លះក្នុងហ្វូងប្រជាជនដែលភាគច្រើនជាកុមារ បានចោលដុំថ្មសំដៅគ្រឿងចក្រ ធ្វើឱ្យបែកបង្អួច ។ បន្ទាប់មក បុគ្គលិកក្រុមហ៊ុនក៏បានរត់ចេញ ដោយបន្សល់ទុកគ្រឿងចក្រ និងរថយន្តចោលនៅទីកើតហេតុនោះ ។

អ្នកតំណាងសហគមន៍ដីក្រហមបានព្យាយាមធ្វើឱ្យហ្វូងប្រជាជនដែលមានកំហឹងបានស្ងប់ស្ងាត់ និងអំពាវនាវពួកគាត់តាមឧបករណ៍បំពងសំលេងសុំឱ្យឈប់ចោលដុំថ្ម ។ ភ្លាមនោះដែរ អ្នកតំណាងក្រុមហ៊ុន សេរិន អិន ជី បានទៅដាក់ពាក្យបណ្តឹងនៅការិយាល័យនគរបាលអំពីការខូចខាតទៅលើគ្រឿងចក្រ ។ អស់រយៈពេលជាង ២ម៉ោង ក្រុមហ៊ុន សេរិន អិន ជី មិនព្រមយករថយន្ត ឬគ្រឿងចក្រចេញពីទីកើតហេតុនោះទេ ។

នគរបាលដែលមានវត្តមាននៅនោះ មានឆន្ទៈតិចតួចក្នុងការធ្វើអន្តរាគមន៍ ឬធ្វើឱ្យមានភាពស្ងប់ស្ងាត់ទៅលើហ្វូងប្រជាជន- តាមពិត គឺអ្នកតំណាងសហគមន៍ផ្ទាល់ទេ ដែលបានចាត់ចែងកិច្ចការនេះ ។ នគរបាលឯកសណ្ឋានមួយចំនួនតូចត្រូវបានបញ្ជូនទៅកាន់កន្លែងកើតហេតុ ប៉ុន្តែក៏មានមន្ត្រីនគរបាលឯកសណ្ឋានស៊ីវិលមួយចំនួនធំដែរ ដែលគ្មានបានធ្វើអ្វីសោះ គ្រាន់តែពីសំលឹងមើល និងថតរូបថតតែប៉ុណ្ណោះ ។

*Licadho Offices:*
Banteay Meanchey: (054) 958 861
Battambang: (053) 952 828
Koh Kong: (035) 936 116
Kompong Cham: (042) 941 464
Kompong Chhnang: (026) 988 637
Kompong Speu: (025) 987 220
Kompong Thom: (062) 961 292
Kompot: (033) 932 663
Pursat: (052) 951 496
Siem Reap: (063) 964 066
Sihanoukville: (034) 933 716
Svay Rieng: (044) 945 833

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

#16 Street 99, P. O. Box 499
Phnom Penh, Cambodia
Tel: (855) 23 360 965 / 364 901
Fax: (855) 23 360 965 / 217 626
or +1 (815) 550 4474
Email: contact@licadho.org
Web Site: http://www.licadho.org/

- ថ្ងៃទី២៩ សីហា ក្រុមហ៊ុន សេរិន អិន ជី បាននាំកម្មករសំណង់បំពាក់ដោយដែកគាស់ស្រួច និងពូថៅ ទៅកាន់តំបន់ដីក្រហម ដើម្បីរុះរើទីទៅឈើរបស់ប្រជាជន ។ នៅពេលដែលប្រជាជនបានព្យាយាមរារាំងការរុះរើដោយអហិង្សា នគរបាលបានណែនាំកម្មករសំណង់ឱ្យសំរុកចូលក្នុងហ្វូងប្រជាជន ដែលទង្វើនេះងាយនឹងបង្កឱ្យមានការប្រឈមមុខហិង្សាដាក់គ្នា ។ ក្នុងកំឡុងពេលឧប្បត្តិហេតុ បុគ្គលិកក្រុមហ៊ុន សេរិន អិន ជី បានដាក់ខ្នោះស្ត្រីតំនាងសហគមន៍ម្នាក់ ដែលបានធ្វើការតវ៉ាដោយសន្តិវិធី ។
- ថ្ងៃទី២៧ កញ្ញា សន្តិសុខម្នាក់របស់ក្រុមហ៊ុន សេរិន អិន ជី បានប្តឹងនគរបាលថា អ្នកតំនាងសហគមន៍ដីក្រហមម្នាក់ បានលួចទូរស័ព្ទរបស់គាត់ ។ រឿងនេះបានកើតឡើងបន្ទាប់ពីការប្រវាយប្រតប់គ្នាមួយ នៅខណៈដែលសន្តិសុខនោះបានប្រើទូរស័ព្ទថតស្ត្រីតំនាងសហគមន៍ ដែលកំពុងធ្វើសន្និសិទការសែត ហើយទូរស័ព្ទនោះបានជ្រុះធ្លាក់ ។ សន្តិសុខនោះមិនបានរើសទូរស័ព្ទឡើងវិញទេ ហើយភ្លាមនោះ បានទៅប្តឹងនគរបាលថា អ្នកតំនាងសហគមន៍បានលួចយកទូរស័ព្ទរបស់គាត់ ។ សហគមន៍ក៏បានយកទូរស័ព្ទនោះទៅជូននគរបាល ។ ក្រោយមក អ្នកតំនាងសហគមន៍នោះត្រូវបានចោទប្រកាន់ពីបទប្លន់ ដែលអាចនាំទៅដល់ការកាត់ទោសជាប់ពន្ធនាគារ ១០ឆ្នាំ បើទោះបីជា មានការខ្វះខាតភស្តុតាងទាំងស្រុងក្តី ចំពោះបទល្មើសបែបនោះ ។
- កាលពីពីរថ្ងៃមុន គឺថ្ងៃទី២ ធ្នូ បុរសអ្នកតំនាងសហគមន៍ម្នាក់ទៀត បានទទួលការគំរាមសំលាប់ ។ បុរសនោះកំពុងជិះម៉ូតូរបស់គាត់ ហើយបានឈប់ភ្លាមនៅខណៈដែលបុរសមិនស្គាល់មុខម្នាក់ទៀតបានលេចមុខឡើង ដោយធ្វើការព្រមានថា " កុំខ្លាំង ប្រយ័ត្នស្លាប់ " ។

លោកស្រីវេជ្ជ.ពុង ឈីវកេក ប្រធានអង្គការ លីកាដូ មានប្រសាសន៍ថា "ភាពតានតឹងនៅតំបន់ដីក្រហមមានសភាពធ្ងន់ធ្ងរ ហើយភាគីពាក់ព័ន្ធ ដូចជា សហគមន៍ ក្រុមហ៊ុន និងអាជ្ញាធរ ត្រូវតែធ្វើការប្រកបដោយការស្តាបនាក្នុងការធ្វើឱ្យស្ថានភាពបានស្ងប់ស្ងាត់" "មធ្យោបាយល្អបំផុតចំពោះករណីនេះ គឺ ក្រុមហ៊ុន សេរិន អិន ជី និងអាជ្ញាធររដ្ឋាភិបាលត្រូវចរចារជាមួយសហគមន៍ឱ្យបានច្បាស់លាស់ រិះរកដំណោះស្រាយសមស្របណាមួយដែលគ្រប់ភាគីអាចទទួលយកបាន ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនង

លោក អំ សំអាត អ្នកគ្រប់គ្រងបច្ចេកទេសស៊ើបអង្កេត ០១២ ៣២៧ ៧៧០

*Licadho Offices:*
Banteay Meanchey: (054) 958 861
Battambang: (053) 952 828
Koh Kong: (035) 936 116
Kompong Cham: (042) 941 464
Kompong Chhnang: (026) 988 637
Kompong Speu: (025) 987 220
Kompong Thom: (062) 961 292
Kompot: (033) 932 663
Pursat: (052) 951 496
Siem Reap: (063) 964 066
Sihanoukville: (034) 933 716
Svay Rieng: (044) 945 833

## ឧបសម្ព័ន្ធទី២៥




ប្លង់អភិវឌ្ឍន៍លំនៅដ្ឋានរបស់ប្រជាពលរដ្ឋនៅតំបន់ដីក្រហម ស្ថិតក្នុងសង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

http://www.licadho.org/